ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គជអប

NCDD

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)

# របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ

# ស្តីពី

# ការអនុវត្តផែនការសកម្មភាព និងថវិកា ឆ្នាំ២០២២

# របស់ គ.ជ.អ.ប.

រៀបចំដោយ ៖ គ.ជ.អ.ប.

# អារម្ភកថា

ផែនការសកម្មភាព និងថវិកាឆ្នាំ២០២២ របស់ គ.ជ.អ.ប. គឺជាផែនការឆ្នាំទី២នៃការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ រយៈពេល១០ឆ្នាំ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ (កជទី២)។ ផែនការនេះផ្តោតជាសំខាន់លើការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ គ.ជ.អ.ប. អនុគណៈកម្មាធិការ គ.ជ.អ.ប. លេខាធិការដ្ឋាន គ.ជ.អ.ប. និងគណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការពង្រឹងរដ្ឋបាលក្រុង ស្រុកដែលជារដ្ឋបាលមូលដ្ឋានក្នុងការបំពេញមុខងាររបស់ខ្លួនស្របតាមចនាសម្ព័ន្ធថ្មី ការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងការអនុវត្តគោលការណ៍ បែបបទ និងនីតិវិធីនានាសម្រាប់គ្រប់គ្រងបុគ្គលិក និងការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ការបន្សុីគ្នារវាងកិច្ចដំណើរការកសាងផែនការ និងគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការពង្រឹងដំណើរការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ និងការលើកកម្ពស់ការវិនិយោគ និងការផ្តល់សេវាសាធារណៈនានាដែលពាក់ព័ន្ធនឹងភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ការការពារជំងឺឆ្លងរាតត្បាតកាចសាហាវនានា និងការលើកកម្ពស់សេវាសង្គមប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គម។

របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីការអនុវត្តផែនការសកម្មភាព និងថវិកា (ផ.ស.ថ.) ឆ្នាំ២០២២ របស់ គ.ជ.អ.ប. គ្របដណ្តប់រយៈពេល១២ខែ ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២២។ ជារួម ក្នុងអំឡុងពេលនេះ ទោះបីប្រទេសជាតិនៅបន្តជួបប្រទះបញ្ហាធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩ក៏ដោយ ក៏ គ.ជ.អ.ប. បានខិតខំប្រឹងប្រែងអនុវត្ត ផ.ស.ថ. ឆ្នាំ២០២២ និងសម្រេចបាននូវលទ្ធផលសំខាន់ៗចម្បងៗដូចជា ឯកសារ កជទី២ ត្រូវបានរៀបចំផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តជាផ្លូវការនៅខែមីនា ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ហើយផែនការអនុវត្ត០៥ឆ្នាំដំណាក់កាលទី១ ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥ (ផអ៥ទី១) នៃកជទី២ ត្រូវបានរៀបចំ និងអនុម័តដោយ គ.ជ.អ.ប. នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ ដោយមានមានការចូលរួម និងបានពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា។ ជាមួយគ្នានេះដែរ បណ្តាលិខិតបទដ្ឋានគតិយុត្តសំខាន់ៗពាក់ព័ន្ធនឹងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក៏ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តរួមមានដូចជា ច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលត្រូវបានប្រកាសឱ្យប្រើប្រាស់នៅខែមិថុនា ឆ្នាំ២០២២ ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ អនុក្រឹត្យស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត និងសេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិត្រូវបានរៀបចំ និងដាក់ជូនកិច្ចប្រជុំលើកទី២០របស់ គ.ជ.អ.ប. ពិនិត្យ និងផ្តល់យោបល់។

ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គោលការណ៍ បែបបទ និងនីតិវិធីនានាសម្រាប់ការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ កែសម្រួល និងដាក់ឱ្យអនុវត្ត សេចក្តីព្រាងលិខិតបទដ្ឋានស្តីពីការបរិយាយអំពីមុខតំណែងនានារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក៏ត្រូវបានរៀបចំឡើង ដើម្បីជាមូលដ្ឋានសម្រាប់ការកំណត់ចំនួនមន្ត្រី និងចំនួនមុខតំណែងវិជ្ជាជីវៈតាមអង្គភាពនីមួយៗនៃរដ្ឋបាលក្រុង ស្រុក និងជាមូលដ្ឋានសម្រាប់ការរៀបចំ ការជ្រើសរើស និងការអភិវឌ្ឍសមត្ថភាពមន្ត្រីថ្នាក់ក្រុង ស្រុក ខណ្ឌ ព្រមទាំងបានអភិវឌ្ឍសមត្ថភាពដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈសាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា។ ធនធានមូលនិធិនានាក៏ត្រូវបានវិភាជជូនរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ប្រភេទស្របតាមគោលការណ៍ លក្ខណៈវិនិច្ឆ័យ និងនីតិវិធីហិរញ្ញវត្ថុ រួមមាន ថវិការាជធានី ខេត្តមូលនិធិក្រុង ស្រុក មូលនិធិឃុំ សង្កាត់ និងមូលនិធិមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់។ យន្តការផ្តល់សេវារដ្ឋបាល និងយន្តការគណនេយ្យភាពសង្គមក៏ត្រូវបានពង្រឹង និងពង្រីកទៅថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀតតាមរយៈការបណ្តុះបណ្តាល ការរៀបចំឱ្យមាននីតិវិធីអនុវត្តច្បាស់លាស់ និងការរៀបចំជាបណ្តើរៗនូវយន្តការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (អនឡាញ)។

ទន្ទឹមនឹងលទ្ធផលចម្បងៗខាងលើនេះ ក៏មានបញ្ហាប្រឈមមួយចំនួនដែលពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗក្នុងការផ្ទេរមុខងារ ការគ្រប់គ្រងបុគ្គលិកនិងការអភិវឌ្ឍសមត្ថភាព ការផ្ទេរធនធានហិរញ្ញវត្ថុ និងការផ្តល់សេវាសាធារណៈដែលបញ្ហាទាំងនេះ ចាំបាច់ត្រូវដោះស្រាយជាបន្តបន្ទាប់ចាប់ពីឆ្នាំ២០២៣នេះតទៅ។

ក្នុងនាម គ.ជ.អ.ប. ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានាដែលបានចូលរួមទទួលខុសត្រូវ និងគាំទ្រដល់ការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២២ ឱ្យសម្រេចបាននូវលទ្ធផលសំខាន់ៗគួរឱ្យកត់សម្គាល់។ ខ្ញុំសង្ឃឹមថា ឯកឧត្តម លោកជំទាវ លោក លោកស្រីនឹងបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២៣ និងបន្តគាំទ្រដល់កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីឈានទៅសម្រេចបាននូវចក្ខុវិស័យ និងលទ្ធផលរំពឹងទុកនានាតាមកម្មវិធីដែលបានគ្រោងទុក។

ថ្ងៃចន្ទ ៦កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប.**

**សម្តេចក្រឡាហោម ស ខេង**

# មាតិកា


**អារម្ភកថា** ........................................ i

**មាតិកា** ........................................ iii

**អក្សរកាត់** ........................................ iv

១. សេចក្តីផ្តើម ........................................ ១

២. អំពីវឌ្ឍនភាពនៃការអនុវត្តសកម្មភាព ........................................ ២

ក. សមាសភាគទី១៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់ ............. ២

ខ. សមាសភាគទី២៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ......... ១០

គ. សមាសភាគទី៣៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ........................ ១៥

ឃ. សមាសភាគទី៤៖ វិមជ្ឈការហិរញ្ញវត្ថុនិងប្រព័ន្ធផែនការនិងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ...... ២០

ង. សមាសភាគទី៥៖ ការផ្តល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋាន .................... ២៣

៣. ស្ថានភាពហិរញ្ញវត្ថុ ........................................ ២៩

៤. បញ្ហាប្រឈម និងដំណោះស្រាយ ........................................ ៣១

៥. សកម្មភាពជាអាទិភាពសម្រាប់ឆ្នាំ២០២៣ ........................................ ៣៣

៦. សេចក្តីសន្និដ្ឋាន ........................................ ៣៧

**ឧបសម្ព័ន្ធ**

១. តារាងវឌ្ឍនភាពនៃការអនុវត្តសកម្មភាពជាអាទិភាពនីមួយៗ ........................ ៣៨

២. តារាងវឌ្ឍនភាពនៃការអនុវត្តថវិកាប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្ត ........................ ៨៤

៣. តារាងស្ថានភាពនៃការគ្រប់គ្រងហានិភ័យ ........................................ ៨៧

# អក្សរកាត់

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| គ.ជ.អ.ប. | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| កជទី១ | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី១ ពីឆ្នាំ ២០១០ ដល់ឆ្នាំ២០២០ |
| កជទី២ | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ |
| ផអ៥ទី១ | ផែនការអនុវត្តរយៈពេលប្រាំឆ្នាំ(២០២១-២០២៥)ដំណាក់កាលទី១នៃ កជទី២ |
| ផ.ស.ថ. | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ |
| គ.ដ.វ.វ. | គណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ |
| គ.ក.ស.ក. | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| គ.ក.ន.ក. | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ |
| SNIF | មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ |
| I4Cs | កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ |
| ISAF | ផែនការអនុវត្តគណនេយ្យភាពសង្គម |
| TSSD-AF/ADB | ការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូច ដំណាក់កាលទី២ |
| NASLA/ADB | គម្រោងគាំទ្រសាលាជាតិរដ្ឋបាលមូលដ្ឋាន |
| ASPIRE/IFAD | គម្រោងផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីធន់នឹងការប្រែប្រួលអាកាសធាតុ |
| LGCC/UNCDF | គម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ |
| UNICEF | មូលនិធិកុមាររបស់អង្គការសហប្រជាជាតិ |
| STARD/UNDP | គម្រោងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាថាមពលពន្លឺព្រះអាទិត្យសម្រាប់វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទនៅកម្ពុជា |
| EmPower/ UNEP | គម្រោងពង្រឹងសិទ្ធិអំណាចស្ត្រីដើម្បីសង្គមធន់នឹងការប្រែប្រួលអាកាសធាតុ |
| CNP/WB | គម្រោងអាហារូបត្ថម្ភនៅកម្ពុជា |
| SRELFOODS/ WFP | គម្រោងសន្តិសុខស្បៀង និងការគាំទ្រការស្តារឡើងវិញរបស់សហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់ដោយសារទឹកជំនន់នៅប្រទេសកម្ពុជា |
| ISD/GIZ | កម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា |
| CCCA | គម្រោងធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា |
| GCF | គម្រោងគាំទ្រស្ថាប័នទទួលហិរញ្ញប្បទានផ្ទាល់នៅកម្ពុជា ដើម្បីបំពេញលក្ខខណ្ឌទទួលស្គាល់ |
| CSOs | អង្គការសង្គមស៊ីវិល |

## ១. សេចក្ដីផ្ដើម

ផែនការសកម្មភាព និងថវិកា (ផ.ស.ថ.) ប្រចាំឆ្នាំ២០២២ របស់ គ.ជ.អ.ប. ស្ដីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាផែនការឆ្នាំទី២នៃការអនុវត្ត កជទី២ (២០២១-២០៣០) ដែលត្រូវបានអនុម័តដោយ គ.ជ.អ.ប. នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២ ផែនការនេះ រួមមានលទ្ធផលរំពឹងទុកចំនួន**៣៤** សកម្មភាពជាអាទិភាពចំនួន**៨៥** និងអនុសកម្មភាពចំនួន**២៥០** និងគម្រោងថវិកាចំណាយសរុបមានចំនួន**៤.៥៥៦.៦២៧ លានរៀល** ស្មើនឹង**១.១៣៩ លានដុល្លារ** ក្នុងនោះថវិការបស់រាជរដ្ឋាភិបាលមានចំនួន **៤.២៩០.៦១៨ លានរៀល** ស្មើនឹង**៩៤,១៦%** និងថវិកាកម្ចី និងជំនួយឥតសំណងគាំទ្រដោយដៃគូអភិវឌ្ឍន៍នានាមានចំនួន**២៦៦.០០៨ លានរៀល (៦៧លានដុល្លារ)** ស្មើនឹង**៥.៨៤%**។

ផ.ស.ថ. ឆ្នាំ២០២២ របស់ គ.ជ.អ.ប. រួមមាន ៥សមាសភាគដូចខាងក្រោម៖

- សមាសភាគទី១ ៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់
- សមាសភាគទី២ ៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សមាសភាគទី៣ ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស
- សមាសភាគទី៤ ៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិកាថ្នាក់ក្រោមជាតិ
- សមាសភាគទី៥ ៖ ការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

**តារាងទី១ ៖ ផែនការចំណាយសរុបតាមសមាសភាគសម្រាប់ឆ្នាំ២០២២ (គិតជាលានរៀល)**

| ល.រ. | សមាសភាគ | ថវិការាជរដ្ឋាភិបាល | ថវិកាកម្ចី | ថវិកាជំនួយឥតសំណង | សរុប |
|---|---|---|---|---|---|
| ១ | ការដឹកនាំ និងសម្របសម្រួលការងារកំណែទម្រង់ | 9,557 | 0 | 0 | 9,557 |
| ២ | រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ | 9,753 | 0 | 16,736 | 26,489 |
| ៣ | ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សថ្នាក់ក្រោមជាតិ | 3,905 | 4,055 | 0 | 7,960 |
| ៤ | វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិកាថ្នាក់ក្រោមជាតិ | 4,265,113 | 120,705 | 0 | 4,385,818 |
| ៥ | ការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន | 2,291 | 101,735 | 22,777 | 126,803 |
| | **សរុបរួម** | **4,290,618** | **226,495** | **39,513** | **4,556,627** |
| | **គិតជាភាគរយ** | **94.16%** | **4.97%** | **0.87%** | **100%** |

របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនេះរៀប រាប់អំពីស្ថានភាពនៃការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២២របស់ គ.ជ.អ.ប.គិតពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២២ រួមមាន៖ វឌ្ឍនភាពនៃការអនុវត្តសកម្មភាពស្ថានភាពនៃការប្រើប្រាស់ថវិកា បញ្ហាប្រឈមនានា និងសកម្មភាពជាអាទិភាពសម្រាប់អនុវត្តឆ្នាំ២០២៣។

## ២. អំពីវឌ្ឍនភាពនៃការអនុវត្តសកម្មភាព

ក្នុងចំណោមសកម្មភាពជាអាទិភាពទាំង **៨៥** នៃ ផ.ស.ថ. ឆ្នាំ២០២២របស់ គ.ជ.អ.ប. មានសកម្មភាពជាអាទិភាពចំនួន **៧៣** ស្មើនឹង **៨៦%** ត្រូវបានអនុវត្តដូចមានសង្ខេបក្នុងតារាងខាងក្រោម។

**តារាងទី២ ៖ ស្ថានភាពនៃការអនុវត្តសកម្មភាពជាអាទិភាព**




| **សមាសភាគ** | **បរិយាយ** | **សកម្មភាពអាទិភាព** | **បានអនុវត្ត (ចំនួន)** | **បានអនុវត្ត (%)** |
|---|---|---|---|---|
| ១ | ការដឹកនាំ និងសម្របសម្រួលការងារកំណែទម្រង់ | 21 | 18 | 85% |
| ២ | របនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ | 12 | 9 | 75% |
| ៣ | ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សថ្នាក់ក្រោមជាតិ | 22 | 20 | 90% |
| ៤ | វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិកាថ្នាក់ក្រោមជាតិ | 20 | 16 | 80% |
| ៥ | ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន | 10 | 10 | 100% |
| **សរុប** | | **85** | **73** | **86%** |

លទ្ធផលសំខាន់ៗនៃការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំ២០២២ មានរៀបរាប់តាមសមាសភាគនីមួយៗដូចខាងក្រោម ៖

## ក. សមាសភាគទី១÷ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់

សមាសភាគទី១នេះ រួមមានសកម្មភាពជាអាទិភាពចំនួន**២១** ក្នុងនោះមានសកម្មភាពអាទិភាពចំនួន**១៨** ត្រូវបានអនុវត្ត ដោយមានវឌ្ឍនភាពដូចខាងក្រោម៖

**១. ការបន្តពង្រឹងតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់**

ក្នុងឆ្នាំ២០២២នេះ គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំចំនួន២លើក គឺលើកទី១ ជាកិច្ចប្រជុំលក្ខណៈចង្អៀតក្នុងចំណោមក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.អ.ប. ចំនួន០៤ក្រសួង រួមមាន ក្រសួងមហាផ្ទៃ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួងយុត្តិធម៌ដោយមានការចូលរួមពីតំណាងក្រុមអ្នកច្បាប់នៃទីស្តីគណៈរដ្ឋមន្ត្រីនាថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២ ដើម្បីពិនិត្យ និងឯកភាពលើគោលការណ៍សំខាន់ៗពាក់ព័ន្ធនឹងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ សេចក្តីព្រាងច្បាប់ស្តីពីជលផល និងសេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។ ចំណែកកិច្ចប្រជុំលើកទី២ ជាកិច្ចប្រជុំលើកទី២០ របស់ គ.ជ.អ.ប. ដែលត្រូវបានរៀបចំឡើងនាថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២ ដោយពិនិត្យសម្រេចទៅលើរបៀបវារៈសំខាន់ៗរួមមាន (១). ការពិនិត្យ និងឯកភាពលើសេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ សេចក្តីព្រាងច្បាប់ស្តីពីជលផល និងសេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (២). ការពិនិត្យ និងអនុម័តផអ៥ទី១ នៃកជទី២ និង (៣). ការពិនិត្យ និងផ្តល់យោបល់លើវឌ្ឍនភាពនៃការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**២. ការពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.**

លេខាធិការដ្ឋាន គ.ជ.អ.ប. បានរៀបចំ និងដាក់ឱ្យដំណើរការនូវក្រុមការងារទទួល និងដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងការអនុវត្តគម្រោងនិងកម្មវិធីនានាក្នុងក្របខ័ណ្ឌកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងបានអភិវឌ្ឍសមត្ថភាពដល់មន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប. រួមមានដូចជា៖

- សិក្ខាសាលាពង្រឹងសមត្ថភាពដល់មន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីរៀបចំសំណើគម្រោងស្របតាមគោលការណ៍និងនីតិវិធីរបស់មូលនិធិអាកាសធាតុបៃតងដោយមានអ្នកចូលរួមសរុប ៣២រូប ក្នុងនោះស្ត្រី១១រូប នាថ្ងៃទី៤ ដល់ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២
- សិក្ខាសាលាពង្រឹងសមត្ថភាពតាមអនឡាញអំពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ការរៀបចំសំណើគម្រោងនិងការអនុវត្តគម្រោង ការរៀបចំផែនការសកម្មភាព និងការវិភាគទិន្នន័យគម្រោងដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុតាមរយៈការសម្របសម្រួលដោយមូលនិធិអាកាសធាតុបៃតងនាថ្ងៃទី០១-១៩ ខែកក្កដា ឆ្នាំ២០២២
- វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិស្តីពីកិច្ចប្រតិបត្តិការមូលនិធិគាំទ្រការផ្តល់សេវាឃុំសង្កាត់ នៃគម្រោងអាហារូបត្ថម្ភនៅកម្ពុជាចំនួន០៤វគ្គ ដោយមានអ្នកចូលរួមចំនួន៩៧នាក់ ស្ត្រីចំនួន២៧នាក់ ក្នុងឆ្នាំ២០២២
- វគ្គបណ្តុះបណ្តាលការអភិវឌ្ឍសមត្ថភាពលើភាពជាអ្នកដឹកនាំរបស់មន្ត្រីរាជការជាស្ត្រីនាថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២
- ថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានចូលរួមវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំចំនួន៩០នាក់ ស្ត្រីចំនួន៩០នាក់
- វគ្គបណ្តុះបណ្តាលអំពីសៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការកម្មវិធី និងសវនកម្មផ្ទៃក្នុងនាថ្ងៃទី៩ ដល់ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ អ្នកចូលរួមសរុបចំនួន៧១នាក់ ស្ត្រីចំនួន២៦នាក់មកពីរាជធានី ខេត្តទាំង២៥

- ការបញ្ជូនមន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប. ចំនួន១នាក់ ទៅទទួលការបណ្តុះបណ្តាលរយៈពេលខ្លីនៅក្រៅប្រទេសពាក់ព័ន្ធនឹងប្រធានបទស្តីពីរដ្ឋាភិបាលអេឡិចត្រូនិក និងគ្រប់គ្រងរដ្ឋបាលសាធារណៈនៅប្រទេសកូរ៉េ ( Master in E-Government and Public Management ) នាខែសីហា ឆ្នាំ២០២១ ដល់ខែកុម្ភៈ ឆ្នាំ២០២៣
- ការបញ្ជូនមន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប. ចំនួន១នាក់ ទៅទទួលការបណ្តុះបណ្តាលរយៈពេលខ្លីនៅក្រៅប្រទេសពាក់ព័ន្ធនឹងប្រធានបទស្តីពីអភិបាលកិច្ច និងរដ្ឋបាលសាធារណៈនៅទីក្រុងហ្សូរីច ប្រទេសស្វីស នាថ្ងៃទី២៣ ខែសីហា ដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២
- ការរៀបចំ និងសម្របសម្រួលសិក្ខាសាលា (តាមរយៈ Zoom) ស្តីពីការពង្រឹងលទ្ធិប្រជាធិបតេយ្យសម្រាប់ប្រជាជន និងបទពិសោធន៍នៃការអនុវត្តនៅប្រទេសចិននាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ ដោយសហការជាមួយបណ្តាញអង្គការមិនមែនរដ្ឋាភិបាលនៃប្រទេសចិនសម្រាប់ការផ្លាស់ប្តូរអន្តរជាតិ និងវិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍកម្ពុជាដែលមានសិក្ខាកាមសរុបចំនួន៤៥៧នាក់មកពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល។

## ៣. ការលើកកម្ពស់ប្រសិទ្ធភាពដឹកនាំរបស់គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ (គ.ដ.វ.វ.)

គ.ដ.វ.វ. នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ បានរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីបូកសរុបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២១ និងការត្រួតពិនិត្យការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២២ ព្រមទាំងការរៀបចំ ផ.ស.ថ. ឆ្នាំ២០២៣។ ទន្ទឹមនឹងនេះ សេចក្តីសម្រេចរួមរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយនឹងក្រសួង ស្ថាប័ន ពាក់ព័ន្ធចំនួន១៧ និងរដ្ឋបាលរាជធានី ខេត្តទាំង២៥ត្រូវបានរៀបចំ ចុះហត្ថលេខា និងអនុវត្ត។ ក្រៅពីនេះ រដ្ឋបាលខេត្តត្បូងឃ្មុំបានពិនិត្យ និងកែសម្រួលសមាសភាព គ.ដ.វ.វ. របស់ខ្លួនដោយបញ្ចូលតំណាងមកពីមន្ទីរ អង្គភាពពាក់ព័ន្ធមួយចំនួនជាសមាជិក គ.ដ.វ.វ.។

## ៤. ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានា

លេខាធិការដ្ឋាននៃកំណែទម្រង់៣បូក១ (លេខាធិការដ្ឋាន គ.ជ.អ.ប. លេខាធិការដ្ឋានកំណែទម្រង់រដ្ឋបាលសាធារណៈ អគ្គលេខាធិការដ្ឋានកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអគ្គលេខាធិការដ្ឋានកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌) បានរៀបចំកិច្ចប្រជុំជាទៀងទាត់ប្រចាំត្រីមាស និងតាមវេនដឹកនាំរបស់លេខាធិការដ្ឋាន/អគ្គលេខាធិការដ្ឋាននីមួយៗ ព្រមទាំងបានរៀបចំកិច្ចប្រជុំដោយឡែកចំនួន០៤លើក ដើម្បីពិនិត្យ និងរៀបចំឯកសារទស្សនទានស្តីពីចក្ខុវិស័យ និងយុទ្ធសាស្ត្រសុខដុមនីយកម្មនៃកំណែទម្រង់៣បូក១ ផែនការអនុវត្តឯកសារទស្សនទាន និងអនុក្រឹត្យស្តីពីការបង្កើតយន្តការនៃលេខាធិការដ្ឋាន៣បូក១។ លេខាធិការដ្ឋាននៃកំណែទម្រង់៣បូក១បានសហការគ្នារៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានានូវឯកសារ

ទស្សនទានស្តីពីចក្ខុវិស័យ និងយុទ្ធសាស្ត្រសុខដុមនីយកម្មនៃកំណែទម្រង់៣បូក១ ផែនការអនុវត្តឯកសារទស្សនទាន និងអនុក្រឹត្យស្តីពីការបង្កើតយន្តការនៃលេខាធិការដ្ឋាន៣បូក១ នាថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២ ក្រោមអធិបតីភាព**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប. ក្នុងពិធីបិទ និងក្រោមអធិបតីភាព**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការដឹកនាំការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងពិធីបើក។

**៥. ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានាប្រកបដោយភាពស្ថាបនា**

បានសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍នានានិងអង្គការសង្គមស៊ីវិលដែលជាសមាជិកក្រុមការងារបច្ចេកទេសស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (TWG-SNDD) ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងឯកសារ ផអ៥ទី១ (២០២១-២០២៥)។

**៦. ការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ**

ក្រុមការងារយេនឌ័រសម្រាប់គាំទ្រការអនុវត្ត កជទី២ នៃលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបានពិនិត្យ និងកែសម្រួលទាំងសមាសភាព និងតួនាទី ភារកិច្ច និងការទទួលខុសត្រូវ។ គណៈកម្មការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ និងគណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ បានរៀបចំកិច្ចប្រជុំរបស់ខ្លួនជាទៀងទាត់ ដើម្បីពិនិត្យអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។ ទន្ទឹមនឹងនោះ លេខាធិការដ្ឋាន គ.ជ.អ.ប. ក៏បានសហការជាមួយនឹងក្រសួងកិច្ចការនារីដោយមានការគាំទ្រពីកម្មវិធីធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈនៅប្រទេសកម្ពុជា (ISD/GIZ) បាននិងកំពុងរៀបចំកែសម្រួលផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

គិតមកដល់ចុងឆ្នាំ២០២២នេះ ចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិសម្រេចបានដូចខាងក្រោម៖

- មុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត ចំនួន៧៦នាក់ ស្មើនឹង ១២.១២%
- មុខតំណែងគ្រប់គ្រងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំនួន៧៦៦នាក់ ស្មើនឹង១៩.៥២%
- មុខតំណែងគ្រប់គ្រងនៅរដ្ឋបាលឃុំ សង្កាត់ រួមមានមេឃុំ ចៅសង្កាត់មានចំនួន១៧៣នាក់ ស្មើនឹង១០.៤៧% ជំទប់ទី១មានចំនួន៣១៩ ស្មើ១៩.៣១% ជំទប់ទី២មានចំនួន១៨៩ ស្មើ ១១.៤៤%

## ៧. ការកែលម្អ និងការពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង

យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងក្នុងក្របខ័ណ្ឌកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ និងកែសម្រួលដោយផ្តោតជាសំខាន់ទៅលើមធ្យោបាយ និងវិធីសាស្ត្រនៃការទំនាក់ទំនង និងការផ្សព្វផ្សាយព័ត៌មាន ដើម្បីលើកកម្ពស់ការប្រាស្រ័យទាក់ទង និងការចែករំលែកព័ត៌មានឱ្យបានទូលំទូលាយទៅដល់អ្នកពាក់ព័ន្ធ និងសាធារណជននានា ដែលមានស្រាប់សម្រាប់ជាមូលដ្ឋានក្នុងការកែសម្រួលយុទ្ធសាស្ត្រនេះ។ ឯកសារយុទ្ធសាស្ត្រនេះនឹងត្រូវពិនិត្យ កែសម្រួល និងអនុម័តក្នុងឆ្នាំ២០២៣។

## ៨. ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង

បានរៀបចំ និងផ្សព្វផ្សាយឯកសារព័ត៌មានសំខាន់ៗដែលពាក់ព័ន្ធទៅនឹងចក្ខុវិស័យ គោលបំណង គោលដៅ និងសមិទ្ធផល លទ្ធផលរំពឹងទុកនានានៃ កជទី២ ព្រមទាំងផ្សព្វផ្សាយអំពីសមិទ្ធផលនានាដែលសម្រេចបានក្នុងការអនុវត្ត កជទី១ ដែលរួមមានដូចខាងក្រោម៖

- ឯកសារព័ត៌មានចំនួន៤៦៤ឯកសារ ត្រូវបានដាក់បញ្ចូល និងផ្សព្វផ្សាយក្នុងគេហទំព័រ និងក្នុងបណ្តាញសង្គមរួមមាន Facebook និង YouTube
- ខិតប័ណ្ណផ្សព្វផ្សាយស្តីពីខ្លឹមសារសំខាន់ៗនៃ កជទី២
- បោះពុម្ពផ្សព្វផ្សាយផ្ទាំងព័ត៌មានបញ្ឈរ (I-Stand) អំពីសេចក្តីសង្ខេប និងសមិទ្ធផលសំខាន់ៗនៃកម្មវិធីជាតិដំណាក់កាលទី១ និងកម្មវិធីជាតិដំណាក់កាលទី២
- អនុសាសន៍សំខាន់ៗរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល និងគណៈកម្មាធិការជាតិនៃកំណែទម្រង់ស្នូលនានារបស់រាជរដ្ឋាភិបាល
- បោះពុម្ពប្រតិទិន និងសៀវភៅទិនានុលេខន៍ប្រចាំឆ្នាំ២០២២ និងឆ្នាំ២០២៣
- ផលិតវីដេអូបទយកការខ្លីស្តីពីការដឹកនាំល្អរបស់មេឃុំក្នុងការផ្តល់សេវា និងអភិវឌ្ឍមូលដ្ឋាន
- បានរៀបចំមាតិកាខ្លីៗ (Contents) ដើម្បីផ្សព្វផ្សាយដល់សាធារណជន
- ផលិតវីដេអូស្តីពីសាវតារគម្រោងការធ្វើឱ្យប្រសើរនូវមូលដ្ឋានទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា
- វគ្គបណ្តុះបណ្តាលស្តីពីការសរសេរអត្ថបទព័ត៌មានសម្រាប់ផ្សព្វផ្សាយដល់មន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប. បង្រៀនដោយអ្នកជំនាញផ្នែកទំនាក់ទំនងមកពីស្នាក់ការកណ្តាលរបស់ GIZ។

## ៩. ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការអនុវត្តដំណាក់កាលនីមួយៗនៃ កជទី២

កជទី២ (២០២១-២០៣០) ត្រូវបានប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដោយមានការចូលរួមពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យ

ឯកជន និងភាគីពាក់ព័ន្ធនានាដែលមានអ្នកចូលរួមដោយផ្ទាល់ប្រមាណជាង ៤០០នាក់ និងតាមរយៈប្រព័ន្ធបញ្ជូនសំឡេង និងរូបភាពពីចម្ងាយ (Zoom) ប្រមាណជាង ៧.០០០នាក់។

ផែនការអនុវត្តរយៈពេល៥ឆ្នាំដំណាក់កាលទី១ (២០២១-២០២៥) ដែលត្រូវបានរៀបចំឡើងដោយមានការចូលរួម និងការផ្តល់យោបល់ពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ត្រូវបានពិនិត្យ និងអនុម័តក្នុងកិច្ចប្រជុំលើកទី២០របស់ គ.ជ.អ.ប. ដែលបានរៀបចំនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២ និងបានផ្សព្វផ្សាយអនុវត្ត។

## ១០. ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប.

ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០២២របស់ គ.ជ.អ.ប. (ផ.ស.ថ.) ត្រូវបានរៀបចំឡើងដោយការដាក់បញ្ចូលនូវផែនការសកម្មភាព និងថវិការបស់ក្រសួង ស្ថាប័នអនុវត្តនីមួយៗ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងដោយមានការពិភាក្សា និងពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា។ ផ.ស.ថ. ឆ្នាំ២០២២ ត្រូវបានផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តដោយសម្រេចបានលទ្ធផលសំខាន់ៗ និងបញ្ហាប្រឈមនានាដូចមានកំណត់ក្នុងរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ២០២២។

ទន្ទឹមនេះ របាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមប្រចាំឆ្នាំ២០២១ស្តីពីការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប. ត្រូវបានរៀបចំ និងអនុម័តនាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ និងបានផ្សព្វផ្សាយ។

## ១១. ការរៀបចំ និងការដាក់បញ្ចូលកិច្ចការ ឬគម្រោងនានានៃ កជទី២ ទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័នអនុវត្តនីមួយៗ

លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនានានៃ កជទី២ ត្រូវបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤ របស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងរដ្ឋបាលរាជធានី ខេត្តទាំង ២៥។ ជាមួយគ្នានេះ សកម្មភាពជាអាទិភាពនានាពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានដាក់បញ្ចូលទៅក្នុង ផ.ស.ថ. ប្រចាំឆ្នាំ២០២២របស់ក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ១២. ការរៀបចំគម្រោងនានាគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ ឬអង្គការសង្គមស៊ីវិលនានាដោយបន្សុីជាមួយ កជទី២

គម្រោង និងកម្មវិធីជាច់ដោយឡែកចំនួន១២ ដែលគ្រប់គ្រង និងដឹកនាំសម្របសម្រួលដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបានរៀបចំតាមរយៈកិច្ចព្រមព្រៀងរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងដៃគូអភិវឌ្ឍន៍ ព្រមទាំងបានអនុវត្តដោយសម្រេចបាននូវលទ្ធផលសំខាន់ៗជាច្រើនដែលជាការរួមចំណែកដល់ការសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅនៃ កជទី២។ គម្រោង និងកម្មវិធីទាំងនេះបានផ្តោតទៅលើការកែលម្អលក្ខខណ្ឌសេដ្ឋកិច្ចនិងសង្គមរបស់កសិករខ្នាតតូចជុំវិញបឹងទន្លេសាប ការធ្វើប្រសើរឡើងនូវការប្រើប្រាស់និងគុណភាពសេវាសុខភាពមាតា កុមារនិងអាហារូបត្ថម្ភដោយផ្តោតលើការ

ជំរុញឱ្យមានតម្រូវការនិងគណនេយ្យភាពនៅកម្រិតសហគមន៍ ការកសាងសមត្ថភាព កសាងហេដ្ឋារចនាសម្ព័ន និងការរៀបចំប្រព័ន្ធហិរញ្ញវត្ថុសម្រាប់វិនិយោគលើការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ ការពង្រឹងសមត្ថភាពមន្ត្រីគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ ពង្រឹងភាពអង់អាចដល់ស្ត្រីដើម្បីសង្គមធននឹងដើម្បីជួយដល់សហគ្រិនស្ត្រីឬក្រុមកែលម្អជីវភាពដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ការកសាងភាពធនទៅនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្មតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាថាមពលពន្លឺព្រះអាទិត្យ ពង្រីកការអនុវត្តមូលនិធិធន់ទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជាតាមរយៈការដោះស្រាយផ្គត់ផ្គង់ទឹកស្អាត និងការកសាងសមត្ថភាពក្នុងការអនុវត្តមុខងារគ្រប់គ្រងទឹកស្អាតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ លើកកម្ពស់ការផ្តល់សេវានិងអភិវឌ្ឍន៍មូលដ្ឋានដោយរដ្ឋបាលថ្នាក់ក្រោមជាតិ លើកកម្ពស់ស្ត្រី កុមារ និងងាយជនរងគ្រោះ

ជាមួយគ្នានេះ គម្រោង/កម្មវិធីដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍បានជួយគាំទ្រដល់កម្មវិធីជាតិលើសកម្មភាពមួយចំនួនពាក់ព័ន្ធនឹងការគាំទ្រជំនួយបច្ចេកទេស ការចំណាយប្រតិបត្តិការ ការពង្រឹងសមត្ថភាព ការសិក្សា និងវាយតម្លៃសវនកម្មផ្ទៃក្រៅ រួមមានដូចជា ISAF, DAR-ISD/GIZ, NASLA/ ADB, SNIF/ADB, Readiness/GCF, LGCC-WRP, Empower, SRELFOODS ។

## ១៣. ការរៀបចំ និងការអនុវត្តសាកល្បងនូវគំនិតផ្តួចផ្តើមថ្មីៗ

គម្រោងសាកល្បងដែលពាក់ព័ន្ធនឹងការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក ក្នុងការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងភាពជាដៃគូជាមួយវិស័យឯកជនត្រូវបានរៀបចំ និងអនុវត្តសាកល្បងនៅឃុំបាសាក់ ស្រុករុក្ខគិរី ខេត្តបាត់ដំបង និងកំពុងបន្តសិក្សារៀបចំជាគម្រោងសម្រាប់ការអនុវត្តសាកល្បងនៅថ្នាក់ក្រុង ស្រុកដទៃទៀតក្នុងឆ្នាំ២០២៣។

## ១៤. ការសម្របសម្រួល ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តកថទី២

លេខាធិការដ្ឋាន គ.ជ.អ.ប. បានសម្របសម្រួល គាំទ្រ និងតាមដានការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំ ២០២២ របស់ គ.ជ.អ.ប. ដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការសម្រេចបាននូវលទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនានាដែលបានគ្រោងក្នុង ផ.ស.ថ. ឆ្នាំ២០២២របស់ គ.ជ.អ.ប .។ របាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈម ស្តីពីការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២១របស់ គ.ជ.អ.ប. ត្រូវបានរៀបចំ និងអនុម័តនាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ និងផ្សព្វផ្សាយ។

## ១៥. រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័នពាក់ព័ន្ធនានាត្រូវបានកែសម្រួលដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ

ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបាននិងកំពុងពិនិត្យ និងកែសម្រួលនូវរចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធគ្រប់គ្រងរបស់ខ្លួន ដើម្បីឱ្យស្របទៅតាមមុខងារដែលបានផ្ទេរ

និងមានលក្ខណៈងាយស្រួលក្នុងការផ្តល់ការគាំទ្រ ត្រួតពិនិត្យ និងវាយតម្លៃដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច។

**១៦. ការពង្រឹងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

បានរៀបចំកិច្ចប្រជុំ ការផ្សព្វផ្សាយ និងការអភិវឌ្ឍសមត្ថភាពពាក់ព័ន្ធនឹងការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន៖

- កិច្ចប្រជុំក្រុមប្រឹក្សាជាតិរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដោយមានអ្នកចូលរួមសរុបចំនួន៣២១រូប ក្នុងនោះមានស្ត្រីចំនួន៧២រូប ដើម្បីពិនិត្យ និងពិភាក្សាឯកសារទស្សនទានស្តីពីកម្មវិធីពានរង្វាន់ឧត្តមភាពការងាររៀបចំទីប្រជុំជន ក្រោមការគាំទ្រពីគម្រោងពង្រឹងសមត្ថភាពអាជ្ញាធរថ្នាក់ក្រោមជាតិនៅកម្ពុជាក្នុងការរៀបចំផែនការនគរូបនីយកម្ម និងការគ្រប់គ្រងដីធ្លី ដើម្បីកែប្រែមុខមាត់សហគមន៍មិនទាន់រៀបរយ និងធានានូវលទ្ធភាពក្នុងការទទួលបាននូវសេវាសាធារណៈជាសារវ័ន្ត
- កិច្ចប្រជុំថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិ ដើម្បីពិនិត្យកែសម្រួលសមាសភាពគណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារ និងការបែងចែកភារកិច្ចថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិទទួលបន្ទុកតាមរាជធានី ខេត្ត
- កិច្ចប្រជុំរវាងគណៈកម្មការទទួលបន្ទុកកិច្ចការស្ត្រី និងកុមាររបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសមាជិកក្រុមប្រឹក្សារាជធានី ខេត្តទាំង២៥
- កិច្ចប្រជុំថ្នាក់ដឹកនាំសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ដើម្បីពិនិត្យ និងពិភាក្សាលើការកែសម្រួលអង្គអភិបាលកិច្ចរបស់សមាគមសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រចាំឆ្នាំ២០២២
- ការផ្សព្វផ្សាយពីលទ្ធផលនៃវេទិកាថ្នាក់ខេត្តទាំង៤ (ខេត្តបាត់ដំបង ខេត្តស្វាយរៀង ខេត្តក្រចេះ និងខេត្តព្រះវិហារ) ដល់ក្រុមប្រឹក្សាជាតិរបស់សម្ព័ន្ធភាពជាតិ ដើម្បីចែករំលែកបទពិសោធន៍ល្អ និងបញ្ហាប្រឈមនានា ដែលកើតមានឡើងនៅក្នុងមូលដ្ឋានសំដៅពង្រឹងការអនុវត្តតួនាទីរបស់ក្រុមប្រឹក្សា
- ការបណ្តុះបណ្តាលលេខាធិការសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្តស្តីពីការងារលទ្ធកម្ម និងកិច្ចការរដ្ឋបាល
- ការបណ្តុះបណ្តាលថ្នាក់ដឹកនាំសមាគមជាតិ និងប្រធានក្រុមប្រឹក្សារាជធានី ខេត្តអំពីខ្លឹមសារនៃអនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការរៀបចំវគ្គបណ្តុះបណ្តាលដល់គណៈកម្មការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ និងគណៈកម្មការអភិវឌ្ឍសមត្ថភាពសមាគមជាតិស្តីពីជំនាញសម្របសម្រួល ជំនាញធ្វើបទបង្ហាញ និងការនិយាយជាសាធារណៈ។

**១៧. ការសិក្សាអំពីជម្រើសនៃការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

ផ្អែកតាមសំណើរបស់សមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ លេខាធិការដ្ឋាន គ.ជ.អ.ប. កំពុងរៀបចំផែនការ និងវិធីសាស្ត្រនៃការសិក្សា វាយតម្លៃ និងកំណត់អំពីជម្រើសសមស្របនានាសម្រាប់ការកែសម្រួលរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។

**១៨. ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយនានាពាក់ព័ន្ធនឹងកំណែទម្រង់**

អង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា ត្រូវបានអញ្ជើញ និងលើកទឹកចិត្តក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការរៀបចំផែនការអនុវត្ត៥ឆ្នាំដំណាក់កាលទី១ (២០២១-២០២៥) ការរៀបចំសេចក្ដីព្រាងច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិ និងបណ្ដាលិខិតបទដ្ឋាននានា ឯកសារបច្ចេកទេសនានាក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ជាមួយគ្នានេះ លេខាធិការដ្ឋាន គ.ជ.អ.ប. បានសហការក្នុងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម ការពង្រឹងយន្តការសម្រុះសម្រួល និងដោះស្រាយវិវាទរដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងគម្រោង កម្មវិធីពាក់ព័ន្ធផ្សេងទៀត។

## ខ. សមាសភាគទី២ ៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

សមាសភាគទី២នេះ រួមមានសកម្មភាពជាអាទិភាពចំនួន**១២** ក្នុងនោះមានសកម្មភាពអាទិភាពចំនួន**០៩** ត្រូវបានអនុវត្ត ដោយមានវឌ្ឍនភាពដូចខាងក្រោម ៖

**១. ការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់រដ្ឋបាលក្រុង ស្រុក**

លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមាន៖

- វគ្គបណ្ដុះបណ្ដាលអំពីការគ្រប់គ្រង តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌចំនួន**២៧វគ្គ** ត្រូវបានរៀបចំសម្រាប់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន**៧៦២នាក់** ក្នុងនោះស្ត្រីចំនួន**២០៣នាក់** ដោយសាលាជាតិរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ
- វគ្គបណ្ដុះបណ្ដាលជំហានទី៤ស្ដីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការផ្ដល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីការិយាល័យច្រកចេញចូលតែមួយនៅខេត្តកំពង់ធំ។ វគ្គបណ្ដុះបណ្ដាលអំពីបែបបទ និងនីតិវិធីផ្ដល់សេវារដ្ឋបាលក្នុងវិស័យដឹកជញ្ជូនផ្លូវគោកចំនួន**១៤វគ្គ** ត្រូវបានរៀបចំសម្រាប់ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន**១១៩គោលដៅ**។ កិច្ចប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានពាក់ព័ន្ធនឹងការផ្ដល់សេវារដ្ឋបាលក្នុងវិស័យចំនួន៤ រួមមាន វិស័

យវ៉ែ និងថាមពល វិស័យទេសចរណ៍ វិស័យវប្បធម៌ និងវិស័យឧស្សាហកម្មត្រូវបានរៀបចំសម្រាប់មន្ត្រីការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានចុះពិនិត្យ និងគាំទ្រដល់ការអនុវត្តមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុកនៅរដ្ឋបាលក្រុង ស្រុកចំនួន០៣ នៃខេត្តបាត់ដំបង ក្នុងឆ្នាំ២០២២
- បានរៀបចំកិច្ចប្រជុំចំនួន០២លើក ដើម្បីពិភាក្សា និងរកដំណោះស្រាយនូវបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ទាំង១៤ នៃខេត្តបាត់ដំបង ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធនានារួមមាន ក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ មន្ទីរអប់រំ យុវជន និងកីឡា មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មន្ទីរមុខងារសាធារណៈ រដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង ស្រុកទាំង១៤នៃខេត្តបាត់ដំបង ដោយមានការគាំទ្រពីកម្មវិធី DAR/GIZ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចុះសិក្សានៅរដ្ឋបាលក្រុង ស្រុកមួយចំនួន ដើម្បីស្វែងយល់និងគិតគូរអំពីការផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារទាំង៥៥ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- លេខាធិការដ្ឋាន គ.ជ.អ.ប. បានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការចុះទៅសិក្សា និងរៀបចំលិខិតបទដ្ឋានសម្រាប់ផ្ទេរទ្រព្យសម្បត្តិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមមុខងារដែលបានផ្ទេរ
- ក្រសួងបរិស្ថាន និងក្រសួងសាធារណការនិងដឹកជញ្ជូន បានចុះទៅផ្សព្វផ្សាយ និងណែនាំអនុវត្តនូវមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងកម្មវិធីការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា(ISD/GIZ) បានផ្តល់ការគាំទ្រ និងតាមដានការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក ដូចជាការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៣-២០២៥) ការរៀបចំ និងការអនុវត្តមុខងារក្នុងវិស័យអប់រំ សុខាភិបាល ការគ្រប់គ្រងសំរាម សំណល់រឹងនៅទីប្រជុំជន និងការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក និងឃុំ សង្កាត់ ឆ្នាំ២០២២
- លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងសិក្សា និងកំណត់នូវមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសរបស់រដ្ឋបាលក្រុង ស្រុក
- ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងរៀបចំ និងកែសម្រួលឡើងវិញនូវសេចក្តីណែនាំស្តីពីកិច្ចការរដ្ឋបាលក្រុង ស្រុក។

**២. ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាលឃុំ សង្កាត់**

ក្រសួង ស្ថាប័នពាក់ព័ន្ធបានផ្តល់ការគាំទ្រ និងពង្រឹងការអនុវត្តមុខងាររបស់រដ្ឋបាលឃុំ សង្កាត់តាមរយៈ៖

- ក្រសួងមហាផ្ទៃបានផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលឃុំ សង្កាត់ទាំងអស់ចំនួនប្រមាណ **៨៩២.១៣៣លានរៀល** (ស្មើនឹងប្រមាណជាង **២១៧លានដុល្លារ**) ក្នុងឆ្នាំ២០២២

- យន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលឃុំ សង្កាត់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តតាមរយៈ សេចក្តីណែនាំលេខ ០១៨ សនណ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ស្តីពីបែបបទ និងនីតិវិធី នៃការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ ដើម្បីលើក កម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវារដ្ឋបាលនៅថ្នាក់ឃុំ សង្កាត់
- ការរៀបចំឱ្យមានមន្ត្រីជំនួយការហិរញ្ញវត្ថុនៅថ្នាក់ឃុំ សង្កាត់ទូទាំងប្រទេស ដើម្បីជួយគាំទ្រ ដល់ការរៀបចំ ការគ្រប់គ្រង និងការប្រើប្រាស់ហិរញ្ញវត្ថុនៅថ្នាក់ឃុំ សង្កាត់ (ប្រកាសអន្តរ ក្រសួងលេខ០០២ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២ ស្តីពីការជ្រើសរើស ការ កំណត់តួនាទី និងភារកិច្ចរបស់ជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់)
- រដ្ឋបាលរាជធានី ខេត្តបានផ្តល់ការគាំទ្របច្ចេកទេសដល់រដ្ឋបាលឃុំ សង្កាត់ក្នុងការរៀបចំកម្មវិធី វិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលឃុំ សង្កាត់ និងការរៀបចំគម្រោងឃុំ សង្កាត់
- ការរៀបចំ និងដាក់ឱ្យអនុវត្តនូវកម្មវិធីជ័យលាភីពានរង្វាន់សេវាសង្គមសម្រាប់រដ្ឋបាលថ្នាក់ ក្រោមជាតិដោយក្រសួងមហាផ្ទៃ ដែលក្នុងនោះរដ្ឋបាលខេត្តចំនួន០២ (ខេត្តសៀមរាប និង ខេត្តកណ្តាល) រដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន០៣ (រដ្ឋបាលក្រុងតាខ្មៅ រដ្ឋបាលខណ្ឌមាន ជ័យ និងរដ្ឋបាលខណ្ឌកំបូល) និងរដ្ឋបាលឃុំ សង្កាត់មានចំនួន០៥ (សង្កាត់បឹងកេងកងទី១ ឃុំបាគង ឃុំបន្សាយត្រែង សង្កាត់បឹងកេងកងទី២ សង្កាត់ឡាបានសៀក) ទទួលបានពាន រង្វាន់ជើងឯកសេវាសង្គម និងរដ្ឋបាលរាជធានី ខេត្តចំនួន០៧ រដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន ៦១ រដ្ឋបាលឃុំ សង្កាត់ចំនួន៤១៧ ទទួលបានពានរង្វាន់ផ្កាយសេវាសង្គម
- សម្ព័ន្ធភាពជាតិ និងសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមខេត្តបានជួយគាំទ្រដល់ក្រុម ប្រឹក្សាឃុំ សង្កាត់តាមរយៈ (១). ការបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អំពីការក សាងផែនការនៅខេត្តកំពង់ចាម (២). ការបណ្តុះបណ្តាល គ.ក.ន.ក. អំពីការរៀបចំផែនការ សេវាសង្គមនៅខេត្តបាត់ដំបង (៣). ការបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាជាស្ត្រីអំពីច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះនៅខេត្តស្វាយរៀង (៤). ការបណ្តុះបណ្តាលបេក្ខនារីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ អំពីការនិយាយជាសាធារណៈ និងការកសាងផែនការឃោសនាបោះឆ្នោតនៅខេត្តកែប ខេត្ត កំពត ខេត្តកំពង់ឆ្នាំង ខេត្តសៀមរាប និងខេត្តព្រៃវែង និង(៥). ការកសាងសមត្ថភាពសមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់តាមរយៈការជួបពិគ្រោះយោបល់ និងការបង្ហាត់បង្ហាញដល់សមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់ផ្ទាល់។

### ៣. ការពង្រឹងលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

វគ្គបណ្តុះបណ្តាលដល់លេខាធិការដ្ឋានក្រុមប្រឹក្សា ត្រូវបានអនុវត្តរួមគ្នាជាមួយកម្មវិធីអភិវឌ្ឍសមត្ថ ភាពរបស់រដ្ឋបាលរាជធានី ខេត្ត ដែលក្នុងឆ្នាំ២០២២នេះ រដ្ឋបាលរាជធានី ខេត្ត បានសម្របសម្រួល និង រៀបចំវគ្គបណ្តុះបណ្តាលចំនួន៨០វគ្គ ដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិចំនួនប្រមាណ១.៧០០នាក់។

## ៤. ការពង្រឹងយន្តការផ្ដល់ព័ត៌មានជូនប្រជាពលរដ្ឋ

ការងារគណនេយ្យភាពសង្គមត្រូវបានពង្រីក និងដាក់ឱ្យអនុវត្តនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន **១៧៣** រដ្ឋបាលឃុំ សង្កាត់ចំនួន**១.៤១៣** សាលាបឋមសិក្សាចំនួន**៦.២៣១** និងមណ្ឌលសុខភាពចំនួន **១.១១០** ក្នុងរាជធានី ខេត្តទាំង**២៤** ក្នុងនោះធនាគារពិភពលោកបានផ្ដល់ការគាំទ្រការអនុវត្តនៅថ្នាក់ក្រុង ស្រុកចំនួន**៥៥** និងឃុំ សង្កាត់ចំនួន**៤៦៥** ក្នុងខេត្តចំនួន**១០** ក្រៅពីនេះជាការគាំទ្រដោយថវិការបស់រដ្ឋបាលរាជធានី ខេត្ត។

ទិន្នន័យព័ត៌មានស្ដីពីលទ្ធផលការងាររបស់អង្គភាពផ្ដល់សេវាទាំង៣ រួមមាន រដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាពត្រូវបានបញ្ចូលក្នុងប្រព័ន្ធទិន្នន័យបានចំនួន**៩៨%** និងបានផ្សព្វផ្សាយជូនប្រជាពលរដ្ឋតាមរយៈការបិទផ្សាយជាផ្ទាំងព័ត៌មាន (I4Cs) កម្មវិធីទូរស័ព្ទដៃ (Mobile App) ការចាក់ផ្សាយតាមប្រព័ន្ធឧឃោសនស័ព្ទ ការប្រជុំផ្សព្វផ្សាយ និងតាមប្រព័ន្ធទំនាក់ទំនងសង្គមផ្សេងៗទៀត។ ទន្ទឹមនឹងនេះ មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន**២.៥៣៤រូប (ស្ត្រីចំនួន៥១២រូប)** បានចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការអនុវត្តការងារគណនេយ្យភាពសង្គម។ សកម្មភាពជាអាទិភាពចំនួន**៤.៩១៦ (ស្មើនឹង៤៦%)** នៃផែនការសកម្មភាពរួមស្ដីពីការងារគណនេយ្យភាពសង្គម (ខែសីហា ឆ្នាំ២០២២ ដល់ខែកក្កដា ឆ្នាំ២០២៣) ត្រូវបានអនុវត្ត។ សកម្មភាពទាំងនេះត្រូវបានអនុវត្តក្នុងភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិលនានារួមមាន៖ អង្គការទស្សនពិភពលោក (World Vision) អង្គការអុកស្វាមកម្ពុជា (Oxfam Cambodia) អង្គការឃែរអន្តរជាតិប្រចាំកម្ពុជា (Care Cambodia) និងអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360)។ ប្រជាពលរដ្ឋប្រមាណជាង**៥៩២.០០០នាក់ (ស្ត្រីចំនួន៣៤២.០០០នាក់)** បានចូលរួមយ៉ាងសកម្មក្នុងកិច្ចដំណើរការអនុវត្តការងារគណនេយ្យភាពសង្គម តាមរយៈការចូលរួមផ្សព្វផ្សាយអំពីកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ កិច្ចប្រជុំដាក់ពិន្ទុសហគមន៍ និងកិច្ចប្រជុំរួម ដើម្បីកំណត់អាទិភាពតាមវិស័យនីមួយៗ។

## ៥. ការពង្រឹងយន្តការសម្រាប់ទទួលការដាក់សំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ

សកម្មភាពនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ការរៀបចំការបណ្ដុះបណ្ដាល និងពង្រឹងសមត្ថភាពដល់មន្ត្រីការិយាល័យប្រជាពលរដ្ឋចំនួន០៣លើក អំពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ការិយាល័យប្រជាពលរដ្ឋ
- បានដាក់ចេញសៀវភៅណែនាំស្ដីពីការស៊ើបអង្កេតបណ្ដឹងរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងបានរៀបចំវគ្គបណ្ដុះបណ្ដាលគ្រូបង្គោលរាជធានី ខេត្តស្ដីពីបច្ចេកទេសស៊ើបអង្កេតបណ្ដឹងរបស់ការិយាល័យប្រជាពលរដ្ឋ។
- ការរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងនៅរដ្ឋបាលរាជធានី ខេត្តចំនួន០៣ (រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តកំពង់ចាម) រដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន០៨ និងរដ្ឋបាលឃុំ សង្កាត់ចំនួន៣០ នូវកម្មវិធីតាមទូរស័ព្ទដៃ (មតិយើង) សម្រាប់ប្រជាពលរដ្ឋផ្ដល់ព័ត៌មាន មតិយោបល់ និងដាក់ពាក្យបណ្ដឹងនានាពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរដ្ឋបាល និងការផ្ដល់សេវាសាធារណៈ ដែលជាសមត្ថកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋ

- ការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រាជធានី ខេត្តបានទទួលបណ្តឹង និងព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋសរុបចំនួន**៦២១ករណី** ក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចមានចំនួន**៣៩២ករណី** (បញ្ចប់ការដោះស្រាយចំនួន**៣៣២ករណី** កំពុងដោះស្រាយចំនួន**៦០ករណី**) បណ្តឹងក្រៅសមត្ថកិច្ចចំនួន**១០៧ករណី** និងព័ត៌មានផ្សេងៗចំនួន**១២២ករណី** (ការសរសើរចំនួន**២០ករណី** សំណូមពរចំនួន**៣៤ករណី** និងការសាកសួរព័ត៌មានចំនួន**៦៨ករណី**)
- ការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក ខណ្ឌបានទទួលបណ្តឹង និងព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋបានសរុបចំនួន**៦.៣៨៥ករណី** ក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចមានចំនួន**១៤០ករណី** (បញ្ចប់ការដោះស្រាយចំនួន**១៣៣ករណី** កំពុងដោះស្រាយចំនួន**០៧ករណី**) បណ្តឹងក្រៅសមត្ថកិច្ចចំនួន**៦៦ករណី** ព័ត៌មានផ្សេងៗសរុបចំនួន**៦.១៧៩ករណី** (ការសរសើរមាន**១៤៤ករណី** សំណូមពរមានចំនួន**៤៧៥ករណី** ការសាកសួរព័ត៌មានចំនួន**៥.៥៦០ករណី**)
- ក្រុមការងារទទួល និងដោះស្រាយបណ្តឹងនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបានបង្កើតនៅខែមីនា ឆ្នាំ២០២២ ដើម្បីទទួល និងដោះស្រាយបណ្តឹងនានាពាក់ព័ន្ធនឹងការអនុវត្តគម្រោងកម្មវិធីគាំទ្រដោយដៃគូអភិវឌ្ឍន៍ក្នុងក្របខ័ណ្ឌកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

**៦. ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងកិច្ចដំណើរការចូលរួមរបស់ប្រជាពលរដ្ឋ**

សកម្មភាពនេះ សម្រេចបានលទ្ធផលដូចខាងក្រោម ៖

- អង្គការសង្គមស៊ីវិលចំនួន៣២ បានចូលរួមអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ (Demand Side) ដើម្បីពង្រឹងសិទ្ធិអំណាច និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចដំណើរការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន
- ក្រសួងមហាផ្ទៃបានសហការជាមួយអង្គការតម្លាភាពអន្តរជាតិកម្ពុជា (TI) ក្នុងការពង្រឹងតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់ការិយាល័យប្រជាពលរដ្ឋដែលជាយន្តការទទួល និងដោះស្រាយបណ្តឹងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- រដ្ឋបាលថ្នាក់ក្រោមជាតិបានបង្កលក្ខណៈ និងលើកទឹកចិត្តដល់អង្គការសង្គមស៊ីវិលពាក់ព័ន្ធនានាក្នុងការចូលរួមក្នុងវេទិកាសាធារណៈនានា ដែលរៀបចំឡើងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៧. ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ប្រព័ន្ធគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធឌីជីថលត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាជំហានៗក្នុងនោះរួមមាន៖

- ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS)នៅថ្នាក់រាជធានី ខេត្តទាំង២៥
- ប្រព័ន្ធពិនិត្យតាមដានការអនុវត្តសកម្មភាពការងារគណនេយ្យភាពសង្គម (ISAF, M&E Database System)
- ប្រព័ន្ធទូទាត់វិក្កយបត្រ (Payment Hub) នៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត។

**៤. ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវបានអនុវត្ត**

ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋត្រូវបានរៀបចំឡើងតាមរយៈ៖

- យន្តការគណនេយ្យភាពសង្គម លេខាធិការដ្ឋាន គ.ជ.អ.ប.បានបង្កើតឡើងកម្មវិធីតាមទូរស័ព្ទដៃ (Mobile App) ដើម្បីបង្កលក្ខណៈងាយស្រួលឱ្យប្រជាពលរដ្ឋអាចទទួលបានព័ត៌មានអំពីសេវាសាធារណៈនានាពាក់ព័ន្ធនឹងរដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាព
- ក្រសួងមហាផ្ទៃ បានរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងនៅរដ្ឋបាលរាជធានី ខេត្តចំនួន០៣ (រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តកំពង់ចាម) រដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន០៨ និងរដ្ឋបាលឃុំ សង្កាត់ចំនួន៣០ នូវកម្មវិធីទូរស័ព្ទដៃ (មតិយើង) សម្រាប់ប្រជាពលរដ្ឋផ្តល់ព័ត៌មាន មតិយោបល់ និងដាក់ពាក្យបណ្តឹងនានាពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរដ្ឋបាល និងការផ្តល់សេវាសាធារណៈ
- រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំគេហទំព័រ បណ្តាញទំនាក់ទំនងសង្គម ក្រុមតេឡេក្រាម ដើម្បីផ្សព្វផ្សាយព័ត៌មាន និងទទួលមតិយោបល់ត្រឡប់ពីប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**៥. ការពង្រឹងយន្តការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងសិក្សារៀបចំនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងត្រៀមធ្វើការបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងឆ្នាំ ២០២៣។

## គ. សមាសភាគទី៣ ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

សមាសភាគទី៣នេះ រួមមានសកម្មភាពជាអាទិភាពចំនួន**២២** ក្នុងនោះមានសកម្មភាពអាទិភាពចំនួន**២០** ត្រូវបានអនុវត្តដោយមានវឌ្ឍនភាពដូចខាងក្រោម៖

**១. ការពិនិត្យ និងកែសម្រួលអង្គមន្ត្រីរាជការ**

សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីអង្គរដ្ឋបាលត្រូវបានរៀបចំឡើងក្នុងដំណាក់កាលនៃការអនុវត្តផែនការអនុវត្តរយៈពេល៣ឆ្នាំ ដំណាក់កាលទី៣នៃកជទី១។ ក្នុងឆ្នាំ២០២២មកនេះ សេចក្តីព្រាងព្រះរាជក្រឹត្យនេះក៏ត្រូវបានបន្តពិនិត្យ និងកែសម្រួលដោយក្រសួងមុខងារសាធារណៈ។

**២. ការរៀបចំការពិពណ៌នាមុខតំណែងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ**

សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងឯកសារពិពណ៌នាមុខតំណែង (មុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈ) សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងនោះចំនួនមុខតំណែងត្រូវបានកំណត់ឡើងដូចខាងក្រោម៖

- សម្រាប់រដ្ឋបាលស្រុកមានចំនួន**៨៥មុខតំណែង** (មុខតំណែងគ្រប់គ្រងចំនួន**៣១** និងមុខតំណែងវិជ្ជាជីវៈចំនួន**៥៤**)
- សម្រាប់រដ្ឋបាលក្រុងមានចំនួន**៨៦មុខតំណែង** (មុខតំណែងគ្រប់គ្រងចំនួន**៣១** និងមុខតំណែងវិជ្ជាជីវៈចំនួន**៥៥**)
- សម្រាប់រដ្ឋបាលខណ្ឌមានចំនួន**៨១មុខតំណែង** (មុខតំណែងគ្រប់គ្រងចំនួន**២៧** និងមុខតំណែងវិជ្ជាជីវៈចំនួន**៥៤**)។

**៣. ការពង្រឹងការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗបានរៀបចំ និងអនុវត្តនូវលក្ខខណ្ឌការងារសម្រាប់បុគ្គលិកម្នាក់ៗប្រចាំឆ្នាំតាមគោលការណ៍ និងនីតិវិធីជាធរមាន។ លក្ខខណ្ឌការងារទាំងនេះនឹងត្រូវពិនិត្យកែសម្រួលឡើងវិញដោយផ្អែកទៅលើការពិពណ៌នាមុខតំណែង ដែលនឹងត្រូវដាក់ចេញដូចមានកំណត់ក្នុងសកម្មភាពទី២នៃសមាសភាគនេះ។

**៤. ការពង្រឹងការគ្រប់គ្រងវត្តមានបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗបានពង្រឹងការគ្រប់គ្រងបុគ្គលិករបស់ខ្លួន តាមរយៈការត្រួតពិនិត្យការចុះបញ្ជីវត្តមាននៅតាមអង្គភាពនីមួយៗ។

**៥. ការរៀបចំក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

រដ្ឋបាលថ្នាក់ក្រោមជាតិបានបន្តពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គ្រូបង្រៀន និងគ្រូពេទ្យដែលបានផ្ទេរមកឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ចំពោះក្រមសីលធម៌សម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀតនឹងត្រូវរៀបចំ និងដាក់ឱ្យអនុវត្តនៅឆ្នាំ២០២៣។

**៦. ការលើកកម្ពស់ការតាមដាន និងការវាយតម្លៃលើការបំពេញការងារ**

សេចក្តីព្រាងអនុក្រឹត្យ និងសេចក្តីណែនាំស្តីពីការវាយតម្លៃផ្អែកលើសមិទ្ធកម្មត្រូវបាន និងកំពុងរៀបចំដោយក្រសួងមុខងារសាធារណៈ ដើម្បីជាមូលដ្ឋានសម្រាប់ការវាយតម្លៃទៅលើការបំពេញការងាររបស់បុគ្គលិកប្រចាំឆ្នាំ។

**៧. ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ**

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មាន ទិន្នន័យបុគ្គលិក ការជ្រើសរើស ការត្រួតពិនិត្យវាយតម្លៃ ការបំពេញការងារ សម្រាប់ដំឡើងថ្នាក់ ឋានន្តរសក្តិ ការតែងតាំងមុខតំណែង ការដាក់ពិន័យ ការចូលនិវត្ត និងការគ្រប់គ្រងផ្សេងៗទៀតត្រូវបាននិងកំពុងសិក្សា និងរៀបចំដោយក្រសួងមុខងារសាធារណៈ។

**៨. ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

រដ្ឋបាលរាជធានី ខេត្តទាំងអស់បានរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់ខ្លួនតាមគោលការណ៍ បែបបទ និងនីតិវិធីជាធរមាន។

## ៩. ការលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ កំពុងដំណើរការពិនិត្យ និងកែសម្រួលក្រោមការដឹកសម្របសម្រួលរៀបចំដោយក្រសួងកិច្ចការនារី និង លេខាធិការដ្ឋាន គ.ជ.អ.ប.។

គិតមកដល់ចុងឆ្នាំ២០២២នេះចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រេចបានដូចខាងក្រោម៖

- មុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្តចំនួន**៧៦នាក់** ស្មើនឹង**១២.១២%**
- មុខតំណែងគ្រប់គ្រងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន**៧៦៦នាក់** ស្មើនឹង**១៩.៥២%**។




- មុខតំណែងគ្រប់គ្រងនៅរដ្ឋបាលឃុំ សង្កាត់ រួមមានមេឃុំចៅសង្កាត់មានចំនួន**១៧៣នាក់** ស្មើនឹង**១០.៤៧%** ជំទប់ទី១មានចំនួន**៣១៩** ស្មើនឹង**៩.៣១%** ជំទប់ទី២មានចំនួន**១៨៩** ស្មើនឹង**១.៤៤%**។




## ១០. ការពិនិត្យ និងការកែសម្រួលនូវឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

វិធីសាស្ត្រ និងឧបករណ៍សម្រាប់ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិកំពុងដំណើរការពិនិត្យ និងកែសម្រួលដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន។

## ១១. ការពង្រឹងសមត្ថភាពដល់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តអំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព

អង្គភាពអភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត ទទួលបានការណែនាំពីសាលាជាតិរដ្ឋបាលមូលដ្ឋានអំពីការរៀបចំវាយតម្លៃលើតម្រូវការអភិវឌ្ឍសមត្ថភាពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**១២. ការរៀបចំការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

រដ្ឋបាលរាជធានី ខេត្តបានរៀបចំការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពសម្រាប់បុគ្គលិក ដែលបំពេញការងារនៅក្នុងរដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជាទៀងទាត់ប្រចាំឆ្នាំ។

**១៣. ការរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមតម្រូវការអភិវឌ្ឍសមត្ថភាព**

រដ្ឋបាលរាជធានី ខេត្តទាំងអស់កំពុងដំណើរការរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំ២០២៣ របស់ខ្លួន ដោយរួមបញ្ចូលនូវសកម្មភាពអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**១៤. ការជ្រើសរើស និងការពង្រឹងសមត្ថភាពបុគ្គលិកនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន**

ក្រសួងមហាផ្ទៃបានចាត់តាំង និងរៀបចំបុគ្គលិកបំពេញការងារនៅតាមនាយកដ្ឋានទាំង០៤នៃសាលាជាតិរដ្ឋបាលមូលដ្ឋានដែលមានចំនួន**៨២នាក់ ស្ត្រីចំនួន២៩នាក់** និងត្រៀមផ្តល់ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីទាំងនោះ។

**១៥. កិច្ចសហការជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ និងឯកជន និងស្ថាប័នពាក់ព័ន្ធនានាដើម្បីរៀបចំ និងអនុវត្តការបណ្តុះបណ្តាល**

សាលាជាតិរដ្ឋបាលមូលដ្ឋានបានសហការជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលមួយចំនួនដូចជា សាលាភូមិន្ទរដ្ឋបាល វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកិច្ចការនារី លេខាធិការដ្ឋាន គ.ជ.អ.ប. ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលមួយចំនួនដូចជា GIZ, UNDP, KOICA, ADB, UNPOG, CDRI, WaterSHED, TI Cambodia ក្នុងការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

**១៦. ការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមគោលដៅផ្សេងៗ៖**

សាលាជាតិរដ្ឋបាលមូលដ្ឋានបានសម្របសម្រួល និងរៀបចំវគ្គបណ្តុះបណ្តាលចំនួន**២៧វគ្គ**ដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន**៧៦២នាក់ ស្ត្រីចំនួន២០៣នាក់** ដូចជា៖

- វគ្គវិក្រឹត្យការជំនាញគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់
- វគ្គអន្តរាគមន៍អភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- វគ្គវិក្រឹត្យការមូលដ្ឋាន
- វគ្គលេខាធិការរដ្ឋបាល
- វគ្គភាពជាអ្នកដឹកនាំជាស្ត្រីជំនាន់ទី០៣

- វគ្គមុខងារគ្រប់គ្រងសុខាភិបាល
- វគ្គកម្មវិធីអប់រំភាពជាអ្នកដឹកនាំ។

ទន្ទឹមនេះ រដ្ឋបាលរាជធានី ខេត្តបានសម្របសម្រួល និងរៀបចំវគ្គបណ្តុះបណ្តាលចំនួន**៨០វគ្គ**ដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិចំនួនប្រមាណ**១.៧០០នាក់** ដោយផ្តោតលើប្រធានបទសំខាន់ៗមានដូចជា៖

- ការងារគណនេយ្យភាពសង្គម
- ការគ្រប់គ្រងធនធានមនុស្ស
- ការកសាងផែនការ និងការរៀបចំថវិកា
- សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម
- ភាពជាអ្នកដឹកនាំ
- ការរៀបចំ និងការអនុវត្តផែនការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈនៃបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- កិច្ចដំណើរការ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ។

**១៧. ការជ្រើសរើសស្ថាប័នអភិវឌ្ឍសមត្ថភាព ស្ថាប័នជំនាញវិជ្ជាជីវៈ និងអ្នកជំនាញវិជ្ជាជីវៈ ដើម្បីចូលរួមរៀបចំកម្មវិធីសិក្សា និងឯកសារសម្ភារៈបណ្តុះបណ្តាល**

សាលាជាតិរដ្ឋបាលមូលដ្ឋានបានសហការជាមួយស្ថាប័នអភិវឌ្ឍសមត្ថភាពមួយចំនួនក្នុងការរៀបចំកម្មវិធីសិក្សា និងឯកសារបណ្តុះបណ្តាលសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជា សាលាភូមិន្ទរដ្ឋបាល វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកិច្ចការនារី។

**១៨. ការរៀបចំ ពិនិត្យកែសម្រួល និងធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលនានា**

សាលាជាតិរដ្ឋបាលមូលដ្ឋាន កំពុងដំណើរការរៀបចំសេចក្តីណែនាំស្តីពីការរៀបចំកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាល។

**១៩. ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពលើឯកសារ សម្ភារៈបណ្តុះបណ្តាលសម្រាប់កម្មវិធីសិក្សានានា**

សាលាជាតិរដ្ឋបាលមូលដ្ឋានកំពុងដំណើរការរៀបចំសេចក្តីណែនាំស្តីពីការរៀបចំឯកសារ សម្ភារៈសម្រាប់វគ្គបណ្តុះបណ្តាល។

**២០. ការជ្រើសរើស និងការអនុម័តវិធីសាស្ត្រផ្សេងៗសម្រាប់វគ្គបណ្តុះបណ្តាលនានា**

សាលាជាតិរដ្ឋបាលមូលដ្ឋានកំពុងដំណើរការរៀបចំសេចក្តីណែនាំស្តីពីការរៀបចំវិធីសាស្ត្រផ្សេងៗសម្រាប់វគ្គបណ្តុះបណ្តាលបណ្តាល។



Vda

## ឃ. សមាសភាគទី៤៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

សមាសភាគទី៤នេះ រួមមានសកម្មភាពជាអាទិភាពចំនួន២០ ក្នុងនោះមានសកម្មភាពអាទិភាពចំនួន១៦ត្រូវបានអនុវត្ត ដោយមានវឌ្ឍនភាពដូចខាងក្រោម៖

**១. ការបន្សុីគ្នារវាងកិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

រដ្ឋបាលរាជធានី ខេត្តទាំង២៥បានរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដោយផ្អែកតាមបញ្ជីគម្រោងជាអាទិភាពនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ស្របតាមគោលការណ៍ណែនាំជាធរមាន។

**២. ការពិនិត្យ និងកែសម្រួលឡើងវិញប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ក្រសួងផែនការកំពុងដំណើរការពិនិត្យមើលឡើងវិញ និងសិក្សាអំពីលិខិតបទដ្ឋាន និងសេចក្តីណែនាំនានាដែលពាក់ព័ន្ធនឹងការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**៣. ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

កម្រងបញ្ជីសំណួរនៃទិន្នន័យមូលដ្ឋានថ្នាក់ក្រោមជាតិកំពុងពិនិត្យ និងកែសម្រួលដោយបញ្ចូលនូវកម្រងបញ្ជីសំណួរដែលពាក់ព័ន្ធនឹងការងារប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ ជំងឺឆ្លងរាតត្បាត កាចសាហាវ និងសេវាសង្គមនានា។ល។

**៤. ការបន្តការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៥)**

រដ្ឋបាលរាជធានី ខេត្តទាំង២៥កំពុងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុដែលបានរៀបចំ និងដាក់ឱ្យអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**៥. ការធ្វើវិមជ្ឈការ និងការពង្រឹងការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងដំណើរការពិនិត្យមើលឡើងវិញនូវច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋាននានា ដើម្បីផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងពង្រឹងការអនុវត្តកិច្ចលទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៦. ការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលសារពើពន្ធដែលមានស្រាប់**

រដ្ឋបាលរាជធានី ខេត្តផ្អែកតាមគោលការណ៍ណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានពង្រឹងការប្រមូលចំណូលសារពើពន្ធរបស់ខ្លួនចំនួន**០៩មុខ** រួមមាន ពន្ធលើឈ្នួលផ្ទះនិងដី ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានយន្តគ្រប់ប្រភេទ ពន្ធប៉ាតង់ ពន្ធប្រថាប់ត្រា ពន្ធលើអចលនទ្រព្យ អាករសម្រាប់បំភ្លឺសាធារណៈ អាករលើការស្នាក់នៅ ពន្ធតែមប្រិ៍សារពើពន្ធ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដែលសម្រេចបានចំណូលក្នុងឆ្នាំ២០២២ ចំនួនប្រមាណ**១.៥៦៣លានរៀល** ស្មើនឹងប្រមាណជាង**៣៨៦លានដុល្លារ**។

**៧. ការបែងចែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងដំណើរការពិនិត្យមើលឡើងវិញនូវលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការបែងចែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់។ ក្នុងឆ្នាំ២០២២នេះ រដ្ឋបាលរាជធានី ខេត្តបានបែងចែកចំណូលសារពើពន្ធពីរដ្ឋបាលរបស់ខ្លួនទៅឱ្យរដ្ឋបាលក្រុង ស្រុកចំនួន៤% និងទៅឱ្យរដ្ឋបាលឃុំ សង្កាត់ចំនួន៥%។

**៨. ការលើកកម្ពស់ការប្រមូល និងការគ្រប់គ្រងកម្រៃ ឬឈ្នួលសេវា**

ពាក់ព័ន្ធនឹងសកម្មភាពនេះ ក្នុងឆ្នាំ២០២២ សម្រេចបានលទ្ធផលដូចខាងក្រោម៖

- ការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់វិក្កយបត្រ (Payment Hub) នៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តទាំង២៥
- អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្តទាំង២៥បានផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋសរុបចំនួន**៦៩៥.២០៥សេវា**លើ១៤វិស័យ និងទទួលបានចំណូលសរុបចំនួន**១១២.៨៤៩.៩៧១.៧៨៧រៀល** ស្មើនឹង**២៨.២១២.៤៩២ដុល្លារ**
- ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌបានផ្តល់សេវារដ្ឋបាលសរុបចំនួន**១.៥៦១.៧០៤សេវា** និងទទួលបានចំណូលសរុបចំនួន**១១.០០៩.០៦៦.៩៦០រៀល** ស្មើនឹង**២.៧៥២.២៦៦ដុល្លារ**។

**៩. ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

សម្រេចបានលទ្ធផលដូចខាងក្រោម៖

- រដ្ឋបាលរាជធានី ខេត្តទាំង២៥បានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ដែលបានរៀបចំ និងដាក់ឱ្យអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងឆ្នាំ២០២០
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្សព្វផ្សាយ និងណែនាំអនុវត្តនូវវិធានការ និងនីតិវិធីនៃការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**១០. ការបង្កើនការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលក្រុង ស្រុក**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងដំណើរការសិក្សាពិនិត្យមើលឡើងវិញនូវលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធនឹងអត្រាចូលរួមពីធនធានថវិកាជាតិក្នុងមូលនិធិក្រុង ស្រុក។

**១១. ការលើកកម្ពស់សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌសម្រាប់គម្រោងសេវាកម្មនានា**

ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប. កំពុងដំណើរការរៀបចំលិខិតបទដ្ឋានស្តីពីការប្រើប្រាស់មូលនិធិក្រុង ស្រុក និងឃុំ សង្កាត់សម្រាប់គម្រោង/សកម្មភាពសេវាសង្គម។ ទន្ទឹមនេះដែរ រដ្ឋបាលឃុំ សង្កាត់បានពង្រឹង និងលើកកម្ពស់ការអនុវត្តមុខងារសេវាសង្គមស្របតាមសៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់ ឆ្នាំ២០១៨ និងរដ្ឋបាលរាជធានី ខេត្ត

និងក្រុង ស្រុក ខណ្ឌ បានពង្រឹង និងលើកកម្ពស់ការអនុវត្តមុខងារសេវាសង្គមស្របតាមសៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ឆ្នាំ២០២១។

**១២. ការលើកកម្ពស់ការអនុវត្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌក្នុងក្របខ័ណ្ឌដែលមានបច្ចុប្បន្នភាពទាំងរៀបចំ និងកែលម្អក្របខ័ណ្ឌផ្តល់ហិរញ្ញប្បទានដល់មុខងារជាកាតព្វកិច្ចឱ្យកាន់តែប្រសើរឡើង**

សម្រេចបានលទ្ធផលដូចខាងក្រោម៖

- ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារក្នុងវិស័យអប់រំប្រមាណជាង**៣៣លានដុល្លារ**សម្រាប់ឆ្នាំ២០២២នេះ ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ នៃខេត្តបាត់ដំបង
- ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារក្នុងវិស័យសុខាភិបាលប្រមាណ**១៧០លានដុល្លារ**សម្រាប់ឆ្នាំ២០២២នេះ ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្តទាំង២៥
- ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងនៅទីប្រជុំជនប្រមាណ**២លានដុល្លារ**សម្រាប់ឆ្នាំ២០២២ ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុងទាំង២៧
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចុះសិក្សា និងពិនិត្យមើលអំពីលទ្ធភាពនៃការផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារទាំង៥៥ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**១៣. ការលើកកម្ពស់ក្របខ័ណ្ឌសម្រាប់គ្រប់គ្រងធនធានរបស់ដៃគូអភិវឌ្ឍន៍ដែលផ្តល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ**

លេខាធិការដ្ឋាន គ.ជ.អ.ប.បានសម្របសម្រួល និងដាក់បញ្ចូលនូវសកម្មភាពនានារបស់គម្រោង/កម្មវិធីគាំទ្រដោយដៃគូអភិវឌ្ឍន៍ទៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. មានដូចជាគម្រោង ISAF គម្រោងសាងសង់សាលាជាតិរដ្ឋបាលមូលដ្ឋាន គម្រោងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) គម្រោងលើកកម្ពស់អាហារូបត្ថម្ភនៅកម្ពុជា (CNP) គម្រោងនានាពាក់ព័ន្ធនឹងភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុមានចំនួន០៦គម្រោង និងគម្រោងធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាជូនប្រជាពលរដ្ឋនៅកម្ពុជា (ISD/GIZ)។

**១៤. ការពង្រឹងក្របខ័ណ្ឌគ្រប់គ្រងការវិនិយោគសាធារណៈដែលប្រើប្រាស់ថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ក្នុងឆ្នាំ២០២២ រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈ រួមមានរដ្ឋបាលរាជធានី ខេត្តមានចំនួន**៣៧០គម្រោង** រដ្ឋបាលក្រុង ស្រុកមានចំនួន**៤៥៥គម្រោង** និងរដ្ឋបាលឃុំសង្កាត់មានចំនួន**១.៩៣៥គម្រោង**។

**១៥. ការសិក្សា និងរៀបចំនូវក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន**

ក្នុងឆ្នាំ២០២២នេះ គម្រោងសាកល្បងក្នុងភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនលើការគ្រប់គ្រង និងផ្តល់សេវាទឹកស្អាតនៅឃុំបាសាក់ ស្រុករុក្ខគិរី ខេត្តបាត់ដំបង ត្រូវបានរៀបចំ និងអនុវត្ត ដើម្បីធ្វើជាមូលដ្ឋានក្នុងការបង្កើតក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន។

**១៦. ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង និងការរៀបចំនីតិវិធីសវនកម្មផ្ទៃក្នុងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ**

សេចក្តីព្រាងនីតិវិធីសវនកម្ម ឬត្រួតពិនិត្យផ្ទៃក្នុងសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបាន រៀបចំឡើងដោយលេខាធិការដ្ឋាន គ.ជ.អ.ប.។ សេចក្តីព្រាងនេះនឹងត្រូវអនុម័ត និងដាក់ឱ្យអនុវត្តក្នុង ឆ្នាំ២០២៣។ ចំពោះការសិក្សាក្នុងការបង្កើតអង្គភាពសវនកម្មភាពផ្ទៃក្នុងសម្រាប់រដ្ឋបាលរាជធានី ខេត្ត នឹងត្រូវរៀបចំឡើងក្នុងឆ្នាំ២០២៣ផងដែរ។

## ង. សមាសភាគទី៥÷ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន

សមាសភាគទី៥នេះ រួមមានសកម្មភាពជាអាទិភាពចំនួន១០ ហើយត្រូវបានអនុវត្តទាំង១០ សកម្មភាព ដោយមានវឌ្ឍនភាពដូចខាងក្រោម៖

**១. ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច**

សម្រេចបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

- ក្រសួង ស្ថាប័នចំនួន១៤ក្នុងចំណោមក្រសួង ស្ថាប័នសរុបចំនួន២០ បានរៀបចំ និងដាក់ឱ្យ អនុវត្តនូវសេចក្តីណែនាំបច្ចេកទេសសម្រាប់ការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជ ធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ព្រមទាំងបានរៀបចំវគ្គបណ្តុះបណ្តាលអំពីសេចក្តីណែនាំ ទាំងនេះ
- មេរៀន បទពិសោធន៍ស្តីពីការអនុវត្តមុខងារជាកាតព្វកិច្ចកំពុងដំណើរការពិនិត្យ និងប្រមូល ទិន្នន័យ និងព័ត៌មានពាក់ព័ន្ធនានា ដើម្បីរៀបចំចងក្រងជាឯកសារសម្រាប់ផ្សព្វផ្សាយដល់ រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសមុខងារក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ។

**២. ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើស**

បាននិងកំពុងសិក្សា និងរៀបចំកែសម្រួលនីតិវិធីនៃការអនុវត្តមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ ក្រោមជាតិ ដើម្បីពង្រឹង និងលើកកម្ពស់ការអនុវត្តមុខងារជាអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនី មួយៗ។ ទន្ទឹមនោះ លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងរៀបចំចងក្រងមេរៀនបទពិសោធន៍ស្តីពីការ អនុវត្តមុខងារជាជម្រើស ដើម្បីផ្សព្វផ្សាយ និងចែករំលែកដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**៣. ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមអង្គភាពច្រកចេញចូលតែមួយ នៃរដ្ឋបាលរាជធានី ខេត្ត**

បានពិនិត្យ និងកែសម្រួលបែបបទ និងនីតិវិធីនៃការផ្តល់សេវានៅអង្គភាពច្រកចេញចូលតែមួយ ពាក់ព័ន្ធនឹងការផ្តល់សេវាក្នុងវិស័យកសិកម្ម និងវិស័យសាធារណការ និងដឹកជញ្ជូន។

**៤. ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូល តែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់**

សម្រេចបានលទ្ធផលដូចខាងក្រោម៖

- បានរៀបចំកែសម្រួលរចនាសម្ព័ន្ធនៃការិយាល័យច្រកចេញចូលតែមួយនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌតាមរយៈប្រកាសលេខ៧៥១ ប្រ.ក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១



Vdg

- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីរបៀបប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- បានដាក់ចេញសេចក្តីណែនាំលេខ០១៨ សណន ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ស្តីពីបែបបទ និងនីតិវិធីផ្តល់សេវារដ្ឋបាល តាមរយៈយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ និងបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីសេចក្តីណែនាំនេះដល់រដ្ឋបាលឃុំ សង្កាត់នៅខេត្តបាត់ដំបង។

**៥. ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ**

សម្រេចបានលទ្ធផលដូចខាងក្រោម៖

- បាននិងកំពុងពង្រីកការអនុវត្ត និងការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធស្វ័យប្រវត្តិកម្មតាមអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តលើសេវាចុះបញ្ជីយានយន្ត និងការប្រឡងយកបណ្ណបើកបរយានយន្ត និងប្តូរ ពន្យារទុតិយតា តតិយតា (លើកលែងជនបរទេស)
- បាននិងកំពុងពង្រីកការអនុវត្ត និងការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធស្វ័យប្រវត្តិកម្មតាមការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌលើសេវាកម្មម៉ូតូ និងសេវាកម្មត្រីចក្រយានយន្ត ឬរ៉ឺមក
- បាននិងកំពុងសិក្សាអំពីលទ្ធភាពនៃការរៀបចំ និងដាក់ឱ្យអនុវត្តនូវសេវាមួយចំនួនតាមប្រព័ន្ធអនឡាញ
- បាននិងកំពុងពិនិត្យ និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទូទាត់វិក្កយបត្រ (Payment Hub) ដែលបានដាក់ឱ្យអនុវត្តនៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត
- បានរៀបចំវគ្គបំប៉នស្តីពីរបៀបប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**៦. ការរៀបចំបញ្ជីមូលដ្ឋានអាជីវកម្ម ឬសហគ្រាសនៅតាមមូលដ្ឋាន**

រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌបានរៀបចំ និងធ្វើបច្ចុប្បន្នភាពបញ្ជីមូលដ្ឋានអាជីវកម្ម ឬសហគ្រាសនានាដែលប្រកបអាជីវកម្មនៅក្នុងរាជធានី ខេត្ត។

**៧. ការបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា**

លេខាធិការដ្ឋាន គ.ជ.អ.ប. បានចុះសិក្សា និងវាយតម្លៃស្តីពីការអនុវត្តគោលនយោបាយសុវត្ថិភាពដីធ្លី បរិស្ថាន និងជនជាតិដើមភាគតិចរួមបញ្ចូលទាំងការសិក្សាអំពីតួនាទី ភារកិច្ចរបស់យន្តការនានាដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា ដើម្បីជាមូលដ្ឋានដល់ការរៀបចំបង្កើតនូវគណៈកម្មាធិការជាក់លាក់មួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៨. ការកំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវាដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ**

លេខាធិការដ្ឋាន គ.ជ.អ.ប.កំពុងពិនិត្យមើលឡើងវិញអំពីឯកសារបច្ចេកទេសនានាដែលពាក់ព័ន្ធនឹងបទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវា និងការវិនិយោគដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

ជាមួយគ្នានេះ លេខាធិការដ្ឋាន គ.ជ.អ.ប. បានសម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធរៀបចំឯកសារទស្សនទានចំនួន០៧ ពាក់ព័ន្ធនឹងការបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់ដៃគូអភិវឌ្ឍន៍ ដូចជា UNDP, GGGI, UNCDF និង IFAD ត្រូវបានសម្របសម្រួលរៀបចំ និងដាក់ជូនមូលនិធិអាកាសធាតុបៃតង(GCF) ដើម្បីស្នើសុំការគាំទ្រមូលនិធិ។

**៩. ការពង្រឹងការប្រើប្រាស់ទិន្នន័យអំពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា**

រដ្ឋបាលឃុំ សង្កាត់គោលដៅនៃគម្រោង "សន្តិសុខស្បៀង និងការគាំទ្រការស្តារឡើងវិញរបស់សហគមន៍មូលដ្ឋាន ដែលរងផលប៉ះពាល់ដោយសារទឹកជំនន់នៅប្រទេសកម្ពុជា (SRELFOOD2) គម្រោង "លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាថាមពលពន្លឺព្រះអាទិត្យសម្រាប់វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទនៅប្រទេសកម្ពុជា (STARD) និងគម្រោងធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា (CCCA) បានប្រើប្រាស់ទិន្នន័យការប្រែប្រួលអាកាសធាតុក្នុងការរៀបចំផែនការសកម្មភាពរបស់ខ្លួន។

**១០. ការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា**

លេខាធិការដ្ឋាន គ.ជ.អ.ប. បានសម្របសម្រួល និងកៀរគរធនធានពីគម្រោង/កម្មវិធីដាច់ដោយឡែកចំនួន០៦ ដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ដែលមានថវិកាសរុបចំនួនប្រមាណ**១៣.៦៨១លានរៀល** ស្មើនឹងប្រមាណ**៣,៣៧លានដុល្លារ** សម្រាប់វិនិយោគលើការលើកកម្ពស់ភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងការការពារទប់ស្កាត់ជំងឺឆ្លងកាចសាហាវនានា។

ក្រៅពីសមិទ្ធផលនៃសមាសភាគទាំង៥ដូចបានរៀបរាប់ខាងលើ ការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២២ ក៏ទទួលបានការគាំទ្រពីគម្រោង កម្មវិធីដាច់ដោយឡែកមួយចំនួនដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ និងស្ថិតក្រោមការគ្រប់គ្រង និងសម្របសម្រួលដោយលេខាធិការដ្ឋាន គ.ជ.អ.ប.។ សមិទ្ធផលសំខាន់ៗដែលសម្រេចបានដោយគម្រោងទាំងនេះមានសង្ខេបដូចខាងក្រោម ៖

- **គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប ជំហាន២៖** គម្រោងនេះ គាំទ្រដោយ ADB IFAD និងរាជរដ្ឋាភិបាលកម្ពុជារយៈពេលអនុវត្តពីឆ្នាំ២០១៨-២០២៣ ដោយគ្រោងថវិកាសរុបចំនួន៥៧,០៤៧លានដុល្លារ។ ថវិកាគ្រោងឡើងក្នុងឆ្នាំ២០២២ មានចំនួន១៦.៤៥២.៨០០ ដុល្លារ ក្នុងនោះចំណាយអស់ ១៣.៦២៩.៥៨៥ ដុល្លារ។ លទ្ធផលសំខាន់ៗរួមមាន បានរៀបចំ និងអនុវត្តគម្រោងចំនួន៥៤ ក្នុងនោះគម្រោងចំនួន៤៦ បានអនុវត្តចប់ ១០០% បានបង្កើត និងបណ្តុះបណ្តាលក្រុមកែលម្អជីវភាពថ្មីចំនួន ៧០២ ក្រុមដែលមានសមាជិកសរុប ១៧.៥៣៥ នាក់ ក្នុងនោះមានស្ត្រីចំនួន ៧៥% បានរៀបចំធ្វើបង្ហាញបច្ចេកទេសចំនួន៧៧ទីតាំង ស្តីពីបច្ចេកទេសផលិតកម្មសម្រាប់សមាជិកក្រុមកែលម្អជីវភាពថ្មីចំនួន ៣.៨៣៩នាក់ ក្នុងនោះស្ត្រីមានចំនួន ២.២១៥នាក់ បានរៀបចំទិវាផ្សព្វផ្សាយពេលប្រមូល



Vdo

ផលចំនួន២៣ កន្លែង ដែលមានសមាជិកលីកចូលរួមចំនួន ៥៧៣ នាក់ ក្នុងនោះស្ត្រីមានចំនួន២៩៣នាក់។

• **គម្រោងកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ ៖** គម្រោងនេះ គាំទ្រ ដោយ IFAD រយៈពេលអនុវត្តពីឆ្នាំ២០១៥-២០២២ ដោយគ្រោងថវិកាសរុបចំនួន ២០,៩០ លានដុល្លារ ហើយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប ទទួលបន្ទុកអនុវត្តសមាសភាគទី៤ នៃគម្រោងនេះ ។ ក្នុងឆ្នាំ២០២២ ថវិកាគ្រោងមានចំនួន ១.៤០០.០០០ ដុល្លារ និងបានចំណាយសរុបចំនួន ១.៤០០.០០០ ដុល្លារ ។ លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមាន បានសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធចំនួន ១៧គម្រោង និងបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ឃុំគោលដៅបាន ចំនួន១០៤ឃុំ ស្រុកគោលដៅចំនួន ៣២ស្រុក និងខេត្តគោលដៅចំនួន ៨ខេត្ត។

• **គម្រោងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាថាមពលពន្លឺព្រះអាទិត្យសម្រាប់វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទនៅកម្ពុជា ៖** គម្រោងនេះ គាំទ្រដោយ UNDP រយៈពេលអនុវត្តពីឆ្នាំ២០២១-២០២៣ ដោយគ្រោងថវិកាសរុបចំនួន ១២៧.០០០ដុល្លារ ។ ថវិកាគ្រោងឡើងក្នុងឆ្នាំ២០២២ មានចំនួន ៦៥.៦៧៦ ដុល្លារ ក្នុងនោះ ចំណាយ ៦០.៩៤៤,៤៩ ដុល្លារ។ លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមាន បានបំពាក់ប្រព័ន្ធបូមទឹកប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យសរុបចំនួន ៦៧ ប្រព័ន្ធ នៅក្នុងឃុំគោលដៅចំនួន២៣ឃុំ និងបានសាងសង់ផ្សារកសិករចំនួន០៤ ក្នុងខេត្តកំពង់ធំ និងខេត្តសៀមរាប។

• **នវានុវត្តនៃការផ្គត់ផ្គង់ទឹកស្អាតដែលធន់នឹងការប្រែប្រួលអាកាសធាតុ ៖** គម្រោងនេះគាំទ្រដោយអង្គការ UNCDF រយៈពេលអនុវត្តពីឆ្នាំ២០២០-២០២២ ដែលមានគ្រោងថវិកាសរុបចំនួន ៧១៨.៤៨៧ ដុល្លារ។ ក្នុងឆ្នាំ២០២២ ថវិកាគ្រោងមានចំនួន ២៧៦.៦៤០ ដុល្លារ និងបានចំណាយសរុបចំនួន ១០៩.៩៥១ ដុល្លារ។ លទ្ធផលសំខាន់ៗដែលសម្រេចបានមានដូចជា បានរៀបចំប្លង់បច្ចេកទេសសម្រាប់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតនៅឃុំបាសាក់ ស្រុករុក្ខគិរី ខេត្តបាត់ដំបង បានធ្វើលទ្ធកម្មជ្រើសរើសក្រុមហ៊ុនសាងសង់ស្ថានីយ និងបានរៀបចំសេចក្តីព្រាងលក្ខខណ្ឌកិច្ចព្រមព្រៀងរវាងរដ្ឋបាលឃុំបាសាក់ និងវិនិយោគិនឯកជនសម្រាប់ការគ្រប់គ្រងវិនិយោគ និងប្រតិបត្តិប្រព័ន្ធគ្រប់គ្រងទឹក។

• **គម្រោងសន្តិសុខស្បៀង និងការគាំទ្រការស្តារឡើងវិញរបស់សហគមន៍មូលដ្ឋាន ដែលរងផលប៉ះពាល់ដោយសារទឹកជំនន់នៅប្រទេសកម្ពុជា ៖** គម្រោងនេះ គាំទ្រដោយ WFP រយៈពេលអនុវត្តពីឆ្នាំ ២០២១-២០២២ ដោយគ្រោងថវិកាសរុបចំនួន ១.១៦៥.៣៣៧ដុល្លារ និងបានចំណាយអស់ចំនួន ១.១៤៨.០៦០ដុល្លារ។ លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមាន គម្រោងហេដ្ឋាសម្ព័ន្ធខ្នាតតូចមានចំនួន ១៩គម្រោង (គម្រោងជីកនិងស្តារប្រឡាយមានចំនួន០៨គម្រោង គម្រោងស្តារបឹងធម្មជាតិ/អាងស្តុកទឹកមានចំនួន០២គម្រោង និងគម្រោងជួសជុលផ្លូវក្រាលក្រួសក្រហមមានចំនួន០៩គម្រោង) និងបានអភិវឌ្ឍ សមត្ថភាពអំពីការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (CDP) និងកម្មវិធីវិនិយោគបីឆ្នាំរំកិល (CIP) ដល់ក្រុមការងារខេត្ត និងស្រុកគោលដៅ ក្រុមប្រឹក្សាឃុំ និង គ.ផ.ថ. សរុបចំនួន១៨៣នាក់។

• **គម្រោងអាហារូបត្ថម្ភនៅកម្ពុជា (CNP) ៖** គម្រោងនេះ គាំទ្រដោយធនាគារពិភពលោក និងដៃគូអភិវឌ្ឍន៍នានា រយៈពេលអនុវត្តពីឆ្នាំ២០១៩-២០២៦ ដោយបានគ្រោងថវិកាសរុបចំនួន ១០,៨ លានដុល្លារ

ហើយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប ទទួលបន្ទុកអនុវត្តសមាសភាគទី២ នៃគម្រោងនេះ។ ក្នុងឆ្នាំ២០២២ គម្រោងបានគ្រោងថវិកាចំនួន ២.៤៨៧.១៩៤ ដុល្លារ ដែលក្នុងនោះបានចំណាយអស់ ២.២៨៨.០៦០ ដុល្លារ។ លទ្ធផលសំខាន់ៗដែលសម្រេចបានមានដូចជា បានផ្ទេរមូលនិធិគាំទ្រការផ្តល់សេវា ឃុំ សង្កាត់ឱ្យរដ្ឋបាលក្រុង ស្រុកចំនួន៤៤ និងឃុំ សង្កាត់ចំនួន២៧៩ និងបានរៀបចំវគ្គបណ្តុះបណ្តាល ៨៣ វគ្គដល់រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលមានសិក្ខាកាមចំនួន ២.៨១៨នាក់ ក្នុងនោះស្ត្រី ៩៨៩នាក់។

• **គម្រោងពង្រឹងភាពអង់អាចដល់ស្ត្រីដើម្បីសង្គមធននឹងការប្រែប្រួលអាកាសធាតុ** ៖ គម្រោងនេះ គាំទ្រដោយ UNEP រយៈពេលអនុវត្តពីឆ្នាំ២០២០-២០២២ ដោយគ្រោងថវិកាសរុបចំនួន ១៧១.១៩២ ដុល្លារ។ ក្នុងឆ្នាំ២០២២ ថវិកាគ្រោងមានចំនួន ២១.៧២៦ ដុល្លារ និងបានចំណាយសរុបចំនួន ២១.៧២៦ ដុល្លារ ។ លទ្ធផលសំខាន់ៗ ដែលសម្រេចបានរួមមាន ៖ បានបង្កើតមូលនិធិ EmPower ដោយសហការជាមួយជាមួយធនគារ ARDB ក្នុងទិសដៅបង្កើតខ្សែបន្ទាត់ឥណ្ណទានសម្រាប់គាំទ្រស្ត្រី ដែលមានបំណងវិនិយោគលើថាមពលកកើតឡើងវិញ ផ្តល់បច្ចេកទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ យល់ដឹងការបញ្ជ្រាបការវិនិយោគលើថាមពលកកើតឡើងវិញ ក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ខ្លួន បានផ្តល់ចំណេះដឹងដល់ស្ត្រីគោលដៅស្តីការគ្រប់គ្រងអាជីវកម្ម និងហិរញ្ញវត្ថុផ្ទាល់ខ្លួន ដំឡើងម៉ាស៊ីនបូម ទឹកប្រើថាមពលពន្លឺព្រះអាទិត្យសម្រាប់ស្រោចស្រពបន្លែចំនួន៩គ្រួសារ និងបានដំឡើងប្រព័ន្ធសូឡាកូន កាត់សម្រាប់ស្រោចស្រពបន្លែក្នុងផ្ទះសំណាញ់ និងភ្ញាស់ស៊ុតមាន់១គ្រួសារ។

• **គម្រោងសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖** គម្រោងនេះ គាំទ្រដោយមូលនិធិបរធនបាលកិច្ច (WB រដ្ឋាភិបាលអាល្លឺម៉ង់ និងទីភ្នាក់ងារសហប្រតិបត្តិ ការសម្រាប់កិច្ច អភិវឌ្ឍន៍របស់ប្រទេសស្វីស SDC) និងរាជរដ្ឋាភិបាលកម្ពុជា រយៈពេលអនុវត្តពីឆ្នាំ ២០២០-២០២៣ ដោយគ្រោង ថវិកាសរុបចំនួន ១,៧២លានដុល្លារ ។ ថវិកាគ្រោងឡើងក្នុងឆ្នាំ២០២២ មានចំនួន ១.១១៩.៣៦៦ ដុល្លារ ក្នុងនោះចំណាយអស់ ៧៩៣.៥៧៤ ដុល្លារ ។ លទ្ធផល សំខាន់ៗរួមមាន បានពង្រីក និងអនុវត្តការងារគណនេយ្យភាពសង្គមនៅក្នុងរាជធានី ខេត្តចំនួន២៤ ក្រុង ស្រុក ខណ្ឌ ១៧៣ និងឃុំ សង្កាត់ ១.៤១៣ ដោយផ្តោតលើការផ្តល់សេវាចំនួន ០៣ គឺ សេវារដ្ឋបាលឃុំ សង្កាត់ចំនួន១.៤១៣ សេវាអប់រំកម្រិតបឋមសិក្សាចំនួន ៦.២៣១ សាលា និងមណ្ឌលសុខភាពចំនួន ១.១១០ និងសេវារដ្ឋបាលក្រុង ស្រុក ខណ្ឌ ២២ ក្នុងនោះធនាគារពិភពលោកបានគាំទ្រការអនុវត្តក្នុង ខេត្តចំនួន១០ ក្រុង ស្រុកចំនួន៥៥ និងឃុំ សង្កាត់ចំនួន៤៦៥។ ជាមួយគ្នានេះដែរ គម្រោងបាន ផ្សព្វផ្សាយព័ត៌មានអំពីសិទ្ធិ ស្តង់ដាការបំពេញការងារ ការផ្តល់សេវា និងថវិកាជូនប្រជាពលរដ្ឋចំនួន ៤២៥.០៤៩នាក់ ស្ត្រី ២៣៣.៤៣០ នាក់ និងគម្រោងសកម្មភាពគណនេយ្យសង្គមចំនួន ៤.៩១៦ គម្រោង ត្រូវបានគាំទ្រ និងអនុវត្តដោយប្រើប្រាស់ថវិកាឃុំសង្កាត់ និងដៃគូពាក់ព័ន្ធនានា។

• **ការអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ ៖** គម្រោងនេះ ត្រូវបានអនុវត្តដោយអង្គការ ចំនួន០៤ រួមមានអង្គការទស្សនៈពិភពលោក អង្គការអុកស្វាមកម្ពុជា អង្គការឃែរអន្តរជាតិប្រចាំកម្ពុជា អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) ដែលទទួលថវិកាគាំទ្រពីធនាគារពិភពលោក ទីភ្នាក់ងារ សហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) និងសហភាពអ៊ឺរ៉ុប។ ថវិកាគ្រោងប្រចាំឆ្នាំ២០២២

មានចំនួន៣.៣៦៨.០៧២ ដុល្លារ ក្នុងនោះចំណាយចំនួន ៣.០០៧.៧៤០ ដុល្លារ។ លទ្ធផលសំខាន់ៗរួមមាន បានពង្រីក និងបន្តអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការនៅក្នុងរាជធានី ខេត្តចំនួន ១៨ ក្រុង ស្រុក ខណ្ឌចំនួន៩៩ ដោយផ្តោតលើការផ្តល់សេវារដ្ឋបាលឃុំ សង្កាត់ចំនួន៧២៣ សាលាបឋមសិក្សាចំនួន២.៩៧១ មណ្ឌលសុខភាពចំនួន៥៣៧ និងការផ្តល់សេវាលើរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន១៩។ ជាមួយគ្នានេះ អង្គការសង្គមស៊ីវិលបានសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្សព្វផ្សាយព័ត៌មានអំពីសិទ្ធិ ស្តង់ដាការបំពេញការងារ ការផ្តល់សេវា និងថវិកាជូនប្រជាពលរដ្ឋចំនួន ៤៧៧.៩៧០នាក់ ស្ត្រី២៦៦.៣១៣នាក់ និងបានសម្របសម្រួលរៀបចំកិច្ចប្រជុំរួមដើម្បីបង្កើតផែនការសកម្មភាពរួមស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមចំនួន១៥.៤០៨ គម្រោងសកម្មភាព។

- **គម្រោងគាំទ្រស្ថាប័នទទួលហិរញ្ញប្បទានផ្ទាល់នៅកម្ពុជា ដើម្បីបំពេញលក្ខខណ្ឌទទួលស្គាល់** គម្រោងនេះ គាំទ្រដោយ GCF រយៈពេលអនុវត្តពីឆ្នាំ២០២១-២០២២ ដោយគ្រោងថវិកាសរុបចំនួន ៥១៧.០០០ដុល្លារ និងបានចំណាយថវិកាចំនួន**៤៧.០០២ ដុល្លារ**។ លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមាន បានរៀបចំបញ្ចប់ឯកសារទស្សនទានគម្រោងស្តីពីរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុដំណាក់កាលទី៣ បានរៀបចំវគ្គអភិវឌ្ឍសមត្ថភាពអំពីកិច្ចប្រតិបត្តិការ និងសវនកម្មផ្ទៃក្នុងរបស់ គ.ជ.អ.ប. ដល់មន្ត្រីលេខាធិការដ្ឋាន និងរដ្ឋបាលខេត្តចំនួន១១ខេត្ត ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៦៨នាក់ ស្ត្រី១៩នាក់ និងបានធ្វើលទ្ធកម្មជ្រើសរើសក្រុមហ៊ុននិងទីប្រឹក្សាសម្រាប់រៀបចំប្រព័ន្ធផ្សព្វផ្សាយនិងទទួលបណ្តឹងអំពីគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ។

- **គម្រោងធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា៖** គម្រោងនេះ គាំទ្រដោយ CCCA រយៈពេលអនុវត្តពីឆ្នាំ២០២២-២០២៣ ដោយគ្រោងថវិកាសរុបចំនួន៩៤.៩៦៧ ដុល្លារ។ ក្នុងឆ្នាំ២០២២ ថវិកាគ្រោងមានចំនួន១៤.៥៩៥ ដុល្លារ និងបានចំណាយសរុបចំនួន ១២.៣៥៧ ដុល្លារ ។ លទ្ធផលសំខាន់ៗ ដែលសម្រេចបានរួមមាន កំពុងពិនិត្យ និងធ្វើបច្ចុប្បន្នភាពនៃប្រព័ន្ធទិន្នន័យដែលមានស្រាប់ ដើម្បីធ្វើការសិក្សាអំពីអន្តរទំនាក់ទំនងរវាងប្រព័ន្ធទិន្នន័យព័ត៌មានមូលដ្ឋានទិន្នន័យឃុំ សង្កាត់ (CDB) ប្រព័ន្ធទិន្នន័យគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ(SPD) មូលដ្ឋានទិន្នន័យការអនុវត្តគម្រោង(PID) និងសន្ទស្សន៍ងាយរងគ្រោះ (VI) ដោយរកលទ្ធភាពសម្រាប់ការដាក់បញ្ចូលទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៣. ស្ថានភាពហិរញ្ញវត្ថុ

ក្នុងឆ្នាំ២០២២នេះ ចំណាយសរុបសម្រាប់ ផ.ស.ថ.របស់ គ.ជ.អ.ប. មានចំនួន**៤.៧៤៨.៨៧៣ លានរៀល** សមមូល**១.១៨៧ លានដុល្លារ** ស្មើនឹង**៨១**%នៃផែនការថវិកាដែលបានគ្រោងទុកសរុប **៥.៨៤៣.៩៣៣ លានរៀល** សមមូល**១.៤៦១ លានដុល្លារ**។ ការចំណាយនេះ រួមបញ្ចូលការចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងចំណាយរបស់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានាដែលបានគាំទ្រដល់ ផ.ស.ថ.ឆ្នាំ២០២២។ ខាងក្រោមនេះ បង្ហាញអំពីក្រាហ្វិកនានានៃការអនុវត្តចំណាយរបស់ក្រសួង ស្ថាប័នអនុវត្ត និងដៃគូអភិវឌ្ឍន៍តាមសេចក្តីសម្រេចរួមនិងកិច្ចព្រមព្រៀង និងចំណូលសរុបនិងចំណាយសរុបជាក់ស្តែងនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

- ចំពោះការអនុវត្តសកម្មភាពនានានៃសេចក្តីសម្រេចរួម និងកិច្ចព្រមព្រៀងរវាង គ.ជ.អ.ប. ជាមួយស្ថាប័នអនុវត្ត បានចំណាយថវិកាសរុបចំនួន**១១៦.១៨៨ លានរៀល** សមមូល**២៩លានដុល្លារ** ស្មើនឹង**៧៥%** ធៀបនឹងថវិកាគ្រោងមានចំនួន**១៥៥.០៤៧ លានរៀល** សមមូល**៣៩ លានដុល្លារ** ដូចរៀបរាប់សង្ខេបក្នុងតារាង និងក្រាហ្វិកដូចខាងក្រោម។

**តារាងទី៣ ៖ សង្ខេបការអនុវត្តថវិកាប្រចាំឆ្នាំ(គិតជាលានរៀល)**

| ល.រ. | ស្ថាប័នអនុវត្ត | ថវិកា | ការចំណាយ | |
|---|---|---|---|---|
| | | | ចំនួន | % |
| ១ | លេខាធិការដ្ឋាន គ.ជ.អ.ប | 8,550 | 8,549 | 99.98% |
| ២ | ក្រសួង ស្ថាប័ននានា | 11,626 | 9,573 | 82% |
| ៣ | រដ្ឋបាលថ្នាក់ក្រោមជាតិ | 11,922 | 7,021 | 59% |
| ៤ | គម្រោង កម្មវិធីដាច់ដោយឡែកនានា | 122,949 | 91,045 | 74% |
| | **សរុប** | **155,047** | **116,188** | **75%** |




- **រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់**បានចំណាយសរុបចំនួន**៤.៦៣៩.៧០៥ លានរៀល** សមមូល**១.១៦០ លានដុល្លារ** ស្មើនឹង**៨១%**នៃចំណូលសរុបដែលមានចំនួន**៥.៧០០.៨០៩ លានរៀល** សមមូល**១.៤២៥ លានដុល្លារ**



- **រាជធានី ខេត្ត** បានចំណាយសរុបចំនួន **៣.១៨៣.៦៨៨ លានរៀល** សមមូល **៧៩៦ លានដុល្លារ** ស្មើនឹង**៧៥%** នៃចំណូលសរុប ដែលមានចំនួន**៤.២២០.២៥១ លានរៀល សមមូល១.០៥៥ លានដុល្លារ**




- **ក្រុង ស្រុក** បានចំណាយសរុបចំនួន **៥៧៤.១៥៩ លានរៀល** សមមូល **១៤៤ លានដុល្លារ ស្មើនឹង៩៨%** នៃចំណូលសរុប ដែលមានចំនួន**៥៨៥.៥៥៦ លានរៀល** សមមូល**១៤៦ លានដុល្លារ**




- **ឃុំ សង្កាត់** បានចំណាយសរុបចំនួន **៨៨១.៨៥៨ លានរៀល** សមមូល**២២០ លានដុល្លារ** ស្មើនឹង**៩៩%** នៃចំណូលសរុប ដែលមានចំនួន**៨៩៥.០០២ លានរៀល** សមមូល**២២៤ លានដុល្លារ**។



## ៤. បញ្ហាប្រឈម និងសំណើដំណោះស្រាយ

ក្នុងការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២២នេះ សមិទ្ធផលនានាបានសម្រេចដូចបានរៀបរាប់ខាងលើទន្ទឹមនេះ ក៏នៅមានបញ្ហាប្រឈមជាគន្លឹះមួយចំនួនរួមមាន៖

- បញ្ហានៃការរីករាលដាលជំងឺឆ្លងកូវីដ-១៩ បានបណ្តាលឱ្យពន្យារពេលនៃការរៀបចំ និងដាក់ឱ្យអនុវត្តកម្មវិធីជាតិដំណាក់កាលទី២ រហូតដល់ខែមីនា ឆ្នាំ២០២២។ បញ្ហានេះនាំឱ្យការរៀបចំ និងការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២២ មានភាពយឺតយ៉ាវធៀបទៅនឹងបណ្តាឆ្នាំមុនៗ។ ជាក់ស្តែង ផ.ស.ថ. ឆ្នាំ២០២២នេះ ត្រូវបានអនុម័តដោយ គ.ជ.អ.ប. នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២ ដែលនាំឱ្យការរៀបចំ និងការអនុវត្តសេចក្តីសម្រេចរួមរវាង គ.ជ.អ.ប. ជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏មានភាពយឺតយ៉ាវផងដែរ។
- ឆ្នាំ២០២២ ការអនុវត្ត ផ.ស.ថ. បាននិងកំពុងជួបប្រទះនូវជំងឺឆ្លងកាចសាហាវកូវីដ-១៩ ដែលបានពន្យារពេល ឬផ្អាកការអនុវត្តសកម្មភាពជាច្រើនរួមបញ្ចូលទាំងសកម្មភាព ចុះតាមដាន និងគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារដែលបានផ្ទេរ។ សកម្មភាពសំខាន់ៗដែលបានពន្យារពេលរួមមាន ៖
    1. ពិធីប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តនូវកម្មវិធីជាតិដំណាក់កាលទី២ដែលបានធ្វើឡើងនៅក្នុងខែមីនា ឆ្នាំ២០២២
    2. ផែនការអនុវត្តរយៈពេលប្រាំឆ្នាំដំណាក់កាលទី១នៃ កជទី២ កំពុងដំណើរការរៀបចំ
    3. ផែនការសកម្មភាព និងថវិកា ឆ្នាំ២០២២ ត្រូវបានអនុម័តនៅថ្ងៃទី ០១ ខែមេសា ឆ្នាំ២០២២
    4. សេចក្តីសម្រេចរួមរវាង គ.ជ.អ.ប. និងស្ថាប័នអនុវត្តនានា ត្រូវបានរៀបចំ និងអនុម័តភាគច្រើនក្នុងត្រីមាសទី១
    5. ការចុះតាមដាន គាំទ្រ និងការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តតួនាទី ភារកិច្ច និងមុខងារដែលបានផ្ទេរ
    6. ការរៀបចំ និងការអនុវត្តគម្រោងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ល។

- ***ចំពោះបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តមុខងារដែលបានផ្ទេររួមមាន ៖***
    1. ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក៏បានជួបបញ្ហាប្រឈមជាគន្លឹះមួយចំនួនពាក់ព័ន្ធនឹងកម្រិតនៃសិទ្ធិអំណាចកិច្ចការរដ្ឋបាល និងកែសម្រួល រួមមានពង្រឹងយន្តការគាំទ្រ ការអភិវឌ្ឍសមត្ថភាព ការតាមត្រួតពិនិត្យដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការដោះស្រាយបញ្ហាប្រឈមនានា
    2. ការខ្វះមន្ត្រីជំនាញនៅតាមការិយាល័យមួយចំនួនដែលបានបង្កើតរួចហើយ

៣. ការអនុវត្តសិទ្ធិអំណាចមិនបានសមស្របរបស់ក្រុង ស្រុក ខណ្ឌមួយចំនួនក្នុងការតែងតាំង និងការផ្លាស់ប្តូរបុគ្គលិក បន្ទាប់ពីសមាហរណកម្មនៃការិយាល័យជំនាញទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងក្រុង ស្រុក ខណ្ឌ
៤. ការរៀបចំលិខិតបទដ្ឋាន និងឯកសារបច្ចេកទេសស្តីពីការគ្រប់គ្រងបុគ្គលិក និងការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
៥. ថវិកាសម្រាប់អនុវត្តមុខងារវិស័យទាំង២០ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានចំនួនតិចតួចក្នុងការជានាឱ្យការិយាល័យជំនាញនានាអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ។

- ***សកម្មភាពជាអាទិភាពដែលមិនបានអនុវត្តមានចំនួន១២ ដែលរួមមានដូចខាងក្រោម៖***

១. ការបន្តពង្រឹងអនុគណៈកម្មាធិការនានា របស់ គ.ជ.អ.ប. ក្នុងការបំពេញភារកិច្ចឱ្យមានប្រសិទ្ធភាព
២. ការរៀបចំវេទិកា ឬកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្លាស់ប្តូរយោបល់លើការអនុវត្តគោលនយោបាយនានា
៣. ការវាស់វែងលទ្ធផលនៃការប្រាស្រ័យទាក់ទង
៤. ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំ រដ្ឋបាលខេត្តក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់
៥. ការកែសម្រួល និងការបង្កើតគណៈកម្មាធិការនានាបន្ថែមទៀតរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
៦. ការរៀបចំកញ្ចប់ថវិកាជាក់លាក់សម្រាប់គាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ
៧. ការផ្តល់ការលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមលទ្ធផលនៃការវាយតម្លៃការងារ
៨. ការសិក្សាអំពីជម្រើសនានាសម្រាប់ផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
៩. ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ការបង្កើតមូលនិធិភាតរភាពទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
១០. ការបន្ស៊ីគ្នារវាងកម្មវិធីជាតិដំណាក់កាលទី២ និងឯកសារគោលស្តីពីការកែទម្រង់ប្រព័ន្ធ គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
១១. ការពង្រឹងនូវប្រព័ន្ធគ្រប់គ្រងមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ
១២. ការពង្រឹងការធ្វើអធិការកិច្ចហិរញ្ញវត្ថុពីខាងក្រៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៥. សកម្មភាពជាអាទិភាពសម្រាប់ឆ្នាំ២០២៣

សកម្មភាពជាអាទិភាពតាមសមាសភាគនីមួយៗដែលត្រូវអនុវត្តក្នុងឆ្នាំ២០២៣ រួមមានដូចខាងក្រោម៖

### សមាសភាគទី១៖ ការដឹកនាំ និងសម្របសម្រួលការងារកំណែទម្រង់

១. ការបន្តពង្រឹងតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់

២. ការបន្តពង្រឹងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក្នុងការបំពេញភារកិច្ចឱ្យមានប្រសិទ្ធភាព

៣. ការពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.

៤. ការលើកកម្ពស់ប្រសិទ្ធភាពដឹកនាំរបស់គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

៥. ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានា

៦. ការរៀបចំវេទិកា ឬកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

៧. ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានាប្រកបដោយភាពស្ថាបនា

៨. ការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

៩. ការកែលម្អ និងការពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង

១០. ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង (យុទ្ធសាស្ត្រដែលមានស្រាប់)

១១. ការវាស់វែងលទ្ធផលនៃការប្រាស្រ័យទាក់ទង

១២. ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការអនុវត្តដំណាក់កាលនីមួយៗនៃកជទី២

១៣. ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប.

១៤. ការរៀបចំ និងដាក់បញ្ចូលកិច្ចការ ឬគម្រោងនានានៃកជទី២ទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័នអនុវត្តនីមួយៗ

១៥. ការរៀបចំគម្រោងនានាដែលគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ ឬ អង្គការសង្គមស៊ីវិលនានាដោយបន្សុីជាមួយកជទី២

១៦. ការរៀបចំ និងការអនុវត្តសាកល្បងនូវគំនិតផ្តួចផ្តើមថ្មីៗ

១៧. ការសម្របសម្រួល ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តកជទី២

១៨. ការសិក្សាអំពីជម្រើសជាយុទ្ធសាស្ត្រនានាត្រូវបានបញ្ចប់

១៩. ការពង្រឹងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

២០. ការសិក្សាអំពីជម្រើសនៃការកែសម្រួលចេនាសម្ព័ន្ធ និងតួនាទី របស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់

ក្រោមជាតិ

២១. ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយនានាពាក់ព័ន្ធនឹងកំណែទម្រង់

## សមាសភាគទី២៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

១. ការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់រដ្ឋបាលក្រុង ស្រុក

២. ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាលឃុំ សង្កាត់

៣. ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលខេត្តក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់

៤. ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ

៥. ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ

៦. ការកែសម្រួល និងការបង្កើតគណៈកម្មាធិការនានាបន្ថែមទៀតរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ

៧. ការពង្រឹងលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

៨. ការពង្រឹងយន្តការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ

៩. ការពង្រឹងយន្តការសម្រាប់ទទួល និងដោះស្រាយបណ្តឹងតវ៉ា និងសំណើសំណូមពររបស់ប្រជាពលរដ្ឋ

១០. ការលើកកម្ពស់ការចូលរួមរបស់អង្គការស៊ីវិលនៅក្នុងកិច្ចដំណើរការចូលរួមរបស់ប្រជាពលរដ្ឋ។

១១. ការពង្រឹង និងការពង្រីកលទ្ធភាពក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិត

១២. ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

១៣. ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

## សមាសភាគទី៣៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

១. ការពិនិត្យ និងកែសម្រួលអង្គមន្ត្រីរាជការ

២. ការរៀបចំការពិពណ៌នាមុខតំណែងរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

៣. ការពង្រឹងការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

៤. ការពង្រឹងការគ្រប់គ្រងវត្តមានបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

៥. ការរៀបចំក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

៦. ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រង ធនធានមនុស្សនៅថ្នាក់ក្រោមជាតិ

៧. ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីការវាយតម្លៃអំពីតម្រូវការធនធានមនុស្សទាំងបរិមាណ និងវិជ្ជាជីវៈ

៨. ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៩. លើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

១០. ការពិនិត្យ និងការកែសម្រួលនូវឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

១១. ការពង្រឹងសមត្ថភាពដល់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត អំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព

១២. ការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមតម្រូវការអភិវឌ្ឍសមត្ថភាព

១៣. ការជ្រើសរើស និងការពង្រឹងសមត្ថភាពបុគ្គលិកនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន

១៤. កិច្ចសហការជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈនិងឯកជន និងស្ថាប័នពាក់ព័ន្ធនានាដើម្បីរៀបចំ និងអនុវត្តការបណ្តុះបណ្តាល

១៥. ការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមគោលដៅផ្សេងៗ

១៦. ការជ្រើសរើសស្ថាប័នអភិវឌ្ឍសមត្ថភាព ស្ថាប័នជំនាញវិជ្ជាជីវៈ និងអ្នកជំនាញវិជ្ជាជីវៈដើម្បីចូលរួមរៀបចំកម្មវិធីសិក្សា និងឯកសារសម្ភារៈបណ្តុះបណ្តាល

១៧. ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលនានា

១៨. ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពលើឯកសារសម្ភារៈបណ្តុះបណ្តាលសម្រាប់កម្មវិធីសិក្សានានា

១៩. ការជ្រើសរើស និងការអនុម័តវិធីសាស្ត្រផ្សេងៗសម្រាប់វគ្គបណ្តុះបណ្តាលនានា

២០. ការលើកកម្ពស់ការបណ្តុះបណ្តាលតាមបណ្តុំវិស័យ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក

**សមាសភាគទី៤÷ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ**

១. ការបន្សុីគ្នារវាងកិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

២. ការរៀបចំឯកសារជាយុទ្ធសាស្ត្រនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៣. ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៤. ការបន្តការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៥)

៥. ការធ្វើវិមជ្ឈការ និងការពង្រឹងការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៦. ការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលសារពើពន្ធដែលមានស្រាប់

៧. ការចែករំលែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់។

៨. ការលើកកម្ពស់ការប្រមូល និងការគ្រប់គ្រងកម្រៃ ឬឈ្នួលសេវា

៩. ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

១០. ការបង្កើនការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលក្រុង ស្រុក

១១. ការពង្រឹងប្រព័ន្ធគ្រប់គ្រងមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ

១២. ការលើកកម្ពស់ការអនុវត្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌក្នុងក្របខ័ណ្ឌដែលមានបច្ចុប្បន្ន ព្រមទាំងរៀបចំ និង កែលម្អក្របខ័ណ្ឌផ្តល់ហិរញ្ញប្បទានដល់មុខងារជាកាតព្វកិច្ចឱ្យកាន់តែប្រសើរឡើង

១៣. ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង និងការរៀបចំនីតិវិធីសវនកម្មផ្ទៃក្នុងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

**សមាសភាគទី៥៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន**

១. ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច

២. ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើស

៣. ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមរយៈអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត

៤. ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

៥. ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ

៦. ការរៀបចំបញ្ជីមូលដ្ឋានអាជីវកម្ម ឬសហគ្រាសនៅតាមមូលដ្ឋាន

៧. ការបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវ

៨. ការកំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវាដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ

៩. ការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា

## ៦. សេចក្តីសន្និដ្ឋាន

ជារួម ទោះបីការអនុវត្តផែនការសកម្ម និងថវិកាឆ្នាំ២០២២ របស់គ.ជ.អ.ប ស្ថិតក្នុងស្ថានភាពនៃការបន្តរីករាលដាលនៃជម្ងឺកូវីដ-១៩ដែលបានធ្វើឲ្យការអនុវត្តមានភាពយឺតយ៉ាវ មិនអាចអនុវត្តបាននូវសកម្មភាពជាអាទិភាពមួយចំនួន និងជួបប្រទះនូវបញ្ហាប្រឈមជាគន្លឹះមួយចំនួនក៏ដោយ ក៏ក្រោមការដឹកនាំ និងសម្របសម្រួលរបស់ គ.ជ.អ.បដែលមាន **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប** ស្ថាប័នអនុវត្តនិងភាគីពាក់ព័ន្ធនានាបានខិតខំប្រឹងប្រែង ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការចូលរួម និងការអនុវត្ត ផ.ស.ថ.នេះឲ្យសម្រេចបានសមិទ្ធផល និងលទ្ធផលជាច្រើនពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការដឹកនាំ សម្របសម្រួល និងការទទួលខុសត្រូវក្នុងភាពជាម្ចាស់លើការងារកំណែទម្រង់របស់ គ.ជ.អ.ប និងស្ថាប័នអនុវត្តនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការពង្រឹងសមត្ថភាព និងប្រសិទ្ធភាពនៃការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាពិសេសការអនុវត្តមុខងារជាអាណត្តិទូទៅ និងមុខងារជាកាតព្វកិច្ចដែលបានផ្ទេរមកឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធាននានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលរួមមានធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិដែលបានផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងការពង្រឹងយន្តការ នីតិវិធី និងស្តង់ដារសម្រាប់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ព្រមជាមួយនូវការលើកកម្ពស់ការងារគណនេយ្យភាពសង្គមតាមរយៈការពង្រឹងយន្តការចូលរួម យន្តការផ្តល់ព័ត៌មាន និងយន្តការទទួល និងសម្របសម្រួលដោះស្រាយបណ្តឹងតវ៉ានានារបស់ប្រជាពលរដ្ឋ។

ក្នុងឆ្នាំ២០២២នេះ រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិតបានខិតខំប្រឹងប្រែងអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនឲ្យមានការរីកចម្រើនជាបន្តបន្ទាប់តាមរយៈការអភិវឌ្ឍគម្រោងហេដ្ឋារចនាសម្ព័ន្ធនានា និងការផ្តល់សេវាសាធារណៈកាន់តែមានគុណភាព និងប្រសិទ្ធភាពដោះស្រាយបានជាបណ្តើរៗនូវសំណើសំណូមពរចាំបាច់នានារបស់ប្រជាពលរដ្ឋ។ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋកាន់តែមានការយល់ដឹង និងចូលរួមយ៉ាងសកម្មជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអភិវឌ្ឍមូលដ្ឋាន។

ការសម្រេចបាននូវសមិទ្ធផល និងលទ្ធផលទាំងនេះ គឺជាការរួមចំណែកមួយក្នុងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ចូលរួមកាត់បន្ថយភាពក្រីក្រយ៉ាងមានប្រសិទ្ធភាព និងលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋបានយ៉ាងល្អប្រសើរ ជាពិសេសការចូលរួមប្រែក្លាយប្រទេសកម្ពុជា ជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០៕



Vdo

## ឧបសម្ព័ន្ធទី១៖ វឌ្ឍនភាពលម្អិតនៃការអនុវត្តសកម្មភាពជាអាទិភាពចំនួន៨៥ ធៀបនឹងចំណុចដៅដែលគ្រោងទុកក្នុងឆ្នាំ២០២២

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| 1 | **ការដឹកនាំ និងការសម្របសម្រួលការងារ កំណែទម្រង់** | | | | | |
| 1.1.1 | ការបន្តពង្រឹងតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួលកម្មវិធី កំណែទម្រង់ | 1. ចំនួនកិច្ចប្រជុំ គ.ជ.អ.ប. ដែលបានរៀបចំ | កិច្ចប្រជុំ | 2 | កំពុងដំណើរការ | – ក្នុងឆ្នាំ២០២២នេះ គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំចំនួន២ លើក គឺលើកទី១ ជាកិច្ចប្រជុំលក្ខណៈចង្អៀតក្នុងចំណោម ក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.អ.ប. ចំនួន០៤ក្រសួង រួមមាន ក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួងយុត្តិធម៌ដោយមានការចូលរួមពី តំណាងក្រុមអ្នកច្បាប់នៃទីស្តីគណៈរដ្ឋមន្ត្រីនាថ្ងៃទី០៨ ខែ សីហា ឆ្នាំ២០២២ ដើម្បីពិនិត្យ និងឯកភាពលើគោលការណ៍ សំខាន់ៗពាក់ព័ន្ធនឹងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ សេចក្តីព្រាងច្បាប់ស្តីពីជលផល និងសេចក្តីព្រាងច្បាប់ស្តីពី តំបន់ការពារធម្មជាតិ។ ចំណែកកិច្ចប្រជុំលើកទី២ ជាកិច្ចប្រជុំ លើកទី២០របស់ គ.ជ.អ.ប. ដែលត្រូវបានរៀបចំឡើងនាថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០២២ ដោយពិនិត្យសម្រេចទៅលើរបៀបវារៈសំ ខាន់ៗរួមមាន (១). ការពិនិត្យ និងឯកភាពលើសេចក្តីព្រាង ច្បាប់ស្តីពីព្រៃឈើ សេចក្តីព្រាងច្បាប់ស្តីពីជលផល និងសេចក្តី ព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (២). ការពិនិត្យ និងអនុ ម័តផអ៥ទី១ នៃកជទី២ និង (៣). ការពិនិត្យ និងផ្តល់ យោបល់លើវឌ្ឍនភាពនៃការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី ការកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែង សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |
| | | 2. ចំនួនសរុបលិខិតបទដ្ឋានដែលបាន ពិនិត្យ និងអនុម័តដោយ គ.ជ.អ.ប. | លិខិតបទដ្ឋាន | 10 | កំពុងដំណើរការ | – (១). ការពិនិត្យ និងឯកភាពលើសេចក្តីព្រាងច្បាប់ស្តីពីព្រៃ ឈើ សេចក្តីព្រាងច្បាប់ស្តីពីជលផល និងសេចក្តីព្រាងច្បាប់ស្តី ពីតំបន់ការពារធម្មជាតិ (២). ការពិនិត្យ និងអនុម័តផអ៥ទី១ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | ចង្អុលភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | នៃកដទី២ និង (៣). ការពិនិត្យ និងផ្តល់យោបល់លើវឌ្ឍនភាពនៃការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |
| 1.1.2 | ការបន្តពង្រឹងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក្នុងការបំពេញភារកិច្ច ឱ្យមានប្រសិទ្ធភាព | 3. ចំនួនកិច្ចប្រជុំអនុគណៈកម្មាធិការ គ.ជ.អ.ប. ដែលបានរៀបចំ | កិច្ចប្រជុំ | | មិនបានអនុវត្ត | |
| | | 4. ចំនួនសរុបលិខិតបទដ្ឋាននានាដែលបានរៀបចំ និងដាក់ជូន គ.ជ.អ.ប.ពិនិត្យ និងអនុម័ត | លិខិតបទដ្ឋាន | 5 | មិនបានអនុវត្ត | |
| 1.1.3 | ការពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. | 5. ភាគរយសរុបបុគ្គលិកលេខាធិការដ្ឋាន គ.ជ.អ.ប. ដែលទទួលបានការបណ្តុះបណ្តាល | បុគ្គលិក | 70% | បានបញ្ចប់ | លេខាធិការដ្ឋាន គ.ជ.អ.ប. បានរៀបចំ និងដាក់ឱ្យដំណើរការនូវក្រុមការងារទទួល និងដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងការអនុវត្តគម្រោងនិងកម្មវិធីនានាក្នុងក្របខ័ណ្ឌកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងបានអភិវឌ្ឍសមត្ថភាពដល់មន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប. រួមមានដូចជា៖<br>- សិក្ខាសាលាពង្រឹងសមត្ថភាពដល់មន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីរៀបចំសំណើគម្រោងស្របតាមគោលការណ៍ និងនីតិវិធីរបស់មូលនិធិអាកាសធាតុបៃតងដោយមានអ្នកចូលរួមសរុប ៣២រូប ក្នុងនោះស្ត្រី១១រូប នាថ្ងៃទី៤ ដល់ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២<br>- សិក្ខាសាលាពង្រឹងសមត្ថភាពតាមអនឡាញអំពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ការរៀបចំសំណើគម្រោងនិងការអនុវត្តគម្រោង ការរៀបចំផែនការសកម្មភាព និងការវិភាគទិន្នន័យគម្រោងដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុតាមរយៈការសម្របសម្រួលដោយមូលនិធិអាកាសធាតុបៃតងនាថ្ងៃទី០១-១៩ ខែកក្កដា ឆ្នាំ២០២២ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | - វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិស្តីពីកិច្ចប្រតិបត្តិការមូលនិធិគាំទ្រការផ្តល់សេវាឃុំ សង្កាត់ នៃគម្រោងអាហារូបត្ថម្ភនៅកម្ពុជាចំនួន០៤វគ្គ ដោយមានអ្នកចូលរួមចំនួន៩៧នាក់ ស្ត្រីចំនួន២៧នាក់ ក្នុងឆ្នាំ២០២២<br>- វគ្គបណ្តុះបណ្តាលការអភិវឌ្ឍសមត្ថភាពលើភាពជាអ្នកដឹកនាំរបស់មន្ត្រីរាជការជាស្ត្រីនាថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០២២<br>- ថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានចូលរួមវគ្គបណ្តុះ<br>- បណ្តាលភាពជាអ្នកដឹកនាំចំនួន៩០នាក់ ស្ត្រីចំនួន៩០នាក់<br>- វគ្គបណ្តុះបណ្តាលអំពីសៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការកម្មវិធី និងសវនកម្មផ្ទៃក្នុងនាថ្ងៃទី៩ ដល់ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ អ្នកចូលរួមសរុបចំនួន៧១នាក់ ស្ត្រីចំនួន២៦នាក់មកពីរាជធានី ខេត្តទាំង២៥<br>- ការបញ្ជូនមន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប. ចំនួន១នាក់ទៅទទួលការបណ្តុះបណ្តាលរយៈពេលខ្លីនៅក្រៅប្រទេសពាក់ព័ន្ធនឹងប្រធានបទស្តីពីរដ្ឋាភិបាលអេឡិចត្រូនិក និងគ្រប់គ្រងរដ្ឋបាលសាធារណៈនៅប្រទេសកូរ៉េ ( Master in E-Government and Public Management ) នាខែសីហា ឆ្នាំ២០២១ ដល់ខែកុម្ភៈ ឆ្នាំ២០២៣<br>- ការបញ្ជូនមន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប. ចំនួន១នាក់ទៅទទួលការបណ្តុះបណ្តាលរយៈពេលខ្លីនៅក្រៅប្រទេសពាក់ព័ន្ធនឹងប្រធានបទស្តីពីអភិបាលកិច្ច និងរដ្ឋបាលសាធារណៈនៅទីក្រុងហ្សូរីច ប្រទេសស្វីស នាថ្ងៃទី២៣ ខែសីហា ដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
| --- | --- | --- | --- | --- | --- | --- |
| | | | | | | - ការរៀបចំ និងសម្របសម្រួលសិក្ខាសាលា (តាមរយៈ Zoom) ស្តីពីការពង្រឹងលទ្ធិប្រជាធិបតេយ្យសម្រាប់ប្រជាជន និងបទពិសោធន៍នៃការអនុវត្តនៅប្រទេសចិននាថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០២២ ដោយសហការជាមួយបណ្តាញអង្គការមិនមែនរដ្ឋាភិបាលនៃប្រទេសចិនសម្រាប់ការផ្លាស់ប្តូរអន្តរជាតិ និងវិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍកម្ពុជា ដែលមានសិក្ខាកាមសរុបចំនួន៤៥៧នាក់ មកពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល។ |
| 1.1.4 | ការលើកកម្ពស់ប្រសិទ្ធភាពដឹកនាំរបស់គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ (គ.ដ.វ.វ.) | 6. ចំនួន គ.ដ.វ.វ. ថ្មីដែលបានបង្កើត | គណៈកម្មការ | 10 | កំពុងដំណើរការ | រដ្ឋបាលខេត្តត្បូងឃ្មុំបានពិនិត្យ និងកែសម្រួលសមាសភាព គ.ដ.វ.វ. របស់ខ្លួនដោយបញ្ចូលតំណាងមកពីមន្ទីរ អង្គភាពពាក់ព័ន្ធមួយចំនួនជាសមាជិក គ.ដ.វ.វ.។ |
| | | 7. ចំនួនកិច្ចប្រជុំ គ.ដ.វ.វ. ដែលបានរៀបចំដោយក្រសួង ស្ថាប័ន | កិច្ចប្រជុំ | 40 | កំពុងដំណើរការ | គ.ដ.វ.វ. នៃក្រសួង ស្ថាប័នថ្នាក់ជាតិ បានរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីបូកសរុបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២១ និងការត្រួតពិនិត្យការអនុវត្ត ផ.ស.ថ. ឆ្នាំ ២០២២ ព្រមទាំងការរៀបចំ ផ.ស.ថ. ឆ្នាំ២០២៣។ ទន្ទឹមនឹងនេះ សេចក្តីសម្រេចរួមរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយនឹងក្រសួង ស្ថាប័ន ពាក់ព័ន្ធចំនួន១៧ ត្រូវបានរៀបចំ ចុះហត្ថលេខា និងអនុវត្ត។ |
| | | 8. ចំនួនកិច្ចប្រជុំ គ.ដ.វ.វ. ដែលបានរៀបចំដោយរដ្ឋបាលថ្នាក់ក្រោមជាតិ | កិច្ចប្រជុំ | 400 | កំពុងដំណើរការ | – គ.ដ.វ.វ. នៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ បានរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីបូកសរុបអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២១ និងការត្រួតពិនិត្យការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២២ ព្រមទាំងការរៀបចំ ផ.ស.ថ. ឆ្នាំ២០២៣។ ទន្ទឹមនឹងនេះ សេចក្តីសម្រេចរួមរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយនិងរដ្ឋបាលរាជធានី ខេត្តទាំង២៥ត្រូវបានរៀបចំ ចុះហត្ថលេខា និងអនុវត្ត។ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| 1.1.5 | ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានា | 9. ចំនួនកិច្ចប្រជុំរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានាដែលបានរៀបចំ | កិច្ចប្រជុំ | 2 | បានបញ្ចប់ | – លេខាធិការដ្ឋាននៃកំណែទម្រង់៣បូក១ (លេខាធិការដ្ឋាន គ.ជ.អ.ប. លេខាធិការដ្ឋានកំណែទម្រង់រដ្ឋបាលសាធារណៈ អគ្គលេខាធិការដ្ឋានកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអគ្គលេខាធិការដ្ឋានកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌) បានរៀបចំកិច្ចប្រជុំជាទៀងទាត់ប្រចាំត្រីមាស និងតាមវេនដឹកនាំរបស់លេខាធិការដ្ឋាន/អគ្គលេខាធិការដ្ឋាននីមួយៗ ព្រមទាំងបានរៀបចំកិច្ចប្រជុំដោយឡែកចំនួន០៤លើក ដើម្បីពិនិត្យ និងរៀបចំឯកសារទស្សនទានស្តីពីចក្ខុវិស័យ និងយុទ្ធសាស្ត្រសុខដុមនីយកម្មនៃកំណែទម្រង់៣បូក១ ផែនការអនុវត្តឯកសារទស្សនទាន និងអនុក្រឹត្យស្តីពីការបង្កើតយន្តការនៃលេខាធិការដ្ឋាន៣បូក១។ លេខាធិការដ្ឋាននៃកំណែទម្រង់៣បូក១បានសហការគ្នារៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានានូវឯកសារទស្សនទានស្តីពីចក្ខុវិស័យ និងយុទ្ធសាស្ត្រសុខដុមនីយកម្មនៃកំណែទម្រង់៣បូក១ ផែនការអនុវត្តឯកសារទស្សនទាន និងអនុក្រឹត្យស្តីពីការបង្កើតយន្តការនៃលេខាធិការដ្ឋាន៣បូក១ នាថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២ ក្រោមអធិបតីភាពសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប. ក្នុងពិធីបិទ និងក្រោមអធិបតីភាពឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការដឹកនាំការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងពិធីបើក។ |
| 1.1.6 | ការរៀបចំវេទិកា ឬកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោម | 10. ចំនួនកិច្ចប្រជុំដែលបានរៀបចំ | វេទិកា | 1 | មិនបានអនុវត្ត | |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | ជាតិ ដើម្បីផ្លាស់ប្តូរយោបល់លើការអនុវត្តគោលនយោបាយនានា | | | | | |
| 1.1.7 | ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានាប្រកបដោយភាពស្ថាបនា | 11. ចំនួនកិច្ចប្រជុំ TWG-SNDD ដែលបានរៀបចំ | កិច្ចប្រជុំ | 2 | កំពុងដំណើរការ | – បានសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍នានានិងអង្គការសង្គមស៊ីវិលដែលជាសមាជិកក្រុមការងារបច្ចេកទេសស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (TWG-SNDD) ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងឯកសារ ផអ៥ទី១ (២០២១-២០២៥)។ |
| 1.1.8 | ការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម តាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | 12. ចំនួនកិច្ចប្រជុំយន្តការយេនឌ័រថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលបានរៀបចំ | កិច្ចប្រជុំ | 750 | បានបញ្ចប់ | ក្រុមការងារយេនឌ័រសម្រាប់គាំទ្រការអនុវត្ត កជទី២ នៃលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបានពិនិត្យ និងកែសម្រួលទាំងសមាសភាព និងតួនាទី ភារកិច្ច និងការទទួលខុសត្រូវ។ គណៈកម្មការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ និងគណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ បានរៀបចំកិច្ចប្រជុំរបស់ខ្លួនជាទៀងទាត់ ដើម្បីពិនិត្យអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។ ទន្ទឹមនឹងនោះ លេខាធិការដ្ឋាន គ.ជ.អ.ប. ក៏បានសហការជាមួយនឹងក្រសួងកិច្ចការនារី ដោយមានការគាំទ្រពីកម្មវិធីធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈនៅប្រទេសកម្ពុជា (ISD/GIZ) បាន និងកំពុងរៀបចំកែសម្រួលផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ គិតមកដល់ចុងឆ្នាំ២០២២នេះ ចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រេចបានដូចខាងក្រោម៖ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | – មុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត ចំនួន ៧៦នាក់ ស្មើនឹង ១២.១២%<br>– មុខតំណែងគ្រប់គ្រងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំនួន ៧៦៦នាក់ ស្មើនឹង១៩.៥២%<br>– មុខតំណែងគ្រប់គ្រងនៅរដ្ឋបាលឃុំ សង្កាត់ រួមមាន មេឃុំ ចៅសង្កាត់មានចំនួន១៧៣នាក់ ស្មើនឹង១០.៤៧% ជំទប់ទី១មានចំនួន៣១៩ ស្មើ ១៩.៣១% ជំទប់ទី២មានចំនួន១៨៩ ស្មើ១១.៤៤% |
| 1.2.1 | ការកែលម្អ និងការពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង | 13. យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងត្រូវបានពិនិត្យ កែសម្រួល និងអនុម័ត | យុទ្ធសាស្ត្រ | 1 | កំពុងដំណើរការ | យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងក្នុងក្របខ័ណ្ឌកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ និងកែសម្រួលដោយផ្តោតជាសំខាន់ទៅលើគោលនយោបាយ និងវិធីសាស្ត្រនៃការទំនាក់ទំនង និងការផ្សព្វផ្សាយព័ត៌មាន ដើម្បីលើកកម្ពស់ការប្រាស្រ័យទាក់ទង និងការចែករំលែកព័ត៌មានឱ្យបានទូលំទូលាយទៅដល់អ្នកពាក់ព័ន្ធ និងសាធារណជននានាដែលមានស្រាប់សម្រាប់ជាមូលដ្ឋានក្នុងការកែសម្រួលយុទ្ធសាស្ត្រនេះ។ ឯកសារយុទ្ធសាស្ត្រនេះនឹងត្រូវពិនិត្យ កែសម្រួល និងអនុម័តក្នុងឆ្នាំ២០២៣។ |
| 1.2.2 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង | 14. ចំនួនសរុបឯកសារព័ត៌មានស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បានផ្សព្វផ្សាយ | ឯកសារព័ត៌មាន | 230 | បានបញ្ចប់ | បានរៀបចំ និងផ្សព្វផ្សាយឯកសារព័ត៌មានសំខាន់ៗដែលពាក់ព័ន្ធទៅនឹងចក្ខុវិស័យ គោលបំណង គោលដៅ និងសមិទ្ធផល លទ្ធផលរំពឹងទុកនានានៃ កជទី២ ព្រមទាំងផ្សព្វផ្សាយអំពីសមិទ្ធផលនានាដែលសម្រេចបានក្នុងការអនុវត្ត កជទី១ ដែលរួមមានដូចខាងក្រោម៖<br>– ឯកសារព័ត៌មានចំនួន៤៦៤ឯកសារ ត្រូវបានដាក់បញ្ចូល និងផ្សព្វផ្សាយក្នុងគេហទំព័រ និងក្នុងបណ្តាញសង្គមរួមមាន Facebook និង YouTube<br>– ខិតប័ណ្ណផ្សព្វផ្សាយស្តីពីខ្លឹមសារសំខាន់ៗនៃ កជទី២ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | – បោះពុម្ពផ្សព្វផ្សាយផ្ទាំងព័ត៌មានបញ្ឈរ (I-Stand) អំពីសេចក្តីសង្ខេប និងសមិទ្ធផលសំខាន់ៗនៃកម្មវិធីជាតិដំណាក់កាលទី១ និងកម្មវិធីជាតិដំណាក់កាលទី២<br>– អនុសាសន៍សំខាន់ៗរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល និងគណៈកម្មាធិការជាតិនៃកំណែទម្រង់ស្ថាប័ននានារបស់រាជរដ្ឋាភិបាល<br>– បោះពុម្ពប្រតិទិន និងសៀវភៅទិនានុលេខន៍ប្រចាំឆ្នាំ ២០២២ និងឆ្នាំ២០២៣<br>– ផលិតវីដេអូបទយកការខ្លីស្តីពីការដឹកនាំល្អរបស់មេឃុំក្នុងការផ្តល់សេវា និងអភិវឌ្ឍមូលដ្ឋាន<br>– បានរៀបចំមាតិកាខ្លីៗ (Contents) ដើម្បីផ្សព្វផ្សាយដល់សាធារណជន<br>– ផលិតវីដេអូស្តីពីសាវតារគម្រោងការធ្វើឱ្យប្រសើរនូវមូលដ្ឋានទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា<br>– វគ្គបណ្តុះបណ្តាលស្តីពីការសរសេរអត្ថបទព័ត៌មានសម្រាប់ផ្សព្វផ្សាយដល់មន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប. បង្រៀនដោយអ្នកជំនាញផ្នែកទំនាក់ទំនងមកពីស្នាក់ការកណ្តាលរបស់ GIZ។ |
| 1.2.3 | ការវាស់វែងលទ្ធផលនៃការប្រាស្រ័យទាក់ទង | 15. ការអង្កេតអំពីលទ្ធផលនៃការប្រាស្រ័យទាក់ទង | ការអង្កេត | 1 | មិនបានអនុវត្ត | |
| 1.3.1 | ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការអនុវត្តដំណាក់កាលនីមួយៗនៃកជទី២ | 16. ផអ៥ទី១នៃ កជទី២បានរៀបចំ និងអនុម័ត | ផែនការ | 1 | បានបញ្ចប់ | កជទី២ (២០២១-២០៣០) ត្រូវបានប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដោយមានការចូលរួមពីក្រសួង ស្ថាប័ន រដ្ឋបាល |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធនានាដែលមានអ្នកចូលរួមដោយផ្ទាល់ប្រមាណជាង ៤០០នាក់ និងតាមរយៈប្រព័ន្ធបញ្ជូនសំឡេង និងរូបភាពពីចម្ងាយ (Zoom) ប្រមាណជាង ៧.០០០នាក់។ |
| 1.3.2 | ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. | 17. ផ.ស.ថ. ឆ្នាំ២០២២ ត្រូវបានរៀបចំ និងអនុម័ត | ផ.ស.ថ. | 1 | បានបញ្ចប់ | – ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០២២របស់ គ.ជ.អ.ប. (ផ.ស.ថ.) ត្រូវបានរៀបចំឡើងដោយការដាក់បញ្ចូលនូវផែនការសកម្មភាព និងថវិការបស់ក្រសួង ស្ថាប័នអនុវត្តនីមួយៗ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងដោយមានការពិភាក្សា និងពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា។ ផ.ស.ថ. ឆ្នាំ២០២២ ត្រូវបានផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តដោយសម្រេចបានលទ្ធផលសំខាន់ៗ និងបញ្ហាប្រឈមនានាដូចមានកំណត់ក្នុងរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០២២។<br>– ទន្ទឹមនេះ របាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមប្រចាំឆ្នាំ២០២១ស្តីពីការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប. ត្រូវបានរៀបចំ និងអនុម័តនាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ និងបានផ្សព្វផ្សាយ។ |
| | | 18. ភាគរយលទ្ធផលរំពឹងទុកនៃ ផ.ស.ថ. ដែលបានសម្រេច | លទ្ធផលរំពឹងទុក | 80% | បានបញ្ចប់ | សកម្មភាពអាទិភាពចំនួន៧៣ ត្រូវបានអនុវត្តចប់តាមផែនការប្រចាំឆ្នាំ ស្មើនឹង ៨៦ % នៃសកម្មភាពអាទិភាពសរុបចំនួន៨៥ នៃ ផ.ស.ថ. ឆ្នាំ២០២២របស់ គ.ជ.អ.ប.។ |
| | | 19. ចំនួនសេចក្តីសម្រេចរួមដែលបានរៀបចំ និងអនុម័ត | សេចក្តីសម្រេចរួម | 45 | បានបញ្ចប់ | សេចក្តីសម្រេចរួមឆ្នាំ២០២២ រវាង គ.ជ.អ.ប. ជាមួយក្រសួង ស្ថាប័នចំនួន១៧ និងជាមួយរដ្ឋបាលរាជធានី ខេត្តចំនួន២៥ ត្រូវបានរៀបចំ និងអនុម័ត |
| | | 20. ចំនួនកិច្ចព្រមព្រៀងជាមួយគម្រោង និងកម្មវិធីនានា | កិច្ចព្រមព្រៀង | 13 | បានបញ្ចប់ | លេខាធិការដ្ឋាន គ.ជ.អ.ប. បានសម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធរៀបចំឯកសារទស្សនទានចំនួន០៧ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | ពាក់ព័ន្ធនឹងការបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់ដៃគូអភិវឌ្ឍន៍ ដូចជា UNDP, GGGI, UNCDF និង IFAD ត្រូវបានសម្របសម្រួលរៀបចំ និងដាក់ជូនមូលនិធិអាកាសធាតុបៃតង (GCF) ដើម្បីស្នើសុំការគាំទ្រមូលនិធិ។ |
| 1.3.3 | ការរៀបចំ និងដាក់បញ្ចូលកិច្ចការ ឬគម្រោងនានានៃកជទី២ ទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័នអនុវត្តនីមួយៗ | 21. ចំនួនស្ថាប័នបានបញ្ចូលសកម្មភាពនៃកជទី២ក្នុង ផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន | ផែនការ | 45 | បានបញ្ចប់ | – លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនានានៃ កជទី២ ត្រូវបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤ របស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងរាជធានី ខេត្តទាំងអស់២៥<br>– ផ.ស.ថ. ឆ្នាំ២០២២របស់ក្រសួង ស្ថាប័ន និងរដ្ឋបាល ថ្នាក់ក្រោមជាតិស្ដីពីការអនុវត្ត កជទី២ត្រូវបានអនុម័ត និងអនុវត្ត |
| 1.3.4 | ការរៀបចំគម្រោងនានាដែលគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ ឬអង្គការសង្គមស៊ីវិលនានាដោយបន្ស៊ីជាមួយកជទី២ | 22. ចំនួនដៃគូអភិវឌ្ឍន៍ ឬអង្គការសង្គមស៊ីវិលនានាដែលបានបន្ស៊ីគម្រោងរបស់ខ្លួនជាមួយកជទី២ | អង្គការ | 15 | បានបញ្ចប់ | – គម្រោង និងកម្មវិធីដាច់ដោយឡែកចំនួន១២ ដែលគ្រប់គ្រងនិងដឹកនាំសម្របសម្រួលដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបានរៀបចំតាមរយៈកិច្ចព្រមព្រៀងរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងដៃគូអភិវឌ្ឍន៍ ព្រមទាំងបានអនុវត្តដោយសម្រេចបាននូវលទ្ធផលសំខាន់ៗជាច្រើនដែលជាការរួមចំណែកដល់ការសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅនៃកជទី២។ គម្រោង និងកម្មវិធីទាំងនេះ បានផ្ដោតទៅលើការកែលម្អលក្ខខណ្ឌសេដ្ឋកិច្ចនិងសង្គមរបស់កសិករខ្នាតតូចជុំវិញបឹងទន្លេសាប ការធ្វើប្រសើរឡើងនូវការប្រើប្រាស់និងគុណភាពសេវាសុខភាពមាតា កុមារនិងអាហារូបត្ថម្ភដោយផ្ដោតលើការជំរុញឱ្យមានតម្រូវការនិងគណនេយ្យភាពនៅកម្រិតសហគមន៍ ការកសាងសមត្ថភាព កសាងហេដ្ឋារចនាសម្ព័ននិងការរៀបចំប្រព័ន្ធហិរញ្ញវត្ថុសម្រាប់វិនិយោគលើការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ នៅថ្នាក់ក្រោមជាតិ ការពង្រឹងសមត្ថភាពមន្ត្រីគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ ពង្រឹង |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | ភាពអង់អាចដល់ស្ត្រីដើម្បីសង្គមធននឹងដើម្បីជួយដល់សហគ្រិនស្ត្រីឬក្រុមកែលម្អជីវភាពដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ការកសាងភាពធនទៅនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្មតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាថាមពលពន្លឺព្រះអាទិត្យ ពង្រីកការអនុវត្តមូលនិធិធន់ទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជាតាមរយៈការដោះស្រាយផ្គត់ផ្គង់ទឹកស្អាត និងការកសាងសមត្ថភាពក្នុងការអនុវត្តមុខងារគ្រប់គ្រងទឹកស្អាតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ លើកកម្ពស់ការផ្តល់សេវានិងអភិវឌ្ឍន៍មូលដ្ឋានដោយរដ្ឋបាលថ្នាក់ក្រោមជាតិ លើកកម្ពស់ស្ត្រី កុមារ និងងាយជនរងគ្រោះ<br>ជាមួយគ្នានេះ គម្រោង/កម្មវិធីដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍បានជួយគាំទ្រដល់កម្មវិធីជាតិលើសកម្មភាពមួយចំនួនពាក់ព័ន្ធនឹងការគាំទ្រជំនួយបច្ចេកទេស ការចំណាយប្រតិបត្តិការ ការពង្រឹងសមត្ថភាព ការសិក្សា និងវាយតម្លៃសវនកម្មផ្ទៃក្រៅ រួមមានដូចជា ISAF, DAR-ISD/GIZ, NASLA/ ADB, SNIF/ADB, Readiness/GCF, LGCC-WRP, Empower, SRELFOODS ។ |
| 1.3.5 | ការរៀបចំ និងការអនុវត្តសាកល្បងនូវ គំនិតផ្តួចផ្តើមថ្មីៗ | 23. ចំនួនសរុបនៃលិខិតបទដ្ឋានស្តីពីវិមជ្ឈការ និងវិសហមជ្ឈការដែលបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 10 | បានបញ្ចប់ | – វឌ្ឍនភាពដូចក្នុងលទ្ធផល ១.១.១. ខាងលើ<br>– គម្រោងសាកល្បងដែលពាក់ព័ន្ធនឹងការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក ក្នុងការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងភាពជាដៃគូជាមួយវិស័យឯកជនត្រូវបានរៀបចំ និងអនុវត្តសាកល្បងនៅឃុំបាសាក់ ស្រុករុក្ខគិរី ខេត្តបាត់ដំបង និងកំពុងបន្តសិក្សា រៀបចំជាគម្រោងសម្រាប់ការអនុវត្តសាកល្បងនៅថ្នាក់ក្រុង ស្រុកក្នុងឆ្នាំ២០២៣។ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| 1.3.6 | ការសម្របសម្រួល ការគាំទ្រ ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្ត កជទី២ | 24. ការវាយតម្លៃការអនុវត្ត កជទី២ | ការវាយតម្លៃ | 1 | បានបញ្ចប់ | លេខាធិការដ្ឋាន គ.ជ.អ.ប. បានសម្របសម្រួល គាំទ្រ និងតាមដានការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំ២០២២ របស់ គ.ជ.អ.ប. ដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការសម្រេចបាននូវលទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនានាដែលបានគ្រោងក្នុង ផ.ស.ថ. ឆ្នាំ២០២២របស់ គ.ជ.អ.ប.។ របាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈម ស្ដីពីការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២១របស់ គ.ជ.អ.ប. ត្រូវបានរៀបចំ និងអនុម័តនាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ និងផ្សព្វផ្សាយ។ |
| | | 25. ការអង្កេតអំពីសមិទ្ធផលនានា | ការអង្កេត | 1 | មិនបានអនុវត្ត | |
| 1.4.3 | រចនាសម្ព័ន្ធ និងប្រព័ន្ធនៃក្រសួងស្ថាប័នពាក់ព័ន្ធនានាត្រូវបានកែសម្រួលដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ដល់សេវា | 26. ការពិនិត្យមើលឡើងវិញអំពីរចនាសម្ព័ន្ធ និងប្រព័ន្ធនៃក្រសួងស្ថាប័នពាក់ព័ន្ធនានា | ការសិក្សា | 1 | កំពុងដំណើរការ | ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបាននិងកំពុងពិនិត្យ និងកែសម្រួលនូវរចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធគ្រប់គ្រងរបស់ខ្លួន ដើម្បីឱ្យស្របទៅតាមមុខងារដែលបានផ្ទេរ និងមានលក្ខណៈងាយស្រួលក្នុងការផ្ដល់ការគាំទ្រ ត្រួតពិនិត្យ និងវាយតម្លៃដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស ក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច។ |
| 1.5.1 | ការពង្រឹងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 27. ការអភិវឌ្ឍសមត្ថភាពដល់សមាគមក្រុមប្រឹក្សាត្រូវបានអនុវត្ត | វគ្គ | 5 | កំពុងដំណើរការ | បានរៀបចំកិច្ចប្រជុំ ការផ្សព្វផ្សាយ និងការអភិវឌ្ឍសមត្ថភាពពាក់ព័ន្ធនឹងការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន៖<br>– កិច្ចប្រជុំក្រុមប្រឹក្សាជាតិរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដោយមានអ្នកចូលរួមសរុបចំនួន៣២១រូប ក្នុងនោះមានស្ត្រីចំនួន៧២រូប ដើម្បីពិនិត្យ និងពិភាក្សាឯកសារទស្សនទានទស្សនទានស្ដីពីកម្មវិធីពានរង្វាន់ឧត្ដមភាពការងាររៀបចំទីប្រជុំជនក្រោមការគាំទ្រពីគម្រោងពង្រឹងសមត្ថភាពអាជ្ញាធរថ្នាក់ក្រោមជាតិនៅ |

| ក្រុង | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | កម្ពុជាក្នុងការរៀបចំផែនការនគរូបនីយកម្ម និងការគ្រប់គ្រងដីធ្លី ដើម្បីកែប្រែមុខមាត់សហគមន៍មិនទាន់រៀបរយ និងធានានូវលទ្ធភាពក្នុងការទទួលបាននូវសេវាសាធារណៈជាសារវ័ន្ត<br>– កិច្ចប្រជុំថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិ ដើម្បីពិនិត្យកែសម្រួលសមាសភាពគណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារ និងការបែងចែកភារកិច្ចថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិទទួលបន្ទុកតាមរាជធានី ខេត្ត<br>– កិច្ចប្រជុំរវាងគណៈកម្មការទទួលបន្ទុកកិច្ចការស្ត្រី និងកុមាររបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសមាជិកក្រុមប្រឹក្សារាជធានី ខេត្តទាំង២៥<br>– កិច្ចប្រជុំថ្នាក់ដឹកនាំសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ដើម្បីពិនិត្យ និងពិភាក្សាលើការកែសម្រួលអង្គអភិបាលកិច្ចរបស់សមាគមសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រចាំឆ្នាំ២០២២<br>– ការផ្សព្វផ្សាយពីលទ្ធផលនៃវេទិកាថ្នាក់ខេត្តទាំង៤ (ខេត្តបាត់ដំបង ខេត្តស្វាយរៀង ខេត្តក្រចេះ និងខេត្តព្រះវិហារ) ដល់ក្រុមប្រឹក្សាជាតិរបស់សម្ព័ន្ធភាពជាតិ ដើម្បីចែករំលែកបទពិសោធន៍ល្អ និងបញ្ហាប្រឈមនានាដែលកើតមានឡើងនៅក្នុងមូលដ្ឋានសំដៅពង្រឹងការអនុវត្តតួនាទីរបស់ក្រុមប្រឹក្សា<br>– ការបណ្តុះបណ្តាលលេខាធិការសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្តស្តីពីការងារលទ្ធកម្ម និងកិច្ចការរដ្ឋបាល<br>– ការបណ្តុះបណ្តាលថ្នាក់ដឹកនាំសមាគមជាតិ និងប្រធានក្រុមប្រឹក្សារាជធានី ខេត្តអំពីខ្លឹមសារនៃអនុក្រឹត្យស្តីពី |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | បញ្ហានភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | មុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ<br>– ការរៀបចំវគ្គបណ្តុះបណ្តាលដល់គណៈកម្មការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ និងគណៈកម្មការអភិវឌ្ឍសមត្ថភាពសមាគមជាតិស្តីពីជំនាញសម្របសម្រួល ជំនាញធ្វើបទបង្ហាញ និងការនិយាយជាសាធារណៈ។ |
| 1.5.2 | ការសិក្សាអំពីជម្រើសនៃការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទី របស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 28. ការសិក្សាអំពីជម្រើសនានាត្រូវបានអនុវត្ត | ការសិក្សា | 1 | កំពុងដំណើរការ | ផ្អែកតាមសំណើរបស់សមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ លេខាធិការដ្ឋាន គ.ជ.អ.ប. កំពុងរៀបចំផែនការ និងវិធីសាស្ត្រនៃការសិក្សា វាយតម្លៃ និងកំណត់អំពីជម្រើសសមស្របនានាសម្រាប់ការកែសម្រួលរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| 1.5.4 | ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយនានាពាក់ព័ន្ធនឹងកំណែទម្រង់ | 29. ការរៀបចំលិខិបទដ្ឋានស្តីពីការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិល | លិខិតបទដ្ឋាន | 1 | កំពុងដំណើរការ | អង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា ត្រូវបានអញ្ជើញ និងលើកទឹកចិត្តក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការរៀបចំផែនការអនុវត្ត៥ឆ្នាំ ដំណាក់កាលទី១ (២០២១-២០២៥) ការរៀបចំសេចក្តីព្រាងច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃឈើ ផលផល និងតំបន់ការពារធម្មជាតិ និងបណ្តាលិខិតបទដ្ឋាននានា ឯកសារបច្ចេកទេសនានាក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ជាមួយគ្នានេះ លេខាធិការដ្ឋាន គ.ជ.អ.ប. បានសហការក្នុងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម ការពង្រឹងយន្តការសម្រុះសម្រួល និងដោះស្រាយវិវាទរដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងគម្រោង កម្មវិធីពាក់ព័ន្ធផ្សេងទៀត។ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| 2 | **រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ៖** | | | | | |
| 2.1.1 | ការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់រដ្ឋបាល ក្រុង ស្រុក | 30.ភាគរយសរុបនៃក្រុង ស្រុក ខណ្ឌដែលទទួលការគាំទ្រ និងអភិវឌ្ឍសមត្ថភាព | ក្រុង ស្រុក ខណ្ឌ | 20% | កំពុងដំណើរការ | លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមាន៖<br>– វគ្គបណ្តុះបណ្តាលអំពីការគ្រប់គ្រង តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌចំនួន២៧វគ្គ ត្រូវបានរៀបចំសម្រាប់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៧៦២នាក់ ក្នុងនោះស្ត្រីចំនួន២០៣នាក់ ដោយសាលាជាតិរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ<br>– វគ្គបណ្តុះបណ្តាលជំហានទី៤ស្តីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីការិយាល័យច្រកចេញចូលតែមួយនៅខេត្តកំពង់ធំ។ វគ្គបណ្តុះបណ្តាលអំពីបែបបទ និងនីតិវិធីផ្តល់សេវារដ្ឋបាលក្នុងវិស័យដឹកជញ្ជូនផ្លូវគោកចំនួន១៤វគ្គ ត្រូវបានរៀបចំសម្រាប់ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន១១៩គោលដៅ។ កិច្ចប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលក្នុងវិស័យចំនួន៤ រួមមាន វិស័យរ៉ែ និងថាមពល វិស័យទេសចរណ៍ វិស័យវប្បធម៌ និងវិស័យឧស្សាហកម្មត្រូវបានរៀបចំសម្រាប់មន្ត្រីការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. បានចុះពិនិត្យ និងគាំទ្រដល់ការអនុវត្តមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុកនៅរដ្ឋបាលក្រុង ស្រុកចំនួន០៣ នៃខេត្តបាត់ដំបង ក្នុងឆ្នាំ២០២២<br>– បានរៀបចំកិច្ចប្រជុំចំនួន០២លើក ដើម្បីពិភាក្សា និងរកដំណោះស្រាយនូវបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ទាំង |

| ក្មង | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | ១៤នៃខេត្តបាត់ដំបង ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធនានារួមមាន ក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ មន្ទីរអប់រំ យុវជន និងកីឡា មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មន្ទីរមុខងារសាធារណៈ រដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង ស្រុកទាំង ១៤នៃខេត្តបាត់ដំបង ដោយមានការគាំទ្រពីកម្មវិធី DAR/GIZ<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចុះសិក្សានៅរដ្ឋបាលក្រុង ស្រុកមួយចំនួន ដើម្បីស្វែងយល់ និងគិតគូរអំពីការផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារទាំង៥៥ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. បានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការចុះទៅសិក្សា និងរៀបចំលិខិតបទដ្ឋានសម្រាប់ផ្ទេរទ្រព្យសម្បត្តិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមមុខងារដែលបានផ្ទេរ<br>– ក្រសួងបរិស្ថាន និងក្រសួងសាធារណការនិងដឹកជញ្ជូន បានចុះទៅផ្សព្វផ្សាយ និងណែនាំអនុវត្តនូវមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>– ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងកម្មវិធីការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា(ISD/GIZ) បានផ្តល់ការគាំទ្រ និងតាមដានការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក ដូចជាការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៣-២០២៥) ការរៀបចំ និងការអនុវត្តមុខងារក្នុងវិស័យអប់រំ សុខាភិបាល ការគ្រប់គ្រងសំរាម សំណល់រឹងនៅទីប្រជុំជន និងការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក និងឃុំ សង្កាត់ ឆ្នាំ២០២២ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | – លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងសិក្សា និងកំណត់នូវមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសរបស់រដ្ឋបាលក្រុង ស្រុក<br>– ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងរៀបចំ និងកែសម្រួលឡើងវិញនូវសេចក្តីណែនាំស្តីពីកិច្ចការរដ្ឋបាលក្រុង ស្រុក។ |
| 2.1.2 | ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាលឃុំ សង្កាត់ | 31. ភាគរយសរុបនៃឃុំ សង្កាត់ដែលទទួលការគាំទ្រ និងអភិវឌ្ឍសមត្ថភាព | ឃុំ សង្កាត់ | 5% | កំពុងដំណើរការ | ក្រសួង ស្ថាប័នពាក់ព័ន្ធបានផ្តល់ការគាំទ្រ និងពង្រឹងការអនុវត្តមុខងាររបស់រដ្ឋបាលឃុំ សង្កាត់តាមរយៈ៖<br>– ក្រសួងមហាផ្ទៃបានផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលឃុំ សង្កាត់ទាំងអស់ចំនួនប្រមាណ៨៩២.១៣៣លានរៀល (ស្មើនឹងប្រមាណជាង ២១៧លានដុល្លារ) ក្នុងឆ្នាំ២០២២<br>– យន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលឃុំ សង្កាត់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តតាមរយៈសេចក្តីណែនាំលេខ ០១៨ សនណ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវារដ្ឋបាលនៅថ្នាក់ឃុំ សង្កាត់<br>– ការរៀបចំឱ្យមានមន្ត្រីជំនួយការហិរញ្ញវត្ថុនៅថ្នាក់ឃុំ សង្កាត់ទូទាំងប្រទេស ដើម្បីជួយគាំទ្រដល់ការរៀបចំការគ្រប់គ្រង និងការប្រើប្រាស់ហិរញ្ញវត្ថុនៅថ្នាក់ឃុំ សង្កាត់ (ប្រកាសអន្តរក្រសួងលេខ០០២ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២ ស្តីពីការជ្រើសរើស |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | ចង្អុលភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | ការកំណត់តួនាទី និងភារកិច្ចរបស់ជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់)<br>– រដ្ឋបាលរាជធានី ខេត្តបានផ្តល់ការគាំទ្របច្ចេកទេសដល់រដ្ឋបាលឃុំ សង្កាត់ក្នុងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលឃុំ សង្កាត់ និងការរៀបចំគម្រោងឃុំ សង្កាត់<br>– ការរៀបចំ និងដាក់ឱ្យអនុវត្តនូវកម្មវិធីជ័យលាភីពានរង្វាន់សេវាសង្គមសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដោយក្រសួងមហាផ្ទៃ ដែលក្នុងនោះរដ្ឋបាលខេត្តចំនួន០២ (ខេត្តសៀមរាប និងខេត្តកណ្តាល) រដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន០៣ (រដ្ឋបាលក្រុងតាខ្មៅ រដ្ឋបាលខណ្ឌមានជ័យ និងរដ្ឋបាលខណ្ឌកំបូល) និងរដ្ឋបាលឃុំ សង្កាត់មានចំនួន០៥ (សង្កាត់បឹងកេងកងទី១ ឃុំបាគង ឃុំបន្សាយត្រែង សង្កាត់បឹងកេងកងទី២ សង្កាត់ឡាបានសៀក) ទទួលបានពានរង្វាន់ជើងឯកសេវាសង្គម និងរដ្ឋបាលរាជធានី ខេត្តចំនួន០៧ រដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន៦១ រដ្ឋបាលឃុំ សង្កាត់ចំនួន៤១៧ ទទួលបានពានរង្វាន់ផ្កាយសេវាសង្គម<br>– សម្ព័ន្ធភាពជាតិ និងសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមខេត្តបានជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់តាមរយៈ (១). ការបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អំពីការកសាងផែនការនៅខេត្តកំពង់ចាម (២). ការបណ្តុះបណ្តាល គ.ក.ន.ក. អំពីការរៀបចំផែនការសេវាសង្គមនៅខេត្តបាត់ដំបង (៣). ការបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាជាស្ត្រីអំពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | នៅខេត្តស្វាយរៀង (៤). ការបណ្តុះបណ្តាលបេក្ខនារីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ អំពីការនិយាយជាសាធារណៈ និងការកសាងផែនការឃោសនាបោះឆ្នោតនៅខេត្តកែប ខេត្តកំពត ខេត្តកំពង់ឆ្នាំង ខេត្តសៀមរាប និងខេត្តព្រៃវែង និង(៥). ការកសាងសមត្ថភាពសមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់តាមរយៈការជួបពិគ្រោះយោបល់ និងការបង្ហាត់បង្ហាញដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ផ្ទាល់។ |
| 2.2.1 | ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលខេត្តក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់ | 32. ការសិក្សាត្រូវបានអនុវត្ត | ការសិក្សា | 1 | មិនបានអនុវត្ត | |
| 2.5.1 | ការកែសម្រួល និងការបង្កើតគណៈកម្មាធិការនានាបន្ថែមទៀតរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ | 33. ការសិក្សាអំពីការកែសម្រួល និងការបង្កើតគណៈកម្មាធិការនានាបន្ថែមទៀតរបស់ក្រុមប្រឹក្សា | ការសិក្សា | 1 | មិនបានអនុវត្ត | |
| 2.5.2 | ការពង្រឹងលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 34. ការអភិវឌ្ឍសមត្ថភាពដែលបានអនុវត្ត | វគ្គ | | កំពុងដំណើរការ | វគ្គបណ្តុះបណ្តាលដល់លេខាធិការដ្ឋានក្រុមប្រឹក្សា ត្រូវបានអនុវត្តរួមគ្នាជាមួយកម្មវិធីអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត ដែលក្នុងឆ្នាំ២០២២នេះ រដ្ឋបាលរាជធានី ខេត្ត បានសម្របសម្រួល និងរៀបចំវគ្គបណ្តុះបណ្តាលចំនួន៨០វគ្គ ដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិចំនួនប្រមាណ១.៧០០នាក់។ |
| 2.5.3 | ការរៀបចំកញ្ចប់ថវិកាជាក់លាក់សម្រាប់គាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 35. លិខិតបទដ្ឋានស្តីពីការបែងចែកថវិកាសម្រាប់គាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | លិខិតបទដ្ឋាន | 1 | មិនបានអនុវត្ត | |
| 2.6.1 | ការពង្រឹងយន្តការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ | 36. ការសិក្សាអំពីជម្រើសនានាក្នុងការបង្កើតយន្តការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ | ការសិក្សា | 1 | បានបញ្ចប់ | ការងារគណនេយ្យភាពសង្គមត្រូវបានពង្រីក និងដាក់ឱ្យអនុវត្តនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន១៧៣ រដ្ឋបាលឃុំ សង្កាត់ចំនួន១.៤១៣ សាលាបឋមសិក្សាចំនួន៦.២៣១ និងមណ្ឌលសុខភាពចំនួន ១.១១០ ក្នុងរាជធានី ខេត្តទាំង២៤ ក្នុងនោះធនាគារ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | បច្ចុប្បន្នភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | ពិភពលោកបានផ្តល់ការគាំទ្រការអនុវត្តនៅថ្នាក់ក្រុង ស្រុកចំនួន ៥៥ និងឃុំ សង្កាត់ចំនួន៤៦៥ ក្នុងខេត្តចំនួន១០ ក្រៅពីនេះជាការគាំទ្រដោយថវិការបស់រដ្ឋបាលរាជធានី ខេត្ត។<br>ទិន្នន័យព័ត៌មានស្តីពីលទ្ធផលការងាររបស់អង្គភាពផ្តល់សេវាទាំង៣ រួមមាន រដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាពត្រូវបានបញ្ចូលក្នុងប្រព័ន្ធទិន្នន័យបានចំនួន៩៨% និងបានផ្សព្វផ្សាយជូនប្រជាពលរដ្ឋតាមរយៈការបិទផ្សាយជាផ្ទាំងព័ត៌មាន (I4Cs) កម្មវិធីទូរស័ព្ទដៃ (Mobile App) ការចាក់ផ្សាយតាមប្រព័ន្ធឧឃោសនស័ព្ទ ការប្រជុំផ្សព្វផ្សាយ និងតាមប្រព័ន្ធទំនាក់ទំនងសង្គមផ្សេងៗទៀត។ ទន្ទឹមនឹងនេះ មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន២.៥៣៤រូប (ស្ត្រីចំនួន៥១២រូប) បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម។ សកម្មភាពជាអាទិភាពចំនួន៤.៩១៦ (ស្មើនឹង៤៦%) នៃផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (ខែសីហា ឆ្នាំ២០២២ ដល់ខែកក្កដា ឆ្នាំ២០២៣) ត្រូវបានអនុវត្ត។ សកម្មភាពទាំងនេះត្រូវបានអនុវត្តក្នុងភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិលនានារួមមានៈ អង្គការទស្សនពិភពលោក (World Vision) អង្គការអុកស្វាមកម្ពុជា (Oxfam Cambodia) អង្គការឃែរអន្តរជាតិប្រចាំកម្ពុជា (Care Cambodia) និងអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360)។ ប្រជាពលរដ្ឋប្រមាណជាង ៥៩២.០០០នាក់ (ស្ត្រីចំនួន៣៤២.០០០នាក់) បានចូលរួមយ៉ាងសកម្មក្នុងកិច្ចដំណើរការអនុវត្តការងារគណនេយ្យភាពសង្គម តាមរយៈការចូលរួមផ្សព្វផ្សាយអំពីកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ កិច្ចប្រជុំដាក់ពិន្ទុសហគមន៍ និងកិច្ចប្រជុំរួម ដើម្បីកំណត់អាទិភាពតាមវិស័យនីមួយៗ។ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| 2.6.2 | ការពង្រឹងយន្តការសម្រាប់ទទួលការដាក់សំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ | 37. ភាគរយបណ្តឹងរបស់ប្រជាពលរដ្ឋត្រូវបានសម្រុះសម្រួលដោះស្រាយដោយការិយាល័យប្រជាពលរដ្ឋ ប្រចាំត្រីមាស (គិតជាមធ្យម) | បណ្តឹង | 80% | បានបញ្ចប់ | សកម្មភាពនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖<br>– ការរៀបចំការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់មន្ត្រីការិយាល័យប្រជាពលរដ្ឋចំនួន០៣លើក អំពីតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់ការិយាល័យប្រជាពលរដ្ឋ<br>– បានដាក់ចេញសៀវភៅណែនាំស្តីពីការស៊ើបអង្កេតបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងបានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្តស្តីពីបច្ចេកទេសស៊ើបអង្កេតបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋ។<br>– ការរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងនៅរដ្ឋបាលរាជធានី ខេត្តចំនួន០៣ (រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តកំពង់ចាម) រដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន០៨ និងរដ្ឋបាលឃុំ សង្កាត់ចំនួន៣០ នូវកម្មវិធីតាមទូរស័ព្ទដៃ (មតិយើង) សម្រាប់ប្រជាពលរដ្ឋផ្តល់ព័ត៌មាន មតិយោបល់ និងដាក់ពាក្យបណ្តឹងនានាពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរដ្ឋបាល និងការផ្តល់សេវាសាធារណៈ ដែលជាសមត្ថកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋ<br>– ការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រាជធានី ខេត្តបានទទួលបណ្តឹង និងព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋសរុបចំនួន៦២១ករណី ក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចមានចំនួន៣៩២ករណី (បញ្ចប់ការដោះស្រាយចំនួន៣៣២ករណី កំពុងដោះស្រាយចំនួន៦០ករណី) បណ្តឹងក្រៅសមត្ថកិច្ចចំនួន១០៧ករណី និងព័ត៌មានផ្សេងៗចំនួន១២២ករណី (ការសរសើរចំនួន២០ករណី សំណូមពរ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | ចំនួន៣៤ករណី និងការសាកសួរព័ត៌មានចំនួន៦៨ ករណី)<br>– ការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក ខណ្ឌបាន ទទួលបណ្តឹង និងព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋបាន សរុបចំនួន៦.៣៨៥ករណី ក្នុងនោះបណ្តឹងក្នុងសមត្ថ កិច្ចមានចំនួន១៤០ ករណី (បញ្ចប់ការដោះស្រាយ ចំនួន១៣៣ករណី កំពុងដោះស្រាយចំនួន០៧ករណី) បណ្តឹងក្រៅសមត្ថកិច្ចចំនួន៦៦ករណី ព័ត៌មានផ្សេងៗ សរុបចំនួន៦.១៧៩ករណី (ការសរសើរមាន១៤៤ ករណី សំណូមពរមានចំនួន៤៧៥ករណី ការសាកសួរ ព័ត៌មានចំនួន៥.៥៦០ករណី)<br>– ក្រុមការងារទទួល និងដោះស្រាយបណ្តឹងនៃ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបានបង្កើតនៅខែមីនា ឆ្នាំ២០២២ ដើម្បីទទួល និងដោះស្រាយបណ្តឹងនានា ពាក់ព័ន្ធនឹងការអនុវត្តគម្រោង កម្មវិធីគាំទ្រដោយដៃគូ អភិវឌ្ឍន៍ក្នុងក្របខ័ណ្ឌកំណែទម្រង់វិមជ្ឈការ និងវិសហ មជ្ឈការ។ |
| 2.6.3 | ការលើកកម្ពស់ការចូលរួមរបស់អង្គការ សង្គមស៊ីវិលនៅក្នុងកិច្ចដំណើរការចូលរួម របស់ប្រជាពលរដ្ឋ | 38. ភាគរយសរុបរាជធានី ខេត្ត បានរៀបចំ វេទិកា ឬកិច្ចប្រជុំសម្របសម្រួល ជាមួយ អង្គការសង្គមស៊ីវិល | រាជធានីខេត្ត | 60% | កំពុងដំណើរការ | សកម្មភាពនេះ សម្រេចបានលទ្ធផលដូចខាងក្រោម ៖<br>– អង្គការសង្គមស៊ីវិលចំនួន៣២ បានចូលរួមអនុវត្តការងារ គណនេយ្យភាពសង្គមផ្នែកតម្រូវការ (Demand Side) ដើម្បីពង្រឹងសិទ្ធិអំណាច និងការចូលរួមរបស់ប្រជា ពលរដ្ឋក្នុងកិច្ចដំណើរការផ្តល់សេវាសាធារណៈ និងការ អភិវឌ្ឍមូលដ្ឋាន<br>– ក្រសួងមហាផ្ទៃបានសហការជាមួយអង្គការតម្លាភាព អន្តរជាតិកម្ពុជា (TI) ក្នុងការពង្រឹងតួនាទី ភារកិច្ច និង ការទទួលខុសត្រូវរបស់ការិយាល័យប្រជាពលរដ្ឋដែល |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | ជាយន្តការទទួល និងដោះស្រាយបណ្តឹងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>– រដ្ឋបាលថ្នាក់ក្រោមជាតិបានបង្កលក្ខណៈ និងលើកទឹកចិត្តដល់អង្គការសង្គមស៊ីវិលពាក់ព័ន្ធនានាក្នុងការចូលរួមក្នុងវេទិកាសាធារណៈនានា ដែលរៀបចំឡើងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| 2.7.2 | ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 39. ការសិក្សា និងរៀបចំគំរូស្តង់ដារដ្ឋាភិបាលឌីជីថលនៅថ្នាក់ក្រោមជាតិ | ការសិក្សា | 1 | កំពុងដំណើរការ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធឌីជីថលត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាជំហានៗក្នុងនោះរួមមាន៖<br>– ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS)នៅថ្នាក់រាជធានី ខេត្តទាំង២៥<br>– ប្រព័ន្ធពិនិត្យតាមដានការអនុវត្តសកម្មភាពការងារគណនេយ្យភាពសង្គម (ISAF, M&E Database System)<br>– ប្រព័ន្ធទូទាត់វិក្កយបត្រ (Payment Hub) នៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត។ |
| 2.7.3 | ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | 40. ភាគរយរាជធានីខេត្ត បានរៀបចំ និងផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (គិតជាមធ្យម) | រាជធានីខេត្ត | 80% | កំពុងដំណើរការ | ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋត្រូវបានរៀបចំឡើងតាមរយៈ៖<br>– យន្តការគណនេយ្យភាពសង្គម លេខាធិការដ្ឋាន គ.ជ.អ.ប.បានបង្កើតឡើងកម្មវិធីតាមទូរស័ព្ទដៃ (Mobile App) ដើម្បីបង្កលក្ខណៈងាយស្រួលឱ្យប្រជាពលរដ្ឋអាចទទួលបានព័ត៌មានអំពីសេវាសាធារណៈនានាពាក់ព័ន្ធនឹងរដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាព<br>– ក្រសួងមហាផ្ទៃ បានរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងនៅរដ្ឋបាលរាជធានី ខេត្តចំនួន០៣ (រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តកំពង់ចាម) រដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន០៨ និងរដ្ឋបាលឃុំ សង្កាត់ចំនួន៣០ នូវកម្ម |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | បញ្ហានភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | វិធីទូរស័ព្ទដៃ (មតិយើង) សម្រាប់ប្រជាពលរដ្ឋផ្តល់ព័ត៌មាន មតិយោបល់ និងដាក់ពាក្យបណ្តឹងនានាពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរដ្ឋបាល និងការផ្តល់សេវាសាធារណៈ<br>– រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំគេហទំព័រ បណ្តាញទំនាក់ទំនងសង្គម ក្រុមតេឡេក្រាម ដើម្បីផ្សព្វផ្សាយព័ត៌មាន និងទទួលមតិយោបល់ត្រឡប់ពីប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ |
| 2.8.1 | ការពង្រឹងយន្តការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 41. លិខិតបទដ្ឋានស្តីពីការពង្រឹងយន្តការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | លិខិតបទដ្ឋាន | 1 | កំពុងដំណើរការ | លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងសិក្សារៀបចំនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងត្រៀមធ្វើការបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងឆ្នាំ២០២៣។ |
| 3 | **ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ៖** | | | | | |
| 3.1.1 | ការពិនិត្យ និងកែសម្រួលអង្គមន្ត្រីរាជការ | 42. លិខិតបទដ្ឋានស្តីពីអង្គមន្ត្រីរាជការត្រូវបានរៀបចំ និងអនុវត្ត | លិខិតបទដ្ឋាន | 1 | កំពុងដំណើរការ | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីអង្គរដ្ឋបាលត្រូវបានរៀបចំឡើងក្នុងដំណាក់កាលនៃការអនុវត្តផែនការអនុវត្តរយៈពេល៣ឆ្នាំដំណាក់កាលទី៣នៃកជ១។ ក្នុងឆ្នាំ២០២២មកនេះ សេចក្តីព្រាងព្រះរាជក្រឹត្យនេះក៏ត្រូវបានបន្តពិនិត្យ និងកែសម្រួលដោយក្រសួងមុខងារសាធារណៈ។ |
| 3.2.1 | ការរៀបចំការពិពណ៌នាមុខតំណែងរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 43. លិខិតបទដ្ឋានស្តីពីការពិពណ៌នាមុខតំណែងរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 1 | កំពុងដំណើរការ | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងឯកសារពិពណ៌នាមុខតំណែង (មុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈ) សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងនោះចំនួនមុខតំណែងត្រូវបានកំណត់ឡើងដូចខាងក្រោម៖ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | – សម្រាប់រដ្ឋបាលស្រុកមានចំនួន៨៥មុខតំណែង (មុខតំណែងគ្រប់គ្រងចំនួន៣១ និងមុខតំណែងវិជ្ជាជីវៈចំនួន៥៤)<br>– សម្រាប់រដ្ឋបាលក្រុងមានចំនួន៨៦មុខតំណែង (មុខតំណែងគ្រប់គ្រងចំនួន៣១ និងមុខតំណែងវិជ្ជាជីវៈចំនួន៥៥)<br>– សម្រាប់រដ្ឋបាលខណ្ឌមានចំនួន៨១មុខតំណែង (មុខតំណែងគ្រប់គ្រងចំនួន២៧ និងមុខតំណែងវិជ្ជាជីវៈចំនួន៥៤)។ |
| 3.2.2 | ការពង្រឹងការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 44. លិខិតបទដ្ឋានស្តីពីលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 1 | កំពុងដំណើរការ | រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗបានរៀបចំ និងអនុវត្តនូវលក្ខខណ្ឌការងារសម្រាប់បុគ្គលិកម្នាក់ៗប្រចាំឆ្នាំតាមគោលការណ៍ និងនីតិវិធីជាធរមាន។ លក្ខខណ្ឌការងារទាំងនេះនឹងត្រូវពិនិត្យកែសម្រួលឡើងវិញដោយផ្អែកទៅលើការពិពណ៌នាមុខតំណែង ដែលនឹងត្រូវដាក់ចេញដូចមានកំណត់ក្នុងសកម្មភាពទី២នៃសមាសភាគនេះ។ |
| 3.2.3 | ការពង្រឹងការគ្រប់គ្រងវត្តមានបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 45. ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិបានពង្រឹងការគ្រប់គ្រងវត្តមានបុគ្គលិក (គិតជាមធ្យម) | រដ្ឋបាលថ្នាក់ក្រោមជាតិ | 70% | កំពុងដំណើរការ | – រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗបានពង្រឹងការគ្រប់គ្រងបុគ្គលិករបស់ខ្លួនតាមរយៈការចុះបញ្ជីវត្តមានប្រចាំថ្ងៃនៅតាមអង្គភាពនីមួយៗ។ |
| 3.2.4 | ការរៀបចំក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 46. លិខិតបទដ្ឋានស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 1 | កំពុងដំណើរការ | រដ្ឋបាលថ្នាក់ក្រោមជាតិបានបន្តពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គ្រូបង្រៀន និងគ្រូពេទ្យដែលបានផ្ទេរមកឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ចំពោះក្រមសីលធម៌សម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀតនឹងត្រូវរៀបចំ និងដាក់ឱ្យអនុវត្តនៅឆ្នាំ២០២៣។ |
| 3.2.5 | ការលើកកម្ពស់ការតាមដាន និង ការវាយតម្លៃលើការបំពេញការងារ | 47. លិខិតបទដ្ឋានស្តីពីការវាយតម្លៃផ្អែកលើសមិទ្ធកម្មត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 1 | កំពុងដំណើរការ | សេចក្តីព្រាងអនុក្រឹត្យ និងសេចក្តីណែនាំស្តីពីការវាយតម្លៃផ្អែកលើសមិទ្ធកម្មត្រូវបាន និងកំពុងរៀបចំដោយក្រសួងមុខងារសាធារ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | ណៈ ដើម្បីជាមូលដ្ឋានសម្រាប់ការវាយតម្លៃទៅលើការបំពេញការងាររបស់បុគ្គលិកប្រចាំឆ្នាំ។ |
| 3.2.6 | ការផ្ដល់ការលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមលទ្ធផលនៃការវាយតម្លៃការងារ | 48. លិខិតបទដ្ឋានស្ដីពីការផ្ដល់ការលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 1 | មិនបានអនុវត្ត | |
| 3.3.1 | ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ | 49. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | ប្រព័ន្ធ | 1 | កំពុងដំណើរការ | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មាន ទិន្នន័យបុគ្គលិក ការជ្រើសរើស ការត្រួតពិនិត្យវាយតម្លៃ ការបំពេញការងារ សម្រាប់ដំឡើងថ្នាក់ ឋានន្តរសក្តិ ការតែងតាំងមុខតំណែង ការដាក់ពិន័យ ការចូលនិវត្ត និងការគ្រប់គ្រងផ្សេងៗទៀតត្រូវបាននិងកំពុងសិក្សា និងរៀបចំដោយក្រសួងមុខងារសាធារណៈ។ |
| 3.4.3 | ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 50. ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំ ( គិតជាមធ្យម ) | រដ្ឋបាលថ្នាក់ក្រោមជាតិ | 70% | បានបញ្ចប់ | រដ្ឋបាលរាជធានី ខេត្តទាំងអស់បានរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់ខ្លួនតាមគោលការណ៍ បែបបទ និងនីតិវិធីជាធរមាន។ |
| 3.5.1 | ការសិក្សាអំពីជម្រើសនានាសម្រាប់ផ្ដល់ការលើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | 51. ការសិក្សាអំពីជម្រើសនានាសម្រាប់ផ្ដល់ការលើកទឹកចិត្តដល់បុគ្គលិកត្រូវបានអនុវត្ត | ការសិក្សា | 1 | មិនបានអនុវត្ត | |
| 3.5.4 | ការលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | 52. ផែនការយុទ្ធសាស្ត្រស្ដីពីការលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | ផែនការ | 1 | កំពុងដំណើរការ | ផែនការយុទ្ធសាស្ត្រស្ដីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិកំពុងដំណើរការពិនិត្យ និងកែសម្រួលក្រោមការដឹកសម្របសម្រួលរៀបចំដោយក្រសួងកិច្ចការនារី និងលេខាធិការដ្ឋាន គ.ជ.អ.ប.។<br>គិតមកដល់ចុងឆ្នាំ២០២២នេះ ចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រេចបានដូចខាងក្រោម៖<br>– មុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត ចំនួន ៧៦នាក់ ស្មើនឹង ១២.១២% |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | បច្ចុប្បន្នភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | – មុខតំណែងគ្រប់គ្រងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំនួន៧៦៦នាក់ ស្មើនឹង១៩.៥២%<br>– មុខតំណែងគ្រប់គ្រងនៅរដ្ឋបាលឃុំ សង្កាត់ រួមមានមេឃុំ ចៅសង្កាត់មានចំនួន១៧៣នាក់<br>– ស្មើនឹង១០.៤៧% ជំទប់ទី១មានចំនួន៣១៩ ស្មើ១៩.៣១% ជំទប់ទី២មានចំនួន១៨៩ ស្មើ១១.៤៤%។ |
| 3.6.1 | ការពិនិត្យ និងការកែសម្រួលនូវឧបករណ៍ និងវិធីសាស្ត្រវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 53. លិខិតបទដ្ឋានស្តីពីឧបករណ៍ និងវិធីសាស្ត្រ នៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 1 | កំពុងដំណើរការ | វិធីសាស្ត្រ និងឧបករណ៍សម្រាប់ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិកំពុងដំណើរការពិនិត្យ និងកែសម្រួលដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន។ |
| 3.6.2 | ការពង្រឹងសមត្ថភាពដល់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តអំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព | 54. ភាគរយសរុបនៃអង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តទទួលបានការបណ្តុះបណ្តាលអំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព | សកម្មភាព | 70% | បានបញ្ចប់ | អង្គភាពអភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត ទទួលបានការណែនាំពីសាលាជាតិរដ្ឋបាលមូលដ្ឋានអំពីការរៀបចំវាយតម្លៃលើតម្រូវការអភិវឌ្ឍសមត្ថភាពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ |
| 3.6.3 | ការរៀបចំការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 55. លិខិតបទដ្ឋានស្តីពីការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិកត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 1 | កំពុងដំណើរការ | រដ្ឋបាលរាជធានី ខេត្តបានរៀបចំការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពសម្រាប់បុគ្គលិកដែលបំពេញការងារនៅក្នុងរដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជាទៀងទាត់ប្រចាំឆ្នាំ។ |
| 3.6.4 | ការរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមតម្រូវការអភិវឌ្ឍសមត្ថភាព | 56. ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិ បានរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំ ២០២៣ | រដ្ឋបាលថ្នាក់ក្រោមជាតិ | 80% | បានបញ្ចប់ | រដ្ឋបាលរាជធានី ខេត្តទាំងអស់កំពុងដំណើរការរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំ២០២៣របស់ខ្លួន ដោយរួមបញ្ចូលនូវសកម្មភាពអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ |
| 3.7.1 | ការជ្រើសរើស និងការពង្រឹងសមត្ថភាពបុគ្គលិកនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន | 57. ភាគរយបុគ្គលិកសាលាជាតិរដ្ឋបាលមូលដ្ឋានដែលបានជ្រើសរើសធៀបនឹងផែនការ | បុគ្គលិក | 50% | បានបញ្ចប់ | ក្រសួងមហាផ្ទៃបានចាត់តាំង និងរៀបចំបុគ្គលិកបំពេញការងារនៅតាមនាយកដ្ឋានទាំង០៤នៃសាលាជាតិរដ្ឋបាលមូលដ្ឋានដែលមានចំនួន៨២នាក់ ស្ត្រីចំនួន២៩នាក់ និងត្រៀមផ្តល់ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីទាំងនោះ។ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| 3.7.2 | កិច្ចសហការជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ និងឯកជន និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីរៀបចំ និងអនុវត្តការបណ្តុះបណ្តាល | 58. បញ្ជីក្រសួង ស្ថាប័ន គ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន វិស័យឯកជន ដៃគូអភិវឌ្ឍន៍ អង្គការ សង្គមស៊ីវិល ដែលអាចផ្តល់ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | បញ្ជី | 1 | កំពុងដំណើរការ | សាលាជាតិរដ្ឋបាលមូលដ្ឋានបានសហការជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលមួយចំនួនដូចជា សាលាភូមិន្ទរដ្ឋបាល វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកិច្ចការនារី លេខាធិការដ្ឋាន គ.ជ.អ.ប. ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលមួយចំនួនដូចជា GIZ, UNDP, KOICA, ADB, UNPOG, CDRI, WaterSHED, TI Cambodia ក្នុងការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| 3.7.3 | ការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមគោលដៅផ្សេងៗ | 59. ភាគរយសរុបសកម្មភាពអភិវឌ្ឍសមត្ថភាពរបស់សាលាជាតិរដ្ឋបាលមូលដ្ឋានដែលបានអនុវត្តធៀបនឹងផែនការ | សកម្មភាព | 70% | បានបញ្ចប់ | សាលាជាតិរដ្ឋបាលមូលដ្ឋានបានសម្របសម្រួល និងរៀបចំវគ្គបណ្តុះបណ្តាលចំនួន២៧វគ្គដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៧៦២នាក់ ស្ត្រីចំនួន២០៣នាក់ ដូចជា៖<br>– វគ្គវិក្រឹត្យការជំនាញគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់<br>– វគ្គអន្តរាគមន៍អភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>– វគ្គវិក្រឹត្យការមូលដ្ឋាន<br>– វគ្គលេខាធិការរដ្ឋបាល<br>– វគ្គភាពជាអ្នកដឹកនាំជាស្ត្រីជំនាន់ទី០៣<br>– វគ្គមុខងារគ្រប់គ្រងសុខាភិបាល<br>– វគ្គកម្មវិធីអប់រំភាពជាអ្នកដឹកនាំ។<br>ទន្ទឹមនេះ រដ្ឋបាលរាជធានី ខេត្តបានសម្របសម្រួល និងរៀបចំវគ្គបណ្តុះបណ្តាលចំនួន៨០វគ្គដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិចំនួនប្រមាណ១.៧០០នាក់ ដោយផ្តោតលើប្រធានបទសំខាន់ៗមានដូចជា៖<br>– ការងារគណនេយ្យភាពសង្គម<br>– ការគ្រប់គ្រងធនធានមនុស្ស<br>– ការកសាងផែនការ និងការរៀបចំថវិកា |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | – សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម<br>– ភាពជាអ្នកដឹកនាំ<br>– ការរៀបចំ និងការអនុវត្តផែនការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈនៃបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ<br>– កិច្ចដំណើរការ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ។ |
| 3.8.1 | ការជ្រើសរើសស្ថាប័នអភិវឌ្ឍសមត្ថភាព ស្ថាប័នជំនាញវិជ្ជាជីវៈ និងអ្នកជំនាញវិជ្ជាជីវៈ ដើម្បីចូលរួមរៀបចំកម្មវិធីសិក្សា និងឯកសារសម្ភារៈបណ្តុះបណ្តាល | 60. បញ្ជីស្ថាប័នអភិវឌ្ឍន៍សមត្ថភាព រួមទាំងស្ថាប័នជំនាញវិជ្ជាជីវៈនិងក្រុមអ្នកជំនាញផ្សេងៗដើម្បីចូលរួមអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | បញ្ជី | 1 | កំពុងដំណើរការ | សាលាជាតិរដ្ឋបាលមូលដ្ឋានបានសហការជាមួយស្ថាប័នអភិវឌ្ឍសមត្ថភាពមួយចំនួនក្នុងការរៀបចំកម្មវិធីសិក្សា និងឯកសារបណ្តុះបណ្តាលសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជាសាលាភូមិន្ទរដ្ឋបាល វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកិច្ចការនារី។ |
| 3.8.2 | ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលនានា | 61. លិខិតបទដ្ឋានស្តីពីបច្ចុប្បន្នភាពកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលនានាត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 1 | កំពុងដំណើរការ | សាលាជាតិរដ្ឋបាលមូលដ្ឋាន កំពុងដំណើរការរៀបចំសេចក្តីណែនាំស្តីពីការរៀបចំកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាល។ |
| 3.8.3 | ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពលើឯកសារសម្ភារៈបណ្តុះបណ្តាលសម្រាប់កម្មវិធីសិក្សានានា | 62. លិខិតបទដ្ឋានស្តីពីបច្ចុប្បន្នភាពលើឯកសារសម្ភារៈបណ្តុះបណ្តាលសម្រាប់កម្មវិធីសិក្សានានាត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 1 | កំពុងដំណើរការ | សាលាជាតិរដ្ឋបាលមូលដ្ឋានកំពុងដំណើរការរៀបចំសេចក្តីណែនាំស្តីពីការរៀបចំឯកសារ សម្ភារៈសម្រាប់វគ្គបណ្តុះបណ្តាល។ |
| 3.9.1 | ការជ្រើសរើស និងការអនុម័តវិធីសាស្ត្រផ្សេងៗសម្រាប់វគ្គបណ្តុះបណ្តាលនានា | 63. លិខិតបទដ្ឋានស្តីពីវិធីសាស្ត្រផ្សេងៗសម្រាប់វគ្គបណ្តុះបណ្តាលនានាត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 1 | កំពុងដំណើរការ | សាលាជាតិរដ្ឋបាលមូលដ្ឋានកំពុងដំណើរការរៀបចំសេចក្តីណែនាំស្តីពីការរៀបចំវិធីសាស្ត្រផ្សេងៗសម្រាប់វគ្គបណ្តុះបណ្តាលបណ្តាល។ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | បញ្ហនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| 4 | **វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ៖** | | | | | |
| 4.1.1 | ការបន្សីគ្នារវាងកិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 64. ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំបញ្ជីគម្រោងទាន់ពេលវេលាសម្រាប់ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ | រដ្ឋបាលថ្នាក់ក្រោមជាតិ | 70% | បានបញ្ចប់ | រដ្ឋបាលរាជធានី ខេត្តទាំង២៥បានរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដោយផ្អែកតាមបញ្ជីគម្រោងជាអាទិភាពនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ស្របតាមគោលការណ៍ណែនាំជាធរមាន។ |
| 4.1.2 | ការពិនិត្យ និងកែសម្រួលឡើងវិញប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 65. ការសិក្សាអំពីការកែសម្រួលប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ការសិក្សា | 3 | កំពុងដំណើរការ | ក្រសួងផែនការកំពុងដំណើរការពិនិត្យមើលឡើងវិញ និងសិក្សាអំពីលិខិតបទដ្ឋាន និងសេចក្តីណែនាំនានាដែលពាក់ព័ន្ធនឹងការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| 4.1.4 | ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 66. ការរៀបចំនិងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានស្តីពីការប្រើប្រាស់ទិន្នន័យមូលដ្ឋានថ្នាក់ក្រោមជាតិ | លិខិតបទដ្ឋាន | 1 | កំពុងដំណើរការ | កម្រងបញ្ជីសំណួរនៃទិន្នន័យមូលដ្ឋានថ្នាក់ក្រោមជាតិកំពុងពិនិត្យ និងកែសម្រួលដោយបញ្ចូលនូវកម្រងបញ្ជីសំណួរដែលពាក់ព័ន្ធនឹងការងារប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ ជំងឺឆ្លងរាតត្បាតកាចសាហាវ និងសេវាសង្គមនានា។ល។ |
| 4.2.1 | ការបន្តការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៥) | 67. ភាគរយរាជធានី ខេត្ត ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (គិតជាមធ្យម) | រាជធានី ខេត្ត | 80% | បានបញ្ចប់ | រដ្ឋបាលរាជធានី ខេត្តទាំង២៥កំពុងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុដែលបានរៀបចំ និងដាក់ឱ្យអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ |
| 4.2.2 | ការធ្វើវិមជ្ឈការ និងការពង្រឹងការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 68. ការពិនិត្យមើលឡើងវិញអំពីសិទ្ធិអំណាចរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តលទ្ធកម្ម | ការពិនិត្យមើល | 1 | កំពុងដំណើរការ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងដំណើរការពិនិត្យមើលឡើងវិញនូវច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋាននានាដើម្បីផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងពង្រឹងការអនុវត្តកិច្ចលទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| 4.3.1 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលសារពើពន្ធ ដែលមានស្រាប់ | 69. លិខិតបទដ្ឋានស្តីពីការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលនិងការគ្រប់គ្រងចំណូលសារពើពន្ធត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 1 | កំពុងដំណើរការ | រដ្ឋបាលរាជធានី ខេត្តផ្អែកតាមគោលការណ៍ណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានពង្រឹងការប្រមូលចំណូលសារពើពន្ធរបស់ខ្លួនចំនួន០៩មុខ រួមមាន ពន្ធលើឈ្នួលផ្ទះនិងដី ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានយន្តគ្រប់ប្រភេទ ពន្ធប៉ាតង់ ពន្ធប្រថាប់ត្រា ពន្ធលើអចលនទ្រព្យ អាករសម្រាប់បំភ្លឺសាធារណៈ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | អាករលើការស្នាក់នៅ ពន្ធតែមប្រើសារពើពន្ធ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដែលសម្រេចបានចំណូលក្នុងឆ្នាំ២០២២ ចំនួនប្រមាណ១.៥៦៣លានរៀល ស្មើនឹងប្រមាណជាង៣៨៦លានដុល្លារ។ |
| 4.3.2 | ការបែងចែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ | 70. ការសិក្សាអំពីការបែងចែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានីខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ | ការសិក្សា | 1 | កំពុងដំណើរការ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងដំណើរការពិនិត្យមើលឡើងវិញនូវលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការបែងចែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់។ ក្នុងឆ្នាំ២០២២នេះ រដ្ឋបាលរាជធានី ខេត្តបានចែករំលែកចំណូលសារពើពន្ធពីរដ្ឋបាលរបស់ខ្លួនទៅឱ្យរដ្ឋបាលក្រុង ស្រុកចំនួន៤% និងទៅឱ្យរដ្ឋបាលឃុំ សង្កាត់ចំនួន៥%។ |
| 4.3.3 | ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ការបង្កើតមូលនិធិភាតរភាពទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | 71. ការសិក្សាអំពីការបង្កើតមូលនិធិភាតរភាព | ការសិក្សា | 1 | មិនបានអនុវត្ត | |
| 4.4.1 | ការបន្សុីគ្នារវាងកម្មវិធីជាតិដំណាក់កាលទី២ និងឯកសារគោលស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ | 72. លិខិតបទដ្ឋានស្តីពីការបន្សុីគ្នារវាង កជទី២និងឯកសារគោលស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ | លិខិតបទដ្ឋាន | 1 | មិនបានអនុវត្ត | |
| 4.4.2 | ការលើកកម្ពស់ការប្រមូល និងការគ្រប់គ្រងកម្រៃ ឬឈ្នួលសេវា | 73. ភាគរយចំណូលតាមយន្តការច្រកចេញចូលតែមួយមានការកើនឡើង (គិតជាមធ្យមប្រចាំឆ្នាំ) | ចំណូល | 10% | បានបញ្ចប់ | ពាក់ព័ន្ធនឹងសកម្មភាពនេះ ក្នុងឆ្នាំ២០២២ សម្រេចបានលទ្ធផលដូចខាងក្រោម៖<br>– ការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់វិក្កយបត្រ (Payment Hub) នៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តទាំង២៥<br>– អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្តទាំង២៥បានផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋសរុបចំនួន៦៩៥.២០៥សេវាលើ១៤វិស័យ និងទទួលបានចំណូលសរុបចំនួន ១១៧.៨៤៩.៩៧១.៧៨៧រៀល ស្មើនឹង២៨.២១២.៩៩២ដុល្លារ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | – ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌបានផ្តល់សេវារដ្ឋបាលសរុបចំនួន១.៥៦១.៧០៤ សេវា និងទទួលបានចំណូលសរុបចំនួន ១១.០០៩.០៦៦.៩៦០រៀល ស្មើនឹង២.៧៥២.២៦៦ ដុល្លារ។ |
| 4.5.1 | ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 74. លិខិតបទដ្ឋានស្តីពីការគ្រប់គ្រង និង ការចាត់ចែងទ្រព្យសម្បត្តិរបស់រដ្ឋបាល ថ្នាក់ក្រោមជាតិត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 1 | កំពុងដំណើរការ | សម្រេចបានលទ្ធផលដូចខាងក្រោម៖<br>– រដ្ឋបាលរាជធានី ខេត្តទាំង២៥បានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ដែលបានរៀបចំ និងដាក់ឱ្យអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងឆ្នាំ ២០២០<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្សព្វផ្សាយ និងណែនាំអនុវត្តនូវវិធានការ និងនីតិវិធីនៃការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| 4.6.1 | ការបង្កើនការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាល ក្រុង ស្រុក | 75. ការកែសម្រួលឡើងវិញនូវអត្រាចូលរួមពីធនធានថវិកាជាតិក្នុងមូលនិធិក្រុង ស្រុក | លិខិតបទដ្ឋាន | 1 | កំពុងដំណើរការ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងដំណើរការសិក្សាពិនិត្យមើលឡើងវិញនូវលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងអត្រាចូលរួមពីធនធានថវិកាជាតិក្នុងមូលនិធិក្រុង ស្រុក។ |
| 4.6.2 | ការពង្រឹងនូវប្រព័ន្ធគ្រប់គ្រងមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | 76. ការកំណត់រូបមន្តនិងលក្ខណៈវិនិច្ឆ័យសម្រាប់ការបែងចែកមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | លិខិតបទដ្ឋាន | 1 | មិនបានអនុវត្ត | |
| 4.6.3 | ការលើកកម្ពស់សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌសម្រាប់គម្រោងសេវាកម្មនានា | 77. លិខិតបទដ្ឋានស្តីពីការលើកកម្ពស់សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងចាត់ចែងនិងប្រើប្រាស់ធនធានផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 1 | កំពុងដំណើរការ | ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប. កំពុងដំណើរការរៀបចំលិខិតបទដ្ឋានស្តីពីការប្រើប្រាស់មូលនិធិក្រុង ស្រុក និងឃុំ សង្កាត់សម្រាប់គម្រោង/សកម្មភាពសេវាសង្គម។ ទន្ទឹមនេះដែរ រដ្ឋបាលឃុំ សង្កាត់បានពង្រឹង និងលើកកម្ពស់ការអនុវត្តមុខងារសេវាសង្គមស្របតាមសៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់ ឆ្នាំ២០១៨ និងរដ្ឋ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | បាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ បានពង្រឹង និងលើកកម្ពស់ការអនុវត្តមុខងារសេវាសង្គមស្របតាមសៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ឆ្នាំ២០២១។ |
| 4.7.1 | ការលើកកម្ពស់ការអនុវត្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌក្នុងក្របខ័ណ្ឌដែលមានបច្ចុប្បន្ន ព្រមទាំងរៀបចំ និង កែលម្អក្របខ័ណ្ឌផ្តល់ហិរញ្ញប្បទានដល់ មុខងារជាកាតព្វកិច្ចឱ្យកាន់តែប្រសើរឡើង | 78. លិខិតបទដ្ឋានស្តីពីការលើកកម្ពស់ការអនុវត្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌក្នុងក្របខ័ណ្ឌត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 1 | កំពុងដំណើរការ | សម្រេចបានលទ្ធផលដូចខាងក្រោម៖<br>– ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារក្នុងវិស័យអប់រំប្រមាណជាង៣៣លានដុល្លារសម្រាប់ឆ្នាំ២០២២នេះ ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ទាំង១៤ នៃខេត្តបាត់ដំបង<br>– ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារក្នុងវិស័យសុខាភិបាលប្រមាណ១៧០លានដុល្លារសម្រាប់ឆ្នាំ២០២២នេះ ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្តទាំង២៥<br>– ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងនៅទីប្រជុំជនប្រមាណ២លានដុល្លារសម្រាប់ឆ្នាំ២០២២ ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុងទាំង២៧<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចុះសិក្សា និងពិនិត្យមើលអំពីលទ្ធភាពនៃការផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារទាំង៥៥ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |
| 4.8.2 | ការលើកកម្ពស់ក្របខ័ណ្ឌសម្រាប់គ្រប់គ្រងធនធានរបស់ដៃគូអភិវឌ្ឍន៍ដែលផ្តល់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | 79. ការសិក្សាអំពីការបញ្ចូលថវិការបស់គម្រោងកម្មវិធីនានារបស់ដៃគូក្នុងថវិការបស់ថ្នាក់ក្រោមជាតិ | ការសិក្សា | 1 | បានបញ្ចប់ | លេខាធិការដ្ឋាន គ.ជ.អ.ប.បានសម្របសម្រួល និងដាក់បញ្ចូលនូវសកម្មភាពនានារបស់គម្រោង/កម្មវិធីគាំទ្រដោយដៃគូអភិវឌ្ឍន៍ទៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. មានដូចជា គម្រោង ISAF គម្រោងសាងសង់សាលាជាតិរដ្ឋបាលមូលដ្ឋាន គម្រោងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | បញ្ហាភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | (SNIF) គម្រោងលើកកម្ពស់អាហារូបត្ថម្ភនៅកម្ពុជា (CNP) គម្រោងនានាពាក់ព័ន្ធនឹងភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុមានចំនួន០៦គម្រោង និងគម្រោងធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាជូនប្រជាពលរដ្ឋនៅកម្ពុជា (ISD/GIZ)។ |
| 4.8.4 | ការពង្រឹងក្របខ័ណ្ឌគ្រប់គ្រងការវិនិយោគសាធារណៈដែលប្រើប្រាស់ថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 80. ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិបានអនុវត្តគម្រោងវិនិយោគសាធារណៈដោយប្រើប្រាស់ថវិការបស់ខ្លួនផ្អែកតាមយុទ្ធសាស្ត្រស្តីពីកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ (២០១៩-២០២៥) (គិតជាមធ្យមប្រចាំឆ្នាំ) | រដ្ឋបាលថ្នាក់ក្រោមជាតិ | 80% | បានបញ្ចប់ | ក្នុងឆ្នាំ២០២២ រដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈ រួមមាន រដ្ឋបាលរាជធានី ខេត្តមានចំនួន៣៧០គម្រោង រដ្ឋបាលក្រុង ស្រុកមានចំនួន៤៥៥គម្រោង និងរដ្ឋបាលឃុំ សង្កាត់មានចំនួន១.៩៣៥គម្រោង។ |
| 4.9.1 | ការសិក្សា និងរៀបចំនូវក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន | 81. ការសិក្សាអំពីក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងវិស័យឯកជនត្រូវបានអនុវត្ត | ការសិក្សា | 1 | កំពុងដំណើរការ | ក្នុងឆ្នាំ២០២២នេះ គម្រោងសាកល្បងក្នុងភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនលើការគ្រប់គ្រង និងផ្តល់សេវាទឹកស្អាតនៅឃុំបាសាក់ ស្រុករុក្ខគិរី ខេត្តបាត់ដំបង ត្រូវបានរៀបចំ និងអនុវត្ត ដើម្បីធ្វើជាមូលដ្ឋានក្នុងការបង្កើតក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន។ |
| 4.10.1 | ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង និង ការរៀបចំនីតិវិធីសវនកម្មផ្ទៃក្នុងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | 82. ការសិក្សាលើការរៀបចំឱ្យមានអង្គភាពសវនកម្មផ្ទៃក្នុងនៃរដ្ឋបាលរាជធានី ខេត្ត | ការសិក្សា | 1 | កំពុងដំណើរការ | សេចក្តីព្រាងនីតិវិធីសវនកម្ម ឬត្រួតពិនិត្យផ្ទៃក្នុងសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំឡើងដោយលេខាធិការដ្ឋាន គ.ជ.អ.ប.។ សេចក្តីព្រាងនេះនឹងត្រូវអនុម័ត និងដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០២៣។ ចំពោះការសិក្សាក្នុងការបង្កើតអង្គភាពសវនកម្មភាពផ្ទៃក្នុងសម្រាប់រដ្ឋបាលរាជធានី ខេត្តនឹងត្រូវរៀបចំឡើងក្នុងឆ្នាំ២០២៣ផងដែរ។ |
| 4.10.2 | ការពង្រឹងការធ្វើអធិការកិច្ចហិរញ្ញវត្ថុពីខាងក្រៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ | 83. ការសិក្សាអំពីប្រព័ន្ធអធិការកិច្ចហិរញ្ញវត្ថុរបស់ថ្នាក់ជាតិទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ | ការសិក្សា | 1 | មិនបានអនុវត្ត | |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| 5 | **ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ៖** | | | | | |
| 5.1.1 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច | 84. មេរៀនបទពិសោធន៍ស្តីពីការអនុវត្តមុខងារជាកាតព្វកិច្ចត្រូវបានរៀបចំ | ការសិក្សា | 1 | កំពុងដំណើរការ | សម្រេចបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖<br>– ក្រសួង ស្ថាប័នចំនួន១៤ក្នុងចំណោមក្រសួង ស្ថាប័នសរុបចំនួន២០ បានរៀបចំ និងដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំបច្ចេកទេសសម្រាប់ការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ព្រមទាំងបានរៀបចំវគ្គបណ្តុះបណ្តាលអំពីសេចក្តីណែនាំទាំងនេះ<br>– មេរៀន បទពិសោធន៍ស្តីពីការអនុវត្តមុខងារជាកាតព្វកិច្ចកំពុងដំណើរការពិនិត្យ និងប្រមូលទិន្នន័យ និងព័ត៌មានពាក់ព័ន្ធនានា ដើម្បីរៀបចំចងក្រងជាឯកសារសម្រាប់ផ្សព្វផ្សាយដល់<br>– រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសមុខងារក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ។ |
| 5.1.2 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើស | 85. មេរៀនបទពិសោធន៍ស្តីពីការអនុវត្តមុខងារជាជម្រើសត្រូវបានផ្សព្វផ្សាយ | សិក្ខាសាលា | 1 | កំពុងដំណើរការ | បាននិងកំពុងសិក្សា និងរៀបចំកែសម្រួលនីតិវិធីនៃការអនុវត្តមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីពង្រឹង និងលើកកម្ពស់ការអនុវត្តមុខងារជាអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ទន្ទឹមនោះ លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងរៀបចំចងក្រងមេរៀនបទពិសោធន៍ស្តីពីការអនុវត្តមុខងារជាជម្រើស ដើម្បីផ្សព្វផ្សាយ និងចែករំលែកដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| 5.2.1 | ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត | 86. លិខិតបទដ្ឋានស្តីពីការកែសម្រួល រចនាសម្ព័ន្ធបែបបទនិងនីតិវិធីនៃការផ្តល់សេវាត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 1 | បានបញ្ចប់ | បានពិនិត្យ និងកែសម្រួលបែបបទ និងនីតិវិធីនៃការផ្តល់សេវានៅអង្គភាពច្រកចេញចូលតែមួយពាក់ព័ន្ធនឹងការផ្តល់សេវាក្នុងវិស័យកសិកម្ម និងវិស័យសាធារណការ និងដឹកជញ្ជូន។ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| 5.2.2 | ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ | 87. លិខិតបទដ្ឋានស្តីពីការកែសម្រួលរចនាសម្ព័ន្ធបែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | 1 | បានបញ្ចប់ | សម្រេចបានលទ្ធផលដូចខាងក្រោម៖<br>– បានរៀបចំកែសម្រួលរចនាសម្ព័ន្ធនៃការិយាល័យច្រកចេញចូលតែមួយនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌតាមរយៈប្រកាសលេខ៧៥១ ប្រ.ក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ ២០២១<br>– បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីរបៀបប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និង ការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>– បានដាក់ចេញសេចក្តីណែនាំលេខ០១៨ សណន ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ស្តីពីបែបបទ និងនីតិវិធីផ្តល់សេវារដ្ឋបាល តាមរយៈយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ និងបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីសេចក្តីណែនាំនេះដល់រដ្ឋបាលឃុំ សង្កាត់នៅខេត្តបាត់ដំបង។<br>– បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីរបៀបប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>– បានដាក់ចេញសេចក្តីណែនាំលេខ០១៨ សណន ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ស្តីពីបែបបទ និងនីតិវិធីផ្តល់សេវា<br>រដ្ឋបាល តាមរយៈយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ និងបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីសេចក្តីណែនាំនេះដល់រដ្ឋបាលឃុំ សង្កាត់នៅខេត្តបាត់ដំបង។ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | បរិយាយភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| 5.2.3 | ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ | ៨៨. ការសិក្សាអំពីប្រព័ន្ធផ្តល់សេវាតាមអនឡាញនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត | ការសិក្សា | 1 | កំពុងដំណើរការ | សម្រេចបានលទ្ធផលដូចខាងក្រោម៖<br>– បាននិងកំពុងពង្រីកការអនុវត្ត និងការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធស្វ័យប្រវត្តិកម្មតាមអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តលើសេវាចុះបញ្ជីយានយន្ត និងការប្រឡងយកបណ្ណបើកបរយានយន្ត និងប្តូរ ពន្យារទុតិយតា តតិយតា (លើកលែងជនបរទេស)<br>– បាននិងកំពុងពង្រីកការអនុវត្ត និងការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធស្វ័យប្រវត្តិកម្មតាមការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌលើសេវាកម្មម៉ូតូ និងសេវាកម្មត្រីចក្រយានយន្ត ឬម៉ែក<br>– បាននិងកំពុងសិក្សាអំពីលទ្ធភាពនៃការរៀបចំ និងដាក់ឱ្យអនុវត្តនូវសេវាមួយចំនួនតាមប្រព័ន្ធអនឡាញ<br>– បាននិងកំពុងពិនិត្យ និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទូទាត់វិក្កយបត្រ (Payment Hub) ដែលបានដាក់ឱ្យអនុវត្តនៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត<br>– បានរៀបចំវគ្គបំប៉នស្តីពីរបៀបប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ |
| 5.3.1 | ការរៀបចំបញ្ជីមូលដ្ឋានអាជីវកម្ម ឬសហគ្រាសនៅតាមមូលដ្ឋាន | ៨៩. បញ្ជីមូលដ្ឋានអាជីវកម្ម ឬសហគ្រាសនានាត្រូវបានរៀបចំដោយរាជធានី ខេត្ត | បញ្ជី | 1 | បានបញ្ចប់ | រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌបានរៀបចំ និងធ្វើបច្ចុប្បន្នភាពបញ្ជីមូលដ្ឋានអាជីវកម្ម ឬសហគ្រាសនានាដែលប្រកបអាជីវកម្មនៅក្នុងរាជធានី ខេត្ត។ |
| 5.4.1 | ការបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | ៩០. ការសិក្សាអំពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយនិងជំងឺឆ្លងកាចសាហាវនានាត្រូវបានអនុវត្ត | ការសិក្សា | 1 | បានបញ្ចប់ | លេខាធិការដ្ឋាន គ.ជ.អ.ប. បានចុះសិក្សា និងវាយតម្លៃស្តីពីការអនុវត្តគោលនយោបាយសុវត្ថិភាពដីធ្លី បរិស្ថាន និងជនជាតិដើមភាគតិចរួមបញ្ចូលទាំងការសិក្សាអំពីតួនាទី ភារកិច្ចរបស់យន្តការនានាដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា ដើម្បីជាមូល |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | បញ្ហានភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | ដ្ឋានដល់ការរៀបចំបង្កើតនូវគណៈកម្មាធិការដាក់លាក់មួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| 5.4.2 | ការកំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវាដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ | 91. ឯកសារបទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវា និងការវិនិយោគដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំ | សៀវភៅណែនាំ | 1 | កំពុងដំណើរការ | លេខាធិការដ្ឋាន គ.ជ.អ.ប.កំពុងពិនិត្យមើលឡើងវិញអំពីឯកសារបច្ចេកទេសនានាដែលពាក់ព័ន្ធនឹងបទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវា និងការវិនិយោគដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។<br>ជាមួយគ្នានេះ លេខាធិការដ្ឋាន គ.ជ.អ.ប. បានសម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធរៀបចំឯកសារទស្សនទានចំនួន០៧ ពាក់ព័ន្ធនឹងការបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់ដៃគូអភិវឌ្ឍន៍ ដូចជា UNDP, GGGI, UNCDF និង IFAD ត្រូវបានសម្របសម្រួលរៀបចំ និងដាក់ជូនមូលនិធិអាកាសធាតុបៃតង(GCF) ដើម្បីស្នើសុំការគាំទ្រមូលនិធិ។ |
| 5.4.3 | ការពង្រឹងការប្រើប្រាស់ទិន្នន័យអំពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | 92. ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិ បានប្រើប្រាស់ទិន្នន័យការប្រែប្រួល អាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនិងជំងឺឆ្លងកាចសាហាវនានាសម្រាប់ការកសាងផែនការ របស់ខ្លួន (គិតជាមធ្យមប្រចាំឆ្នាំ) | រដ្ឋបាលថ្នាក់ក្រោមជាតិ | 30% | បានបញ្ចប់ | រដ្ឋបាលឃុំ សង្កាត់គោលដៅនៃគម្រោង "សន្តិសុខស្បៀង និងការគាំទ្រការស្តារឡើងវិញរបស់សហគមន៍មូលដ្ឋាន ដែលរងផលប៉ះពាល់ដោយសារទឹកជំនន់នៅប្រទេសកម្ពុជា (SRELFOOD2) គម្រោង "លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាថាមពលពន្លឺព្រះអាទិត្យសម្រាប់វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទនៅប្រទេសកម្ពុជា (STARD) និងគម្រោងធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា (CCCA) បានប្រើប្រាស់ទិន្នន័យការប្រែប្រួលអាកាសធាតុក្នុងការរៀបចំផែនការសកម្មភាពរបស់ខ្លួន។ |
| 5.4.4 | ការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | 93. ភាគរយសរុបនៃលទ្ធផលរំពឹងទុកនៃផែនការប្រចាំឆ្នាំរបស់គម្រោងកម្មវិធីត្រូវបានសម្រេច | លទ្ធផលរំពឹងទុក | 80% | បានបញ្ចប់ | លេខាធិការដ្ឋាន គ.ជ.អ.ប. បានសម្របសម្រួល និងកៀរគរធនធានពីគម្រោង/កម្មវិធីដាច់ដោយឡែកចំនួន០៦ ដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ដែលមានថវិកាសរុបចំនួនប្រមាណ១៣.៦៨១លានរៀល ស្មើនឹងប្រមាណ៣,៣៧លានដុល្លារ សម្រាប់វិនិយោគលើការលើកកម្ពស់ភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការកាត់ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងការការពារទប់ស្កាត់ជំងឺឆ្លងកាចសាហាវនានា។<br>ក្រៅពីសមិទ្ធផលនៃសមាសភាគទាំង៥ដូចបានរៀបរាប់ខាងលើ ការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២២ ក៏ទទួលបានការគាំទ្រពីគម្រោង កម្មវិធីដាច់ដោយឡែកមួយចំនួនដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ និងស្ថិតក្រោមការគ្រប់គ្រង និងសម្របសម្រួលដោយលេខាធិការដ្ឋាន គ.ជ.អ.ប.។ សមិទ្ធផលសំខាន់ៗដែលសម្រេចបានដោយគម្រោងទាំងនេះមានសង្ខេបដូចខាងក្រោម ៖<br>– គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប ជំហាន២៖ គម្រោង នេះ គាំទ្រដោយ ADB IFAD និងរាជរដ្ឋាភិបាលកម្ពុជារយៈពេលអនុវត្តពីឆ្នាំ២០១៨-២០២៣ ដោយគ្រោងថវិកាសរុបចំនួន៥៧,០៤៧លានដុល្លារ។ ថវិកាគ្រោងឡើងក្នុងឆ្នាំ២០២២ មានចំនួន១៦.៤៥២.៨០០ ដុល្លារ ក្នុងនោះចំណាយអស់ ១៣.៦២៩.៥៨៥ ដុល្លារ។ លទ្ធផលសំខាន់ៗរួមមាន បានរៀបចំ និងអនុវត្តគម្រោងចំនួន៥៤ ក្នុងនោះគម្រោងចំនួន៤៦ បានអនុវត្តចប់ ១០០% បានបង្កើត និងបណ្តុះបណ្តាលក្រុមកែលម្អជីវភាពថ្មីចំនួន ៧០២ ក្រុមដែលមានសមាជិកសរុប ១៧.៥៣៥ នាក់ ក្នុងនោះមានស្ត្រីចំនួន ៧៥% បានរៀបចំធ្វើបង្ហាញបច្ចេកទេសចំនួន៧៧ទីតាំង ស្តីពីបច្ចេកទេសផលិតកម្មសម្រាប់សមាជិកក្រុមកែលម្អជីវភាពថ្មីចំនួន ៣.៨៣៩នាក់ ក្នុងនោះស្ត្រីមានចំនួន ២.២១៥នាក់ បានរៀបចំទិវាផ្សព្វផ្សាយពេលប្រមូលផលចំនួន២៣ កន្លែង ដែលមានសមាជិកលីកចូលរួមចំនួន ៥៧៣ នាក់ ក្នុងនោះស្ត្រីមានចំនួន២៩៣នាក់ |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | បញ្ហានភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | – គម្រោងកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ ៖ គម្រោងនេះ គាំទ្រដោយ IFAD រយៈពេលអនុវត្តពីឆ្នាំ២០១៥-២០២២ ដោយគ្រោងថវិកាសរុបចំនួន ២០,៩០លានដុល្លារ ហើយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប ទទួលបន្ទុកអនុវត្តសមាសភាគទី៤ នៃគម្រោងនេះ ។ ក្នុងឆ្នាំ២០២២ ថវិកាគ្រោងមានចំនួន ១.៤០០.០០០ ដុល្លារ និងបានចំណាយសរុបចំនួន ១.៤០០.០០០ ដុល្លារ ។ លទ្ធផលសំខាន់ៗ ដែលសម្រេចបានរួមមាន បានសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធចំនួន ១៧ គម្រោង និងបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ឃុំគោលដៅបាន ចំនួន ១០៤ឃុំ ស្រុកគោលដៅចំនួន ៣២ស្រុក និងខេត្តគោលដៅចំនួន ៨ខេត្ត<br>– គម្រោងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាថាមពលពន្លឺព្រះអាទិត្យសម្រាប់វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទនៅកម្ពុជា ៖ គម្រោងនេះ គាំទ្រដោយ UNDP រយៈពេលអនុវត្តពីឆ្នាំ២០២១-២០២៣ ដោយគ្រោងថវិកាសរុបចំនួន ១២៧.០០០ដុល្លារ ។ ថវិកាគ្រោងឡើងក្នុងឆ្នាំ២០២២ មានចំនួន ៦៥.៦៧៦ ដុល្លារ ក្នុងនោះ ចំណាយ ៦០.៩៤៤,៤៩ ដុល្លារ។ លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមាន បានបំពាក់ប្រព័ន្ធបូមទឹកប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យសរុបចំនួន ៦៧ ប្រព័ន្ធ នៅក្នុងឃុំគោលដៅចំនួន២៣ឃុំ និងបានសាងសង់ផ្សារកសិករចំនួន០៤ ក្នុងខេត្តកំពង់ធំ និងខេត្តសៀមរាប |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | – នវានុវត្តនៃការផ្គត់ផ្គង់ទឹកស្អាតដែលធន់នឹងការប្រែប្រួលអាកាសធាតុ ៖ គម្រោងនេះគាំទ្រដោយអង្គការ UNCDF រយៈពេលអនុវត្តពីឆ្នាំ២០២០-២០២២ ដែលមានគ្រោងថវិកាសរុបចំនួន ៧១៨.៤៨៧ ដុល្លារ។ ក្នុងឆ្នាំ២០២២ ថវិកាគ្រោងមានចំនួន ២៧៦.៦៤០ ដុល្លារ និងបានចំណាយសរុបចំនួន ១០៩.៩៥១ ដុល្លារ។ លទ្ធផលសំខាន់ៗដែលសម្រេចបានមានដូចជា បានរៀបចំប្លង់បច្ចេកទេសសម្រាប់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតនៅឃុំបាសាក់ ស្រុករុក្ខគិរី ខេត្តបាត់ដំបង បានធ្វើលទ្ធកម្មជ្រើសរើសក្រុមហ៊ុនសាងសង់ស្ថានីយ និងបានរៀបចំសេចក្តីព្រាងលក្ខខណ្ឌកិច្ចព្រមព្រៀងរវាងរដ្ឋបាលឃុំបាសាក់ និងវិនិយោគិនឯកជនសម្រាប់ការគ្រប់គ្រងវិនិយោគ និងប្រតិបត្តិប្រព័ន្ធគ្រប់គ្រងទឹក<br>– គម្រោងសន្តិសុខស្បៀង និងការគាំទ្រការស្តារឡើងវិញរបស់សហគមន៍មូលដ្ឋាន ដែលរងផលប៉ះពាល់ដោយសារទឹកជំនន់នៅប្រទេសកម្ពុជា ៖ គម្រោងនេះគាំទ្រដោយ WFP រយៈពេលអនុវត្តពីឆ្នាំ២០២១-២០២២ ដោយគ្រោងថវិកាសរុបចំនួន ១.១៦៥.៣៣៧ ដុល្លារ និងបានចំណាយអស់ចំនួន ១.១៤៨.០៦០ ដុល្លារ។ លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមានគម្រោងហេដ្ឋាសម្ព័ន្ធខ្នាតតូចមានចំនួន ១៩គម្រោង (គម្រោងជីកនិងស្តារប្រឡាយមានចំនួន០៨គម្រោង គម្រោងស្តារបឹងធម្មជាតិ/អាងស្តុកទឹកមានចំនួន០២គម្រោង និងគម្រោងជួសជុលផ្លូវក្រាលក្រួសក្រហមមានចំនួន០៩គម្រោង) និងបានអភិវឌ្ឍ សមត្ថភាពអំពីការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ដើម្បីដាក់ |

| ក្រុង | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | បញ្ចូលក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (CDP) និងកម្មវិធីវិនិយោគបីឆ្នាំរំកិល (CIP) ដល់ក្រុមការងារខេត្ត និងស្រុកគោលដៅ ក្រុមប្រឹក្សាឃុំ និង គ.ផ.ថ. សរុបចំនួន១៨៣នាក់<br>– គម្រោងអាហារូបត្ថម្ភនៅកម្ពុជា (CNP) ៖ គម្រោងនេះគាំទ្រដោយធនាគារពិភពលោក និងដៃគូអភិវឌ្ឍន៍នានា រយៈពេលអនុវត្តពីឆ្នាំ២០១៩-២០២៦ ដោយបានគ្រោងថវិកាសរុបចំនួន ១០,៨ លានដុល្លារ ហើយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប ទទួលបន្ទុកអនុវត្តសមាសភាគទី២ នៃគម្រោងនេះ។ ក្នុងឆ្នាំ២០២២ គម្រោងបានគ្រោងថវិកាចំនួន ២.៤៨៧.១៩៤ ដុល្លារ ដែលក្នុងនោះបានចំណាយអស់ ២.២៨៨.០៦០ ដុល្លារ។ លទ្ធផលសំខាន់ៗដែលសម្រេចបានមានដូចជា បានផ្ទេរមូលនិធិគាំទ្រការផ្តល់សេវាឃុំ សង្កាត់ឱ្យរដ្ឋបាលក្រុង ស្រុកចំនួន៤៤ និងឃុំ សង្កាត់ចំនួន២៧៩ និងបានរៀបចំវគ្គបណ្តុះបណ្តាល ៨៣វគ្គដល់រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលមានសិក្ខាកាមចំនួន ២.៨១៨នាក់ ក្នុងនោះស្ត្រី ៩៨៩នាក់<br>– គម្រោងពង្រឹងភាពអង់អាចដល់ស្ត្រីដើម្បីសង្គមធននឹងការប្រែប្រួលអាកាសធាតុ ៖ គម្រោងនេះ គាំទ្រដោយ UNEP រយៈពេលអនុវត្តពីឆ្នាំ២០២០-២០២២ ដោយគ្រោងថវិកាសរុបចំនួន ១៧១.១៩២ ដុល្លារ។ ក្នុងឆ្នាំ ២០២២ ថវិកាគ្រោងមានចំនួន ២១.៧២៦ ដុល្លារ និងបានចំណាយសរុបចំនួន ២១.៧២៦ ដុល្លារ ។ លទ្ធផលសំខាន់ៗ ដែលសម្រេចបានរួមមាន ៖ បានបង្កើតមូលនិធិ EmPower ដោយសហការជាមួយជាមួយធន |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | គារ ARDB ក្នុងទិសដៅបង្កើតខ្សែបន្ទាត់ឥណទានសម្រាប់គាំទ្រស្ត្រី ដែលមានបំណងវិនិយោគលើថាមពលកកើតឡើងវិញ ផ្តល់បច្ចេកទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិយល់ដឹងការបញ្ច្រាបការវិនិយោគលើថាមពលកកើតឡើងវិញ ក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ខ្លួន បានផ្តល់ចំណេះដឹងដល់ស្ត្រីគោលដៅស្តីការគ្រប់គ្រងអាជីវកម្ម និងហិរញ្ញវត្ថុផ្ទាល់ខ្លួន ដំឡើងម៉ាស៊ីនបូមទឹកប្រើថាមពលពន្លឺព្រះអាទិត្យសម្រាប់ស្រោចស្រពបន្លែចំនួន៩គ្រួសារ និងបានដំឡើងប្រព័ន្ធសូឡាកូនកាត់សម្រាប់ស្រោចស្រពបន្លែក្នុងផ្ទះសំណាញ់ និងភ្ញាស់ស៊ុតមាន់១គ្រួសារ<br>– គម្រោងសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖ គម្រោងនេះ គាំទ្រដោយមូលនិធិបរធនបាលកិច្ច (WB រដ្ឋាភិបាលអាល្លឺម៉ង់ និងទីភ្នាក់ងារសហប្រតិបត្តិការសម្រាប់កិច្ចអភិវឌ្ឍន៍របស់ប្រទេសស្វីស SDC) និងរាជរដ្ឋាភិបាលកម្ពុជា រយៈពេលអនុវត្តពីឆ្នាំ២០២០-២០២៣ ដោយគ្រោង ថវិកាសរុបចំនួន ១,៧២លានដុល្លារ ។ ថវិកាគ្រោងឡើងក្នុងឆ្នាំ២០២២ មានចំនួន ១.១១៩.៣៦៦ ដុល្លារ ក្នុងនោះចំណាយអស់ ៧៩៣.៥៧៤ ដុល្លារ ។ លទ្ធផលសំខាន់ៗរួមមាន បានពង្រីក និងអនុវត្តការងារគណនេយ្យភាពសង្គមនៅក្នុងរាជធានី ខេត្តចំនួន២៤ ក្រុង ស្រុក ខណ្ឌ ១៧៣ និងឃុំ សង្កាត់ ១.៤១៣ ដោយផ្តោតលើការផ្តល់សេវាចំនួន ០៣ គឺ សេវារដ្ឋបាលឃុំ សង្កាត់ចំនួន១.៤១៣ សេវាអប់រំកម្រិតបឋមសិក្សាចំនួន ៦.២៣១ សាលា និងមណ្ឌលសុខភាព |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | ចំនួន ១.១១០ និងសេវារដ្ឋបាលក្រុង ស្រុក ខណ្ឌ ២២ ក្នុងនោះធនាគារពិភពលោកបានគាំទ្រការអនុវត្តក្នុងខេត្តចំនួន១០ ក្រុង ស្រុកចំនួន៥៥ និងឃុំ សង្កាត់ចំនួន៤៦៥។ ជាមួយគ្នានេះដែរ គម្រោងបានផ្សព្វផ្សាយព័ត៌មានអំពីសិទ្ធិ ស្តង់ដាការបំពេញការងារការផ្តល់សេវា និងថវិកាជូនប្រជាពលរដ្ឋចំនួន ៤២៥.០៤៩នាក់ ស្ត្រី ២៣៣.៤៣០ នាក់ និងគម្រោងសកម្មភាពគណនេយ្យសង្គមចំនួន ៤.៩១៦ គម្រោងត្រូវបានគាំទ្រ និងអនុវត្តដោយប្រើប្រាស់ថវិកាឃុំសង្កាត់ និងដៃគូពាក់ព័ន្ធនានា<br>– ការអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ ៖ គម្រោងនេះ ត្រូវបានអនុវត្តដោយអង្គការចំនួន០៤ រួមមានអង្គការទស្សនៈពិភពលោក អង្គការអុកស្វាមកម្ពុជា អង្គការឃែរអន្តរជាតិប្រចាំកម្ពុជា អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) ដែលទទួលថវិកាគាំទ្រពីធនាគារពិភពលោក ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) និងសហភាពអឺរ៉ុប។ ថវិកាគ្រោងប្រចាំឆ្នាំ២០២២មានចំនួន៣.៣៦៨.០៧២ ដុល្លារ ក្នុងនោះចំណាយចំនួន ៣.០០៧.៧៤០ ដុល្លារ។ លទ្ធផលសំខាន់ៗ រួមមាន បានពង្រីក និងបន្តអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការនៅក្នុងរាជធានី ខេត្តចំនួន១៨ ក្រុង ស្រុក ខណ្ឌចំនួន៩៩ ដោយផ្តោតលើការផ្តល់សេវារដ្ឋបាលឃុំ សង្កាត់ចំនួន៧២៣ សាលាបឋមសិក្សាចំនួន២.៩៧១ មណ្ឌលសុខភាពចំនួន៥៣៧ និងការផ្តល់សេវាលើរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំនួន១៩។ ជាមួយគ្នានេះ អង្គការសង្គមស៊ីវិល |

| កូដ | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | បានសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្សព្វផ្សាយព័ត៌មានអំពីសិទ្ធិ ស្តង់ដាការបំពេញការងារ ការផ្តល់សេវា និងថវិកាជូនប្រជាពលរដ្ឋចំនួន ៤៧៧.៩៧០នាក់ ស្ត្រី២៦៦.៣១៣នាក់ និងបានសម្របសម្រួលរៀបចំកិច្ចប្រជុំរួមដើម្បីបង្កើតផែនការសកម្មភាពរួមស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមចំនួន១៥.៤០៨ គម្រោងសកម្មភាព<br>– គម្រោងគាំទ្រស្ថាប័នទទួលហិរញ្ញប្បទានផ្ទាល់នៅកម្ពុជាដើម្បីបំពេញលក្ខខណ្ឌទទួលស្គាល់ គម្រោងនេះ គាំទ្រដោយ GCF រយៈពេលអនុវត្តពីឆ្នាំ២០២១-២០២២ ដោយគ្រោងថវិកាសរុបចំនួន ៥១៧.០០០ដុល្លារ និងបានចំណាយថវិកាចំនួន៤៧.០០២ ដុល្លារ។ លទ្ធផលសំខាន់ៗដែលសម្រេចបានរួមមាន បានរៀបចំបញ្ចប់ឯកសារទស្សនទានគម្រោងស្តីពីរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ ដំណាក់កាលទី៣ បានរៀបចំវគ្គអភិវឌ្ឍសមត្ថភាពអំពីកិច្ចប្រតិបត្តិការ និងសវនកម្មផ្ទៃក្នុងរបស់ គ.ជ.អ.ប.ដល់មន្ត្រីលេខាធិការដ្ឋាន និងរដ្ឋបាលខេត្តចំនួន១១ខេត្ត ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៦៨នាក់ ស្ត្រី១៩នាក់ និងបានធ្វើលទ្ធកម្មជ្រើសរើសក្រុមហ៊ុននិងទីប្រឹក្សាសម្រាប់រៀបចំប្រព័ន្ធផ្សព្វផ្សាយនិងទទួលបណ្តឹងអំពីគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ<br>– គម្រោងធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា៖ គម្រោងនេះ គាំទ្រដោយ CCCA រយៈពេលអនុវត្តពីឆ្នាំ២០២២-២០២៣ ដោយគ្រោងថវិកាសរុបចំនួន |

| ក្រុង | សមាសភាគ និងលទ្ធផលរំពឹងទុក | សូចនាករ | ឯកតា | ចំណុចដៅ | ស្ថានភាពអនុវត្ត | វឌ្ឍនភាពសំខាន់ៗនៃការអនុវត្ត |
|---|---|---|---|---|---|---|
| | | | | | | ៩៤.៩៦៧ ដុល្លារ។ ក្នុងឆ្នាំ២០២២ ថវិកាគ្រោងមានចំនួន១៤.៥៩៥ ដុល្លារ និងបានចំណាយសរុបចំនួន ១២.៣៥៧ ដុល្លារ ។ លទ្ធផលសំខាន់ៗ ដែលសម្រេចបានរួមមាន កំពុងពិនិត្យ និងធ្វើបច្ចុប្បន្នភាពនៃប្រព័ន្ធទិន្នន័យដែលមានស្រាប់ ដើម្បីធ្វើការសិក្សាអំពីអន្តរទំនាក់ទំនងរវាងប្រព័ន្ធទិន្នន័យព័ត៌មានមូលដ្ឋានទិន្នន័យឃុំ សង្កាត់ (CDB) ប្រព័ន្ធទិន្នន័យគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ(SPD) មូលដ្ឋានទិន្នន័យការអនុវត្តគម្រោង(PID) និងសន្ទស្សន៍ងាយរងគ្រោះ (VI) ដោយរកលទ្ធភាពសម្រាប់ការដាក់បញ្ចូលទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| | | 94. ចំនួនគម្រោងកម្មវិធីរបស់ដៃគូដែលបានគាំទ្រសកម្មភាពស្នូលនៃកំណែទម្រង់ | គម្រោង | 7 | បានបញ្ចប់ | |

## ឧបសម្ព័ន្ធទី២ ៖ វឌ្ឍនភាពនៃការអនុវត្តថវិកាប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្ត

### វឌ្ឍនភាពនៃការអនុវត្តថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន (គិតជារៀល)

| ល.រ. | ក្រសួង ស្ថាប័ន | ថវិកាជារៀល | ថវិកាចំណាយ | | | សមតុល្យ |
|---|---|---|---|---|---|---|
| | | | ឆមាសទី១ | ឆមាសទី២ | សរុបចំណាយ | |
| ១ | លេខាធិការដ្ឋាន គ.ជ.អ.ប. | 8,550,000,000 | 2,116,065,000 | 6,432,885,522 | 8,548,950,522 | 1,049,478 |
| ២ | ក្រសួងមហាផ្ទៃ | 1,109,950,000 | 0 | 0 | 0 | 1,109,950,000 |
| ៣ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 248,492,000 | 84,048,000 | | 84,048,000 | 164,444,000 |
| ៤ | ក្រសួងផែនការ | 63,550,000 | 63,615,000 | | 63,615,000 | -65,000 |
| ៥ | ក្រសួងមុខងារសាធារណៈ | 78,500,000 | 0 | | 0 | 78,500,000 |
| ៦ | ក្រសួងកិច្ចការនារី | 254,500,000 | 104,960,400 | 120,220,350 | 225,180,750 | 29,319,250 |
| ៧ | ក្រសួងអប់រំ យុវជន និងកីឡា | 40,000,000 | 10,000,000 | 20,000,000 | 30,000,000 | 10,000,000 |
| ៨ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 668,344,000 | 124,389,000 | 100,862,000 | 225,251,000 | 443,093,000 |
| ៩ | ក្រសួងបរិស្ថាន | 8,038,584,000 | 8,027,758,000 | 10826000 | 8,038,584,000 | 0 |
| ១០ | ក្រសួងសុខាភិបាល | 70,000,000 | 0 | | 0 | 70,000,000 |
| ១១ | ក្រសួងសាធារណៈការ និងដឹកជញ្ជូន | 80,000,000 | 0 | | 0 | 80,000,000 |
| ១២ | ក្រសួងទេសចរណ៍ | 29,700,000 | 15,868,200 | 12,829,200 | 28,697,400 | 1,002,600 |
| ១៣ | ក្រសួងអភិវឌ្ឍន៍ជនបទ | 551,666,800 | 95,499,200 | 456,167,600 | 551,666,800 | 0 |
| ១៤ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនិវានុវត្តន៍ | 24,588,000 | 0 | 24,588,000 | 24,588,000 | 0 |
| ១៥ | ក្រសួងរ៉ែ និងថាមពល | 37,848,000 | 1,075,500 | 37,727,800 | 38,803,300 | -955,300 |
| ១៦ | ក្រសួងពាណិជ្ជកម្ម | 80,000,000 | 20,000,000 | 45,000,000 | 65,000,000 | 15,000,000 |
| ១៧ | ក្រសួងធនធានទឹក និងឧតុនិយម | 20,000,000 | 500,000 | 19,500,000 | 20,000,000 | 0 |
| ១៨ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 75,000,000 | 26,000,000 | 49,000,000 | 75,000,000 | 0 |
| ១៩ | ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ | | 0 | - | 0 | 0 |
| ២០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 105,000,000 | 46,000,000 | 39,000,000 | 85,000,000 | 20,000,000 |
| ២១ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 50,500,000 | 17,600,000 | 300,000 | 17,900,000 | 32,600,000 |
| | **សរុប** | **20,176,222,800** | **10,753,378,300** | **7,368,906,472** | **18,122,284,772** | **2,053,938,028** |

# វឌ្ឍនភាពនៃការអនុវត្តថវិកាប្រចាំឆ្នាំរបស់រាជធានី ខេត្ត (គិតជារៀល)

| ល.រ. | រាជធានី ខេត្ត | ថវិកាជារៀល | ថវិកាចំណាយ | | | សមតុល្យ |
|---|---|---|---|---|---|---|
| | | | ឆមាសទី១ | ឆមាសទី២ | សរុបចំណាយ | |
| ១ | បន្ទាយមានជ័យ | 229,272,000 | 99,831,000 | 112,703,000 | 212,534,000 | **16,738,000** |
| ២ | បាត់ដំបង | 988,852,000 | 56,000,000 | | 56,000,000 | **932,852,000** |
| ៣ | កំពង់ចាម | 1,098,214,400 | 77,623,000 | 302,557,900 | 380,180,900 | **718,033,500** |
| ៤ | កំពង់ឆ្នាំង | 194,487,000 | 12,060,000 | 150,376,165 | 162,436,165 | **32,050,835** |
| ៥ | កំពង់ស្ពឺ | 305,396,000 | 130,000,000 | 157,396,000 | 287,396,000 | **18,000,000** |
| ៦ | កំពង់ធំ | 370,744,500 | 38,798,900 | | 38,798,900 | **331,945,600** |
| ៧ | កំពត | 1,104,599,000 | 79,850,500 | 994,854,500 | 1,074,705,000 | **29,894,000** |
| ៨ | កណ្ដាល | 802,990,000 | 70,472,000 | | 70,472,000 | **732,518,000** |
| ៩ | កោះកុង | 483,634,000 | 72,354,000 | 384,943,600 | 457,297,600 | **26,336,400** |
| ១០ | ក្រចេះ | 316,852,000 | 58,956,410 | 89,837,590 | 148,794,000 | **168,058,000** |
| ១១ | មណ្ឌលគិរី | 309,594,000 | 29,974,600 | | 29,974,600 | **279,619,400** |
| ១២ | ភ្នំពេញ | 2,069,294,000 | 212,515,400 | 1,648,755,600 | 1,861,271,000 | **208,023,000** |
| ១៣ | ព្រះវិហារ | 172,285,000 | 35,106,360 | 130,088,640 | 165,195,000 | **7,090,000** |
| ១៤ | ព្រៃវែង | 516,684,000 | 44,130,000 | 235,870,000 | 280,000,000 | **236,684,000** |
| ១៥ | ពោធិ៍សាត់ | 208,070,000 | 13,342,500 | 34,693,500 | 48,036,000 | **160,034,000** |
| ១៦ | រតនគិរី | 179,200,000 | 30,200,000 | 109,776,000 | 139,976,000 | **39,224,000** |
| ១៧ | សៀមរាប | 695,692,000 | 22,580,500 | 503,789,900 | 526,370,400 | **169,321,600** |
| ១៨ | ព្រះសីហនុ | 261,600,000 | 21,630,000 | | 21,630,000 | **239,970,000** |
| ១៩ | ស្ទឹងត្រែង | 186,359,000 | 17,046,000 | 109,070,000 | 126,116,000 | **60,243,000** |
| ២០ | ស្វាយរៀង | 254,726,000 | 93,400,000 | | 93,400,000 | **161,326,000** |
| ២១ | តាកែវ | 284,300,000 | 218,584,300 | 65,714,200 | 284,298,500 | **1,500** |
| ២២ | ឧត្ដរមានជ័យ | 157,264,000 | 25,152,000 | 95,921,400 | 121,073,400 | **36,190,600** |
| ២៣ | កែប | 76,700,000 | 12,660,000 | 57,400,000 | 70,060,000 | **6,640,000** |
| ២៤ | ប៉ៃលិន | 140,245,000 | 390,000 | 8,702,000 | 9,092,000 | **131,153,000** |
| ២៥ | ត្បូងឃ្មុំ | 515,134,000 | 50,560,000 | 305,077,900 | 355,637,900 | **159,496,100** |
| | **សរុប** | **11,922,187,900** | **1,523,217,470** | **5,497,527,895** | **7,020,745,365** | **4,901,442,535** |

# ទិន្នន័យភាពនៃការអនុវត្តថវិកាប្រចាំឆ្នាំរបស់ដៃគូអភិវឌ្ឍ (គិតជារៀល)

| ល.រ. | គម្រោង | ប្រភពមូលនិធិ | ថវិកា | ការអនុវត្តចំណាយ | | | សមតុល្យ |
|---|---|---|---|---|---|---|---|
| | | | | ឆមាសទី១ | ឆមាសទី២ | សរុបចំណាយ | |
| ១ | ការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍកសិកម្មខ្នាតតូច ជំហានទី២ | ADB | 65,811,200,000 | 49,568,648,000 | 4,949,692,000 | 54,518,340,000 | 11,292,860,000 |
| ២ | ការផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីធន់នឹងការប្រែប្រួលអាកាសធាតុ | IFAD | 5,600,000,000 | 2,818,280,000 | 2,781,720,000 | 5,600,000,000 | 0 |
| ៣ | លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាថាមពលពន្លឺព្រះអាទិត្យសម្រាប់វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទនៅកម្ពុជា | UNDP | 262,704,000 | 77,113,760 | 166,664,200 | 243,777,960 | 18,926,040 |
| ៤ | នវានុវត្តនៃការផ្គត់ផ្គង់ទឹកស្អាតដែលធន់នឹងការប្រែប្រួលអាកាសធាតុ | UNCDF | 1,106,560,000 | 246,716,080 | 193,087,920 | 439,804,000 | 666,756,000 |
| ៥ | ពង្រឹងប្រព័ន្ធស្បៀងនៅមូលដ្ឋានដែលមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ | WFP | 4,661,348,000 | 1,998,917,200 | 2,593,322,800 | 4,592,240,000 | 69,108,000 |
| ៦ | កម្មវិធីកំណែទម្រង់រដ្ឋបាលបែបវិមជ្ឈការ និងធ្វើឱ្យប្រសើរឡើងការផ្តល់សេវាជូនប្រជាពលរដ្ឋ | GIZ | 12,525,500,000 | - | | 0 | 12,525,500,000 |
| ៧ | ការលើកកម្ពស់អាហារូបត្ថម្ភនៅកម្ពុជា | WB | 9,948,776,000 | 2,427,963,200 | 6,724,280,760 | 9,152,243,960 | 796,532,040 |
| ៨ | ពង្រឹងភាពអាចដល់ស្ត្រីដើម្បីសង្គមធន់នឹងការប្រែប្រួលអាកាសធាតុ | UNEP | 86,904,000 | 43,452,000 | 43,452,000 | 86,904,000 | 0 |
| ៩ | គម្រោងលើកកម្ពស់វិស័យសេវាសង្គម | UNICEF | 2,870,000,000 | 968,504,000 | | 968,504,000 | 1,901,496,000 |
| ១០ | គម្រោងសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | WB | 4,477,465,120 | 840,736,000 | 2,333,560,000 | 3,174,296,000 | 1,303,169,120 |
| ១១ | ការអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ | WB, EU, USAID, OXFAM | 13,472,288,000 | 7,145,460,000 | 4,885,498,400 | 12,030,958,400 | 1,441,329,600 |
| ១២ | គម្រោងគាំទ្រស្ថាប័នទទួលហិរញ្ញប្បទានផ្ទាល់នៅកម្ពុជា | GCF | 2,068,000,000 | 18,800,856 | 169,207,144 | 188,008,000 | 1,879,992,000 |
| ១៣ | ការធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានទិន្នន័យព័ត៌មានវិនិយោគអាកាសធាតុ | CCA | 58,380,000 | 0 | 49,428,000 | 49,428,000 | 8,952,000 |
| | **សរុប** | | **122,949,125,120** | **66,154,591,096** | **24,889,913,224** | **91,044,504,320** | **31,904,620,800** |

# ឧបសម្ព័ន្ធទី៣ ÷ ស្ថានភាពនៃការគ្រប់គ្រងហានិភ័យ

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| | **សមាសភាគទី១ ៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់** | | | | | |
| ១ | ការបន្តរីករាលដាលនៃជំងឺកូវីដ-១៩ និងគ្រោះមហន្តរាយធម្មជាតិនាំឱ្យពន្យារពេល និងផ្អាកការអនុវត្តសកម្មភាពនានានៃ ផ.ស.ថ. | មធ្យម | ខ្ពស់ | ➢ ពិនិត្យ និងកែសម្រួល ផ.ស.ថ. ដោយផ្តោតលើសកម្មភាពមានអាទិភាពខ្ពស់បំផុត និងមានភាពចាំបាច់ជាងគេ<br>➢ រៀបចំ និងពង្រឹងការអនុវត្តសកម្មភាពនានាតាមរយៈប្រព័ន្ធអនឡាញ | – ស្ថាប័នអនុវត្តទាំងអស់ | ➢ ផ.ស.ថ. ឆ្នាំ២០២២ បានរៀបចំដោយផ្តោតលើសកម្មភាពមានអាទិភាពខ្ពស់បំផុត និងមានភាពចាំបាច់ជាងគេ<br>➢ សកម្មភាពជាច្រើនបានអនុវត្តតាមរយៈប្រព័ន្ធអនឡាញ |
| ២ | ធនធានសម្រាប់សកម្មភាពស្នូលនៃកំណែទម្រង់ដែលបានសន្យាគាំទ្រដោយក្រសួង ស្ថាប័ន និងរាជធានី ខេត្ត មិនបានផ្តល់គ្រប់ចំនួន និងទាន់ពេលវេលា | ទាប | ខ្ពស់ | ➢ ពង្រឹងការតាមដានការអនុវត្តគ្រោងថវិកាឆ្នាំ២០២២របស់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត<br>➢ ពង្រឹងការតាមដានការអនុវត្តសេចក្តីសម្រេចរួម<br>➢ ពង្រឹងទំនាក់ទំនង និងកិច្ចសហការជាមួយ MEF ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តថវិកាសម្រាប់សកម្មភាពស្នូលនៃកំណែទម្រង់ | – ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ | ➢ ក្រសួង ស្ថាប័ន និងរាជធានី ខេត្តបានគ្រោងថវិកាក្នុងចំនួនសម ស្របសម្រាប់អនុវត្ត ផ.ស.ថ. ឆ្នាំ២០២២របស់ខ្លួន<br>➢ លេខាធិការដ្ឋាន គ.ជ.អ.ប. បានតាមដានការអនុវត្ត សេចក្តីសម្រេចរួមជាប្រចាំ |
| ៣ | ភាពអសកម្មភាពនៃគណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលនាំឱ្យ កិច្ចដំណើរការ និងប្រសិទ្ធភាពនៃការងារកំណែទម្រង់មានការថយចុះ រួមបញ្ចូលទាំងការអនុវត្ត ផ.ស.ថ. សេចក្តីសម្រេចរួម និងកិច្ចព្រមព្រៀងនានា | មធ្យម | មធ្យម | ➢ ពង្រឹងការតាមដាន និងការអនុវត្តការងារ កំណែទម្រង់ដោយ គ.ជ.អ.ប. តាមរយៈ កិច្ចប្រជុំ គ.ជ.អ.ប.<br>➢ ពង្រឹងការរៀបចំកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការ អនុវត្ត ផ.ស.ថ. ជាមួយស្ថាប័នអនុវត្តនានា | – គ.ជ.អ.ប.<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | ➢ លេខាធិការដ្ឋាន គ.ជ.អ.ប. បានតាមដាន និងគាំទ្រជាប្រចាំដល់ស្ថាប័នអនុវត្តក្នុងការអនុវត្តសេចក្តីសម្រេចរួមឆ្នាំ២០២២ |

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| | **សមាសភាគទី២ ៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | |
| ១ | ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុកមិនអាចបំពេញតួនាទីរបស់ខ្លួនបានពេញលេញក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងត្រួតពិនិត្យលើការអនុវត្តការងាររបស់គណៈអភិបាល និងបុគ្គលិករបស់ខ្លួន | ខ្ពស់ | ខ្ពស់ | ➢ រៀបចំវគ្គបណ្ដុះបណ្ដាលដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើនការយល់ដឹងបន្ថែមទៅក្នុងការអនុវត្តតួនាទី និងអាណត្តិការងាររបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ<br>➢ ការរៀបចំឱ្យមានគម្រោងចំណាយច្បាស់លាស់របស់ក្រុមប្រឹក្សានៅក្នុងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | – ក្រសួងមហាផ្ទៃ<br>– ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | ➢ សាលាជាតិរដ្ឋបាលមូលដ្ឋាន និងសមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបាន រៀបចំវគ្គបណ្ដុះបណ្ដាលដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើនការយល់ដឹងបន្ថែមក្នុងការអនុវត្តតួនាទី និងអាណត្តិការងាររបស់ខ្លួន |
| ២ | មន្ត្រីរដ្ឋបាលខេត្តមិនផ្លាស់ប្ដូរទម្លាប់ក្នុងការគ្រប់គ្រង និងអន្តរាគមន៍លើការអនុវត្តការងាររបស់រដ្ឋបាលមូលដ្ឋានឱ្យទៅជាការជួយគាំទ្រផ្នែកបច្ចេកទេស និងការប្រឹក្សាយោបល់ | មធ្យម | ខ្ពស់ | ➢ ផ្ដល់គោលការណ៍ណែនាំ និងការបណ្ដុះបណ្ដាលថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលខេត្តអំពីទំនាក់ទំនងការងាររវាងរដ្ឋបាលខេត្ត និងរដ្ឋបាលមូលដ្ឋាន<br>➢ ជំរុញ និងពង្រឹងការតាមដានត្រួតពិនិត្យ និងផ្ដល់អន្តរាគមន៍ពីក្រសួងមហាផ្ទៃ ក្នុងករណីដែលមានអាកប្បកិរិយា និងសកម្មភាពមិនសមស្របរបស់មន្ត្រីនៃរដ្ឋបាលខេត្ត | – ក្រសួងមហាផ្ទៃ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– | ➢ សាលាជាតិរដ្ឋបាលមូលដ្ឋានបានសម្របសម្រួល និងរៀបចំវគ្គបណ្ដុះបណ្ដាលចំនួន២៧វគ្គដល់បុគ្គលិកថ្នាក់ក្រោមជាតិចំនួន៧៦២នាក់ក្នុងនោះស្ត្រីមានចំនួន២០៣នាក់ រួមបញ្ចូលទាំងកម្មវិធីអប់រំភាពជាអ្នកដឹកនាំ។ |
| ៣ | ថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិមិនសូវយកចិត្តទុកដាក់ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្ដីពីការបង្កើនចំនួនស្ត្រី | មធ្យម | ខ្ពស់ | ➢ ពង្រឹងការផ្សព្វផ្សាយអំពីផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋាន និងសេចក្ដីណែនាំនានាស្ដីពី ការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងដឹកនាំ<br>➢ ពង្រឹងការត្រួតពិនិត្យ និងការគាំទ្រក្នុងការ អនុវត្តផែនការយុទ្ធសាស្ត្រស្ដីពីការបង្កើនចំនួនស្ត្រីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | – លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– ក្រសួងកិច្ចការនារី<br>– ក្រសួងមហាផ្ទៃ | ➢ ថ្នាក់ជាតិ និងរាជធានី ខេត្តបានផ្សព្វផ្សាយអំពីផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋាន និង សេចក្ដីណែនាំនានាស្ដីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងដឹកនាំ |

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| | **សមាសភាគទី៣ ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស** | | | | | |
| ១ | សិទ្ធិអំណាចក្នុងការជ្រើសរើស និងរៀបចំបុគ្គលិកមិនអាចអនុវត្តបាន តាមគោលការណ៍ បទប្បញ្ញត្តិដែលបានកំណត់ | មធ្យម | មធ្យម | ➢ ការរៀបចំសេចក្តីណែនាំបន្ថែមរបស់ថ្នាក់ជាតិដើម្បីពង្រឹងការអនុវត្តគោលការណ៍ និងបទប្បញ្ញត្តិដែលបានកំណត់រួចហើយ<br>➢ ការពង្រឹងការតាមដាន ការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស និងរៀបចំបុគ្គលិក | – ក្រសួងមុខងារសាធារណៈ<br>– ក្រសួងមហាផ្ទៃ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | ➢ សេចក្តីណែនាំស្តីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់ គ្រងបុគ្គលិករដ្ឋបាលរាជធានី ខណ្ឌ សេចក្តីណែនាំស្តីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាខេត្ត និងសេចក្តីណែនាំស្តីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលក្រុង ស្រុក ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តនៅខែមករា ឆ្នាំ២០២២ |
| ២ | ការវាយតម្លៃបុគ្គលិកមិនត្រូវបានអនុវត្តទៀងទាត់ និងត្រឹមត្រូវ | ខ្ពស់ | មធ្យម | ➢ ពង្រឹងការគាំទ្រ ការតាមដានត្រួតពិនិត្យការអនុវត្តផែនការវាយតម្លៃបុគ្គលិកទាំងក្នុង ក្របខ័ណ្ឌផ្ទៃក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ និងពីថ្នាក់ជាតិ | – ក្រសួងមហាផ្ទៃ<br>– ក្រសួងមុខងារសាធារណៈ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | ➢ ការវាយតម្លៃបុគ្គលិកនឹងអនុវត្តនៅចុងឆ្នាំ២០២២ |
| ៣ | ខ្វះការចូលរួមរបស់មន្ទីរ អង្គភាព ជំនាញ នាំឱ្យការអភិវឌ្ឍសមត្ថភាពក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តមុខងារដែល បានផ្ទេរមិនសូវមាន ប្រសិទ្ធភាព | មធ្យម | មធ្យម | ➢ ពង្រឹងកិច្ចសហការ និងផ្តល់ការគាំទ្រដល់មន្ទីរ អង្គភាពជំនាញក្នុងការអភិវឌ្ឍសមត្ថភាពក្រុង ស្រុក ខណ្ឌ<br>➢ ពង្រឹងការរៀបចំ និងការអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពដល់ក្រុង ស្រុក ខណ្ឌ តាមរយៈ វិធីសាស្ត្រផ្សេងៗ | – លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– រដ្ឋបាលរាជធានី ខេត្ត | ➢ សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំវគ្គបណ្តោះបណ្តាលដោយបានសហការជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ<br>➢ រាជធានី ខេត្តបានអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពដោយសហការជិតស្និទ្ធជាមួយមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធនានា |
| ៤ | ពុំមានធនធានគ្រប់គ្រាន់ក្នុងការអនុវត្តផែនការអភិវឌ្ឍសមត្ថភាពអន្តរកាលរបស់សាលាជារដ្ឋបាលមូលដ្ឋាន | ខ្ពស់ | មធ្យម | ➢ ពង្រឹងការតាមដានក្រសួងមហាផ្ទៃក្នុងការរៀបចំ និងការវិភាជថវិកាសម្រាប់អនុវត្តផែនការអភិវឌ្ឍសមត្ថភាពរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន<br>➢ សម្របសម្រួល និងសហការជិតស្និទ្ធជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការផ្តល់ថវិកាគាំទ្រផែនការអភិវឌ្ឍសមត្ថភាពរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន | – ក្រសួងមហាផ្ទៃ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | ➢ សាលាជាតិរដ្ឋបាលមូលដ្ឋានបានសម្របសម្រួល និងរៀបចំវគ្គបណ្តុះបណ្តាលចំនួន២៧វគ្គដល់បុគ្គលិកថ្នាក់ក្រោមជាតិចំនួន៧៦២នាក់ក្នុងនោះស្ត្រីមានចំនួន២០៣នាក់ |

| ល.រ. | ហានិភ័យ | លទ្ធភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| | | | | ➢ សម្របសម្រួល និងសហការជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីកៀរគរធនធានសម្រាប់អនុវត្តផែនការអភិវឌ្ឍសមត្ថភាពរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន | | |
| | **សមាសភាគទី៤ ៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការ និងថវិកាថ្នាក់ក្រោមជាតិ** | | | | | |
| ១ | រដ្ឋបាលក្រុង ស្រុកមានធនធានថវិកាផ្នែកអភិវឌ្ឍតិចតួចដែលមិនអាចអនុវត្តមុខងារផ្តល់សេវា ក៏ដូចជាការឆ្លើយតបនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព | មធ្យម | ខ្ពស់ | ➢ ពិនិត្យ និងកែសម្រួលលិខិតបទដ្ឋាន និង សេចក្តីណែនាំនានាដែលពាក់ព័ន្ធនឹងចំណាយផ្នែកអភិវឌ្ឍន៍របស់ក្រុង ស្រុក<br>➢ សិក្សា និងរៀបចំលិខិតបទដ្ឋាននានាអំពី ការបង្កើនចចំណូលដល់រដ្ឋបាលក្រុង ស្រុក | – ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | ➢ កំពុងសិក្សា និងពិនិត្យមើលលិខិតបទដ្ឋាន និង សេចក្តីណែនាំនានាដែលពាក់ព័ន្ធនឹងចំណាយផ្នែកអភិវឌ្ឍន៍របស់ក្រុង ស្រុក |
| ២ | ការផ្ទេរការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវពន្យារពេល | មធ្យម | ខ្ពស់ | ➢ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃត្រូវបន្តធ្វើការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងផ្ទេរមុខងារ ពាក់ព័ន្ធនានា | – ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | ➢ ក្រសួង ស្ថាប័នពាក់ព័ន្ធកំពុងពិនិត្យ និងរៀបចំទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមមុខងារដែលបានផ្ទេរ |
| ៣ | ការបន្តរីករាលដាលនៃជំងឺកូវីដ-១៩ និងគ្រោះធម្មជាតិនាំឱ្យមានការកាត់បន្ថយថវិកាសម្រាប់ការអនុវត្តសកម្មភាពនានានៃ ផ.ស.ថ. ដើម្បីយកទៅប្រើប្រាស់ដើម្បីការពារ និងទប់ស្កាត់ហានិភ័យនេះ | មធ្យម | ខ្ពស់ | ➢ ពិនិត្យ និងកែសម្រួល ផ.ស.ថ. ដោយផ្តោតលើសកម្មភាព និងគម្រោងមានអាទិភាពខ្ពស់បំផុត និងមានភាពចាំបាច់ជាងគេ<br>➢ រៀបចំ និងពង្រឹងការអនុវត្តសកម្មភាពនានាតាមរយៈប្រព័ន្ធអនឡាញ | – ស្ថាប័នអនុវត្តទាំងអស់ | ➢ ផ.ស.ថ. ឆ្នាំ២០២២ បានរៀបចំដោយផ្តោតលើសកម្មភាពមានអាទិភាពខ្ពស់បំផុត និងមានភាពចាំបាច់ជាងគេ<br>➢ សកម្មភាពជាច្រើនបានអនុវត្តតាមរយៈប្រព័ន្ធអនឡាញ |
| | **សមាសភាគទី៥ ៖ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន** | | | | | |
| ១ | ភាពយឺតយ៉ាវក្នុងការរៀបចំលិខិតបទដ្ឋាន និងឯកសារបច្ចេកទេសនានាសម្រាប់ការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលលក្រុង ស្រុក | ទាប | ខ្ពស់ | ➢ ជំរុញ និងពង្រឹងការរៀបចំឯកសារចាំបាច់នានានៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធនានា<br>➢ លេខាធិការដ្ឋាន គ.ជ.អ.ប. តាមដាន សហការ និងផ្តល់ការគាំទ្រដល់ក្រសួង ស្ថាប័នក្នុ ងការរៀបចំឯកសារពាក់ព័ន្ធនានា | – ក្រសួង ស្ថាប័ន<br>– លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– | ➢ ក្រសួង ស្ថាប័នចំនួន១៤ បានរៀបចំបញ្ចប់ឯកសារបច្ចេកទេសនានាសម្រាប់ការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក |

| ល.រ. | ហានិភ័យ | កាលកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| ២ | រដ្ឋបាលក្រុង ស្រុក ខណ្ឌមួយចំនួន ពុំមានបុគ្គលិក និងសមត្ថភាពសមស្រប នាំឱ្យការអនុវត្តមុខងារដែលបានផ្ទេរ ពុំមានប្រសិទ្ធភាព | ទាប | មធ្យម | ➢ សម្របសម្រួល និងពង្រឹងកិច្ចសហការរវាង កម្មវិធីកំណែទម្រង់ទាំងបីក្នុងការសម្របសម្រួលដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានឡើង<br>➢ ពង្រឹងការតាមដាន ការគាំទ្រ និងការអភិវឌ្ឍសមត្ថភាពក្រុង ស្រុក ខណ្ឌនៅនឹងកន្លែង<br>➢ សិក្សា និងពិនិត្យមើលជម្រើសនានាក្នុងការ ផ្ទេរបុគ្គលិកពីមន្ទីរ អង្គភាពជំនាញទៅឱ្យរដ្ឋបាល ក្រុង ស្រុក ខណ្ឌ | – ក្រសួងមុខងារសាធារណៈ<br>– ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– ក្រសួង ស្ថាប័ន<br>– រាជធានី ខេត្ត | ➢ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរាជធានី ខេត្តបានចុះត្រួតពិនិត្យ និងគាំទ្រក្រុង ស្រុក ខណ្ឌជាប្រចាំក្នុងការអនុវត្តមុខងារដែលបានផ្ទេរ |
| ៣ | មុខងារជាជម្រើសពាក់ព័ន្ធនឹងសេវាសង្គមមិនអាចអនុវត្តស្របទៅតាម ឆន្ទានុសិទ្ធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | មធ្យម | មធ្យម | ➢ គោលការណ៍ណែនាំច្បាស់លាស់ស្តីពីការជ្រើសរើស ការរៀបចំ និងការអនុវត្តមុខងារជាជម្រើសដែលពាក់ព័ន្ធនឹងសេវាសង្គម<br>➢ ការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់អាទិភាពដល់ការចំណាយលើការផ្តល់សេវាសង្គមសម្រាប់ក្រុមក្រីក្រ និងងាយរងគ្រោះ | – សួងមហាផ្ទៃ<br>– លេខាធិការដ្ឋាន គ.ជ.អ.ប. | ➢ ក្រសួងមហាផ្ទៃបានពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ អំពីគោលការណ៍ និងសេចក្តីណែនាំដែលពាក់ព័ន្ធនឹងការអនុវត្តគម្រោងសកម្មភាពសេវាសង្គម |
| ៤ | រដ្ឋបាលថ្នាក់ក្រោមជាតិយកចិត្តទុកដាក់តិចតួចអំពីអាទិភាពរបស់ស្ត្រី និងក្រុមជនងាយរងគ្រោះទាំងនៅក្នុងការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងគម្រោងថវិកានានា | ខ្ពស់ | មធ្យម | ➢ រៀបចំផែនការសកម្មភាពនិង ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈឆ្លើយតបនឹងយេនឌ័រ<br>➢ ពង្រឹងការគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>➢ ពង្រឹងការវាយតម្លៃ និងតាមដានដល់ការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំ និងអនុវត្តកម្មវិធីផ្តល់ពានរង្វាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបំពេញការងារបានល្អ។ | – លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– ក្រសួងមហាផ្ទៃ<br>– | ➢ ក្រសួងមហាផ្ទៃកំពុងអនុវត្តកម្មវិធីពានរង្វាន់សេវាសង្គមសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកទឹកចិត្តថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់សេវាសង្គមដល់ប្រជាពលរដ្ឋ និងក្រុមជនងាយរងគ្រោះនានា |
| ៥ | ក្រុង ស្រុក ខណ្ឌមួយចំនួនមិនសូវ យកចិត្តទុកដាក់ និងផ្តួចផ្តើមគំនិតក្នុងការអនុវត្តលិខិតបទដ្ឋាននានា ដែលមាន និង | ទាប | ខ្ពស់ | ➢ ពង្រឹងការតាមដាន និងគាំទ្រក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តមុខងារដែលបានផ្ទេរ | – លេខាធិការដ្ឋាន គ.ជ.អ.ប.<br>– ក្រសួង ស្ថាប័ន | ➢ ក្រសួង ស្ថាប័ន និងរាជធានី ខេត្តបានពង្រឹងការចុះតាមដាន និងគាំទ្រក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តមុខងារដែលបានផ្ទេរ |

| ល.រ. | ហានិភ័យ | ភាពកើតមានឡើង | ផលប៉ះពាល់ | វិធានការកាត់បន្ថយ | អ្នកទទួលខុសត្រូវ | ស្ថានភាពអនុវត្ត |
|---|---|---|---|---|---|---|
| | មុខងារនានាដែលបាន ផ្ទេរនាំឱ្យការគាំទ្របស់រាជធានី ខេត្ត មិនមានប្រសិទ្ធភាព | | | ➢ ធ្វើការណែនាំដល់ក្រុង ស្រុក ខណ្ឌដែលអសកម្ម | – រាជធានី ខេត្ត<br>– | |
| ៦ | ការបន្តកែវាលដាលនៃជំងឺកូវីដ-១៩ និងគ្រោះធម្មជាតិនាំឱ្យពន្យារពេល និងផ្អាកសកម្មភាពនៃការរៀបចំ និងការអនុវត្តសកម្មភាព និងគម្រោងនានានៃ ផ.ស.ថ. | មធ្យម | ខ្ពស់ | ➢ ពិនិត្យ និងកែសម្រួល ផ.ស.ថ. ដោយផ្តោតលើសកម្មភាពមានអាទិភាពខ្ពស់បំផុត និង មានភាពចាំបាច់ជាងគេ<br>➢ រៀបចំ និងពង្រឹងការអនុវត្តសកម្មភាពនានាតាមរយៈប្រព័ន្ធអនឡាញ | – ស្ថាប័នអនុវត្តទាំងអស់ | ➢ ផ.ស.ថ. ឆ្នាំ២០២២ បានរៀបចំដោយផ្តោតលើសកម្មភាពមានអាទិភាពខ្ពស់បំផុត និងមានភាពចាំបាច់ជាងគេ<br>➢ សកម្មភាពជាច្រើនបានអនុវត្តតាមរយៈប្រព័ន្ធអនឡាញ |
| ៧ | រដ្ឋបាលថ្នាក់ក្រោមជាតិពុំមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ក្នុងការចំណាយបន្ថែមលើការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុសម្រាប់គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានា | មធ្យម | ខ្ពស់ | ➢ កៀរគរធនធានបន្ថែមពីមូលនិធិអាកាសធាតុបៃតង និងពីប្រភពផ្សេងទៀត ដើម្បីផ្តល់ហិរញ្ញប្បទានបន្ថែមដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការ ពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ | – លេខាធិការដ្ឋាន គ.ជ.អ.ប. | ➢ លេខាធិការដ្ឋាន គ.ជ.អ.ប. បាន និងកំពុងសម្របសម្រួលជា មួយគម្រោង កម្មវិធីមួយចំនួន ដើម្បីកៀរគរធនធានសម្រាប់ ការអនុវត្តគម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយដូចជាគម្រោង LGCC/WRP, GCF/Readiness, IFAD/ASPIRE, WFP/SRELFOODS, UNEP/ Empower។ល។ |
| ៨ | រដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់មានការយល់ដឹងច្បាស់លាស់អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ | មធ្យម | មធ្យម | ➢ បញ្ចូលការលើកកម្ពស់ចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុទៅក្នុងវគ្គបណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | – លេខាធិការដ្ឋាន គ.ជ.អ.ប. | ➢ ការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតកាចសាហាវបានបញ្ជ្រាបក្នុងវគ្គភាពជាអ្នកដឹកនាំដែលបានរៀបចំដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន |